១០

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤១ ខែ តុលា

ព.ស. ២៥១៣ គ.ស. ១៩៦៩

- ភ្នំពេញ -

១០

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ

## ផ្នែកសាសនា

ទំព័រ

១– ទស្សនវិជ្ជាពុទ្ធសាសនា ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង ១០១៧

២– រឿងបណ្ឌិតសាមណេរ លោក ប៊ូ-ប៊ូ ប្រែរៀបរៀង . . . ១០៣០

## ផ្នែកអក្សរសាស្ត្រ

៣– វិចារណកថា: ការផ្លាស់ប្ដូរប្រពៃណីក្នុងរឿងរកគូស្រករ លោក ផេង-ជ្រីវ រៀបរៀង . . . . . . . . ១០៥៨

៤– ចម្រៀង បញ្ចសិខគន្ធព្វទេវបុត្រ លោក ញូង-សៀង រៀបរៀង . . ១០៦៥

៥– វចនានុក្រមសំស្ក្រឹតខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ១០៧៤

៦– រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ១០៧៨

៧– រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង . . ១១០១

៨– កម្រងទំនុកបុរាណខ្មែរ សហ. លី-ធាមតេង ប្រមូលប្រែង . . . ១១២០

## ផ្នែកកំណាត់–ប្រវត្តិការណ៍

៩– ព្រះរាជជីវប្រវត្តិ នៃសម្ដេចព្រះមហាសុមេធាធិបតី (ជួន-ណាត)
ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ . . . ១១២៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជា៛ ២៣០៛០០ ។

# ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យដុសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា · |

ប ព

## ទស្សនវិជ្ជាពុទ្ធសាសនា

ព្រះមហាវីរយបណ្ឌិតោ ទាំង - ទាស់ រៀបរៀង

## (តពីលេខមុន)

គោលធំបំផុត ក្នុងពុទ្ធសាសនា ដោយពិត និយាយចំពោះតែការត្រាស់ដឹងអរិយសច្ច ដែលព្រះសម្ពុទ្ធប្រើពាក្យថា: "ធម្មចក្ខុ=ភ្នែកធម៌ ឬមានភ្នែកឃើញធម៌" កើតឡើង, បានសេចក្ដីថា "ភ្នែកមានធូលីគឺរាគៈទៅប្រាសហើយ បានឃើញសច្ចធម៌ បានលុះសច្ចធម៌ បានត្រាស់ដឹងសច្ចធម៌ បានចាក់ធ្លុះសច្ចធម៌ មានក្ដីសង្ស័យកន្លងផុតហើយ ឃើញអ្វីៗឃើញដោយបញ្ញាចក្ខុ ដោយពិត ទៅតាមពិត=យថាភូតំ ញាណទស្សនំ, យថាភូតទស្សនញ្ញាណ ៗ បើតាមសេចក្ដីដែលយើងបានសិក្សាគម្ពីរដីកាពុទ្ធសាសនា យើងបានឃើញថា ព្រះសម្ពុទ្ធទ្រង់

ត្រាស់ទុកក្នុងបឋមទេសនាថា (១) "ភ្នែក កើតហើយ ញាណ កើតហើយ បញ្ញា កើតហើយ វិជ្ជា កើតហើយ ពន្លឺកើតហើយ = ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ" ។ ដូច្នេះ ពុទ្ធសាសនា និយាយតែពីការឃើញច្បាស់ដោយ ញាណទស្សនៈ មិនមែននិយាយជំនឿដូចជំនឿ = Croyance, Foi; Faith, Belief នោះទេ ។

ប្រស្នាជំនឿនេះ មានច្រើនអន្លើណាស់ ។ ក្នុងសម័យពុទ្ធកាល មានព្រាហ្មណ៍ច្រើននាក់ សុទ្ធតែជាអ្នកកាន់ជំនឿតឹងរឹង (Orthodox) ចេះប្រកែកជជែកគ្នាតឹងក ក្នុងការប្រើជំនឿទៅតាមប្រពៃណី ដែលខ្លួនធ្លាប់តែប្រកាន់ជឿតរៀងមក ហើយដែលខ្លួនចុះចិត្តស៊ប់ជឿថា ជាសច្ចៈឯក មិនមានប្រស្នាចោទតក៏ឡើយ ។ ថ្ងៃមួយ មានពួកព្រាហ្មណ៍អ្នកប្រាជ្ញច្រើននាក់ សុទ្ធតែបានដល់ត្រើយនៃត្រៃវេទ(២) ជជែកគ្នាពីប្រស្នាជំនឿនេះមិនដាច់ស្រេច បានចូលទៅគាល់ព្រះមានបុណ្យ ហើយលើកប្រស្នាជំនឿមកសាកសួរដេញដោល ។ បណ្ដាព្រាហ្មណ៍ទាំងនោះ មានព្រាហ្មណ៍ម្នាក់នៅក្មេងជាងគេ អាយុទើបតែបាន ១៦ ឆ្នាំ ឈ្មោះកា-បទិកៈ ជាព្រាហ្មណ៍មានការចេះដឹងប្រសើរជាងគេ គេទុកជាព្រាហ្មណ៍

---

១. ធម្មចក្កប្បវត្តនសូត្រ ។ ២. ព្រាហ្មណ៍អ្នកប្រាជ្ញសុទ្ធតែចេះវិជ្ជាព្រាហ្មណ៍ គ្រប់ប្រការ កាន់គម្ពីរ ៥ ជាដើម គឺគម្ពីរនិឃណ្ឌុ, អក្ខរប្បភេទ, កេដុភ, សិក្ខា និង និរុត្តិ, ឥតិហាសៈ ។

ឯក មានប្រាជ្ញាក្ដីថា បានទោទដណ្ដឹងព្រះមានបុណ្យថាៈ[១] ។

បពិត្រព្រះមានបុណ្យ ! មានគម្ពីរព្រាហ្មណ៍ គឺគម្ពីរ វេទ គេបានកេក្ញុកតៗមកដោយប្រពៃ តាមមុខបាឋតាមប្រពៃណី ។ គម្ពីរវេទ នេះ ព្រាហ្មណ៍គ្រប់គ្នាបានយល់គ្រប់គ្នាជាឯកច្ឆន្ទថាៈ "មន្ត្រវេទនេះ ជាសច្ចឯក មិនមានពីរទេ = ឯកំសច្ចំ អាទុតិយមិ ដទៃពីនេះសុទ្ធតែជាធម៌ខុស មិនមែនជាសច្ចៈទេ" ។ សេចក្ដីនេះតើព្រះសមណគោតម មានសេចក្ដីយល់ឃើញជាដូចម្ដេច ?

ព្រះសម្ពុទ្ធទ្រង់ព្រះសណ្ដាប់ហើយ ត្រាស់ក្លាង តបទៅវិញថាៈ ។

" ភារទ្វាជៈ ! បណ្ដាព្រាហ្មណ៍ទាំងអស់ មានព្រាហ្មណ៍ណាម្នាក់ ដែលអួតកាងថាខ្លួនបានដឹងច្បាស់ បានឃើញច្បាស់ដោយក្លួនខ្លួនឯងថា មន្ត្រៈវេទ នេះជាសច្ចឯកមិនមានពីរទេ ដទៃពីនេះសុទ្ធតែជាធម៌ខុសដែរឬទេ ?

" មិនមានទេ ពានប្រោស ! កាលទិកព្រាហ្មណ៍នេះ ជាគេដ៏ស្មោះត្រង់ឆ្លើយតបព្ទុទ្ធដីកាថា, ឥតមានព្រាហ្មណ៍ណាម្នាក់បានដឹង បានឮ បានឃើញដោយក្លួនខ្លួនឯងទេ " ។

" ភារទ្វាជៈ ! ព្រះសម្ពុទ្ធត្រាស់សួរតទៅទៀត, ចុះមានអាចារ្យណាម្នាក់ ឬ អាចារ្យតពីអាចារ្យដើម ដែលជាព្រាហ្មណ៍មានអាយុ

១- មជ្ឈិមនិកាយ ចង្កីសូត្រ មជ្ឈិមបណ្ណាសក សៀវភៅ ទី ២៥ ទំព័រ ១៨ ។

វែងហូតដល់ប្រាំពីរជួរគោត្រ ឬក៏ឫសីដើម (១) ដែលបានចងក្រងគម្ពីរ វេទ ទុកមក ហើយអ្នកអាងថាខ្លួនបានដឹងច្បាស់ បានឮច្បាស់ បានឃើញច្បាស់ដោយភ្នែកខ្លួនឯងថា មន្ត្រៈវេទ ជារបស់ឯកមិនមានពីរទេ ដទៃពីនេះសុទ្ធតែជាធម៌ខុសដែរឬទេ ” ?

“ ទេ ! ទេ ! តានប្រោស ! កាបទិកព្រាហ្មណ៍ក្មេងក្រាបទូលតបពុទ្ធដីកា , មិនមានអ្នកណា បានដឹង បានឮ បានឃើញដោយភ្នែកខ្លួនឯងទេ ” ។

ភារទ្វាជៈ ! ព្រះសម្ពុទ្ធត្រាស់តទៅ , ចម្លើយរបស់អ្នកនេះមើលទៅឃើញថា ព្រាហ្មណ៍ទាំងអស់សុទ្ធតែជាជួរគោត្រមនុស្សខ្វាក់ ៗ ព្រាហ្មណ៍ខ្វាក់ម្នាក់ ដៀពឹងផ្អែកទៅលើព្រាហ្មណ៍ខ្វាក់ម្នាក់ទៀត ដៀខ្វាក់តៗគ្នាហូតមកឫសីជំនាន់ដើម ដែលជាអ្នកចងក្រង វេទ ក៏មិនបានឃើញឫសីជំនាន់កណ្ដាល ក៏មិនបានឃើញដែរ ឫសីជំនាន់ក្រោយតៗមកទៀត ក៏រឹតតែមិនបានឃើញសោះទៅទៀត ។ ដូច្នេះតថាគត យល់ឃើញថា ចម្លើយរបស់អ្នកនេះ ប្រាប់តថាគតច្បាស់ថាស្ថានភាពព្រាហ្មណ៍ទាំងអស់ បើគិតគិតមើលឲ្យបញ្ច្រប់ ជាជួរគោត្រព្រាហ្មណ៍ខ្វាក់ ដូចជាជួរគោត្រមនុស្សខ្វាក់ហូតទាំងគោត្រ យកជា

---

១- ឫសីពីបូរាណសុទ្ធតែអ្នកជំនាញ គឺឫសីអដ្ឋកៈ, វាមកៈ, វាមទេវៈ, វេស្សាមិត្តៈ, យមតគ្គិ, អង្គីរសៈ, ភារទ្វាជៈ, វាសេដ្ឋៈ, កស្សបៈ, ភគុ ។

ការមិនបាន ។ តទៅព្រះសម្ពុទ្ធត្រាស់ទេសនាទូន្មានព្រាហ្មណ៍ទាំងនោះថា សេចក្ដីនេះមិនសមបើបុគ្គលជាអ្នកប្រាជ្ញប្រាកដដូចអ្នកគ្រប់គ្នាដែលជាអ្នកចេះដឹងប្រសើរ នៅតែទទូចប្រកាន់ជឿថា “មន្ត្រៈវេទជាសច្ចឯកមិនមានពីរ ដទៃពីនេះសុទ្ធតែជាចមិខុស” ដូច្នេះឡើយ ។

“ភារទ្វាជៈ! ព្រះសម្ពុទ្ធត្រាស់ដណ្ដឹងតទៅទៀត, ចុះអ្នកគ្រប់គ្នាយល់ឃើញសេចក្ដីនេះ ថាដូចម្ដេច ? បើមិនដូច្នោះទេ មានតែជំនឿព្រាហ្មណ៍ដែលអ្នកអួតអាងមកនេះ ជាអមូលិកា: = មិនមានបុសគល់ពិតប្រាកដ មែនឬទេ ?

“សូមទ្រង់ព្រះមេត្តាប្រោស ! កាបទិកព្រាហ្មណ៍ក្រាបបង្គំទូល, ជំនឿព្រាហ្មណ៍នេះ មិនមែនជាឥតហេតុផលទេ ពួកព្រាហ្មណ៍បានចូលទៅអង្គុយជិត បានសិក្សា រៀនសូត្រ បានឮតៗគ្នាមក ហើយទើបប្រកាន់ជឿដូច្នេះឯង” ។

“ភារទ្វាជៈ! ព្រះសម្ពុទ្ធត្រាស់តទៅ, កាលពីមុន អ្នកបាននិយាយថា “មានជំនឿ” ឥឡូវនេះ អ្នកនិយាយថា “បានឮតៗគ្នាមក បានជាមានជំនឿ„ ។

ភារទ្វាជៈ! ធម៌ ៥ ប្រការគឺ ១–ជំនឿ = សទ្ធា, ២ ការគាប់ចិត្ត = រុចិ, ៣–ការឮតៗតាមគ្នា = អនុស្សវ, ៤–ការត្រិះរិះនូវអាការ = អាការបរិវិតក្កៈ, ៥– ការចូលចិត្តតាមការ

យល់ឃើញ ការចូលចិត្តស៊ប់ = ទិដ្ឋិនិជ្ឈានក្ខន្តិ ទាំង ៥ ប្រការនេះ តែងមានវិបាក ២ ប្រការគឺ៖

ក- ហេតុណា ដែលបុគ្គលស៊ប់, ដែលបុគ្គលគាប់ចិត្ត, ដែលបុគ្គលពុតៗ តាមគ្នា, ដែលបុគ្គលត្រិះរិះនូវអាការ, ដែលបុគ្គលចូលចិត្តស៊ប់ តែហេតុនោះមិនមែនជាការពិត ក៏តែងមានដែរ

ខ- ហេតុណា ដែលបុគ្គលមិនជឿស៊ប់, ដែលបុគ្គលមិនគាប់ចិត្ត ដែលបុគ្គលមិនពុតៗ តាមគ្នា, ដែលមិនត្រិះរិះនូវអាការ, ដែលមិនចូលចិត្តស៊ប់ តែហេតុនោះ ជាការពិត ក៏តែងមានដែរ ។

ដូច្នេះ ធម៌ ៥ ប្រការនេះគឺ សទ្ធា រុចិ អនុស្សវ អាការ-បរិវិតក្ក ទិដ្ឋិនិជ្ឈានក្ខន្តិ មិនមែនជាពុទ្ធសាសនាទេ ។ ពុទ្ធសាសនិកជន ត្រូវវៀរចេញនូវធម៌ ៥ ប្រការនេះ ដែលជាធម៌ពាំងមិនឲ្យយល់សេចក្តីពិតបាន មិនត្រូវឲ្យធម៌នេះ បិតនៅក្នុងសន្តានចិត្តឡើយ ។

លំដាប់នោះ ព្រះសម្ពុទ្ធត្រាស់ទេសនាទូន្មានថា: "ការស្វែងរកសច្ចធម៌មិនត្រូវសម្រេចសេចក្តីអ្វីមួយដោយដាច់ខាតថា មានតែធម៌មួយនេះ វេទ ជាសច្ចឯក អ្វីដទៃទៀតសុទ្ធតែខុសទាំងអស់ ដូច្នេះឡើយ ។

"សូមទ្រង់ព្រះមេត្តាប្រោស! កាបទិកព្រាហ្មណ៍ក្រាបទូលសួរ, ដើម្បីស្វែងរកសច្ចធម៌ ឬការពារសច្ចធម៌ តើត្រូវប្រើឧត្តមគតិដូចម្តេច ?

ភារទ្វាជៈ ! ព្រះសម្ពុទ្ធត្រាស់ពន្យល់, មនុស្សម្នាក់ៗ តែងមានជំនឿ = សទ្ធា (Croyance, Foi) ។ បើនិយាយ គេអាចនិយាយបានថា នេះជាជំនឿ = សទ្ធា របស់ខ្ញុំ ទៅទល់ពេលណាដែលគេរកសច្ចធម៌ឃើញ ។ ប៉ុន្តែជំនឿនេះគេមិនត្រូវជម្រុលទៅដល់ការសម្រេចចិត្តដាច់ខាតថា នេះជាសច្ចឯក ឯធម៌ដទៃទៀតសុទ្ធតែខុសទាំងអស់ ដូច្នេះឡើយ " ។ និយាយមួយបែបទៀតថា: "មនុស្សម្នាក់ៗអាចជឿអ្វីបានតាមដែលខ្លួនយល់ឃើញ ហើយអាចនិយាយបានថា ខ្ញុំជឿដូច្នេះទៅដល់ពេលណា ដែលខ្លួនរកសច្ចធម៌ឃើញ តែដោយជំនឿ (Croyance, Foi) នេះ គេមិនគប្បីសម្រេចដាច់ខាតថា អ្វីដែលខ្លួនជឿនោះជាសច្ចធម៌តែមួយ ឯធម៌ដទៃពីនេះ សុទ្ធតែខុសទាំងអស់ ដូច្នេះទេ " ។

ព្រះសម្ពុទ្ធតែងត្រាស់ទេសនាទូន្មានថា : (១)

« មនុស្សតែងដេកត្រាំនៅក្នុង ទិដ្ឋិ ថា ធម៌នេះ ប្រសើរបំផុត ហើយគោរព សាស្តានោះ ទុកជាសាស្តាវិសេសបំផុត សាស្តាដទៃពីរបស់ខ្លួន សុទ្ធតែថោកទាប ទាំងអស់ ។ ដោយហេតុនេះបានជាមនុស្សនេះតែមានវិវាទមិនចេះចប់ ។

« មនុស្សបាន ឃើញអានិសង្សក្នុងខ្លួន ចំពោះអារម្មណ៍ដែលខ្លួន

---

១- ខុទ្ទកនិកាយ សុត្តនិបាត បរមដ្ឋកសូត្រ សៀវភៅទី ៥៤ ទំព័រ ២៧៣ ។

បានឃើញ បានឮ បានពាល់ត្រូវ ឬ ចំពោះសីលព្វត ក៏ប្រកាន់ខ្ជាប់នូវអានិសង្សនោះ ទុកជា សក្កាយទិដ្ឋិ = ឃើញថាជារបស់ខ្លួនប្រសើរ ហើយទុកគ្រឿងដទៃ ៗ ថាសុទ្ធតែថោកទាបទាំងអស់ " ។

" អ្នកដែលនៅក្នុងសំណាក់គ្រូណា ហើយដេកត្រាំនៅក្នុង ទិដ្ឋិ គ្រូនោះតែងតែយល់ថា ធម៌គ្រូរបស់ខ្លួនប្រសើរបំផុត ធម៌គ្រូដទៃ ៗ សុទ្ធតែជាធម៌ថោកទាបទាំងអស់ ។ អ្នកប្រាជ្ញឈ្លាសវៃប្រដៅទុកថា: "ការជាប់ក្នុង ទិដ្ឋិ នេះ ជាប្រពក់ចងក " ។

ភិក្ខុទាំងឡាយ មិនគួរគប្បីជាប់ជំពាក់ចំពោះ ទិដ្ឋិ និងសីលព្វតនេះឡើយ " ។

មួយទៀត ព្រះសម្ពុទ្ធត្រាស់ទេសនាបដិច្ចសមុប្បាទធម៌[១] ចំពោះភិក្ខុទាំងឡាយ ។ លុះបានស្ដាប់ព្រះធម្មវិសេសទេសនា ហើយ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលព្រះសម្ពុទ្ធថា ៖

" សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គបានឃើញធម៌នោះហើយ " ។

" ភិក្ខុទាំងឡាយ ! ព្រះសម្ពុទ្ធត្រាស់បញ្ជាក់. បើអ្នកពល់គ្នាជាប់ជំពាក់ រីករាយ ក្ដប់កាន់ កប់អានចំពោះទិដ្ឋិនេះថា: បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយតណ្ហា និង ទិដ្ឋិ នោះឡើយទេ ម្ដេចឡើយអ្នកនឹង

---

១- មជ្ឈិមនិកាយ មូលបណ្ណាសក មហាតណ្ហាសង្ខយសូត្រ សៀវភៅទី២២ ទំព័រ ១៦៣ ។

បានយល់ច្បាស់នូវធម៌ដែលមានឧបមាដូចជា សំពៅគេគ្រាដែលតថា-គតសម្តែងហើយ ដើម្បីប្រយោជន៍រំខ្លួនឲ្យចាក ឱឃៈទាំង ៤ មិនមែនដើម្បីប្រយោជន៍ឲ្យប្រកាន់នូវខន្ធបញ្ចកៈនោះទេ មិនដូច្នោះឬ ។

ក្នុងពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់តែងតែត្រាស់ទេសនា ប្រៀបធៀបធម៌ព្រះអង្គថា ដូចជាសំពៅគេគ្រា សម្រាប់ដឹកឆ្លងទៅកាន់ត្រើយនាយ មិនមែនសម្រាប់ប្រកាន់ខ្ជាប់ ហើយលើសែងយកទៅតាមទេ ទ្រង់ត្រាស់ថា :

" ភិក្ខុទាំងឡាយ ? មនុស្សម្នាក់ ជាអ្នកធ្វើដំណើរ ដើរទៅដល់ត្រើយសមុទ្រត្រើយអាយ ប្រកបដោយភ័យច្រើន ត្រើយនាយជាត្រើយនិរភ័យ ប្រកបដោយក្តីក្សេមក្សាន្ត តែមិនមានអ្វីនឹងឆ្លងទៅ ៗ មនុស្សនេះគិតថា សមុទ្រនេះធំធេងណាស់ ត្រើយអាយនេះមានភ័យច្រើនណាស់ ត្រើយនាយឥតភ័យ មានតែក្តីក្សេមក្សាន្ត តែមិនមានយានឆ្លងទៅ ទូកក៏មិនមាន ! ជាការគាប់ប្រសើរណាស់ ប្រសិនបើអាត្មាអញយកស្មៅ ឈើ មែកឈើ ឬ សន្លឹកឈើ មកធ្វើជាក្បូន ហើយអាស្រ័យដោយក្បូននេះ អាត្មាអញនឹងឆ្លងទៅត្រើយនាយ ដោយប្រើដៃនិងជើងអុំទូកចែវទៅ ។

ភិក្ខុទាំងឡាយ ? មនុស្សអ្នកធ្វើដំណើរនេះ ដើររកស្មៅ ឈើ មែកឈើ សន្លឹកឈើ រកបានហើយ ធ្វើជាក្បូននេះ អាស្រ័យដោយ

ក្បូននេះគេច្នង់ទៅត្រើយខាយ ដោយប្រើដៃនិងជើងអុំទូកថែវទៅ ៗ ច្នង់ទៅដល់ត្រើយខាយហើយមានប្រស្នាមួយតទៅទៀត អ្នកធ្វើដំណើរនេះគិតថា អាត្មាអញធ្វើដូម្តេចអេះ ? ក្បូននេះ ជួនអាត្មាអញបានសម្រេចដូចបំណង ហើយអាស្រ័យដោយក្បូនជាពំនឹងនេះ អាត្មាអញបានដល់ត្រើយ ប្រកបដោយក្តីក្សេមក្សាន្ត ដើម្បីតបឧបការ: គួរតែអាត្មាអញលើកក្បូនជាពំនឹងដ៏ប្រសើរនេះដាក់លើក្បាលហើយទូល ឬ អាត្មាអញលើកក្បូននេះ ដាក់លើស្មាហើយលីយកទៅ ទើបសម ៗ

ភិក្ខុទាំងឡាយ សេចក្តីនេះ អ្នកទាំងឡាយគិតដូចម្តេច ? អ្នកដំណើរយើងនេះ ត្រូវធ្វើតាមគំនិតដែលខ្លួនគិតឃើញនេះ ឬ ទើបឈ្មោះថាធ្វើការគួរសមចំពោះក្បូននោះ ?

សូមទ្រង់ព្រះមេត្តាប្រោស ! ពុំគួរសមទេ

ព្រះសម្មុទ្រទ្រង់បន្តព្រះពុទ្ធដីកាតទៅទៀតថា :

" ភិក្ខុទាំងឡាយ ! ឥឡូវនេះ អ្នកធ្វើដំណើរយើងបានច្នង់មកដល់ត្រើយខាយដោយក្តីក្សេមក្សាន្តហើយ ឧបមាថា អ្នកធ្វើដំណើរនេះគិតថា " ក្បូននេះមានគុណបំណាច់នឹងអាត្មាអញណាស់ អាស្រ័យដោយក្បូននេះអាត្មាអញបានច្នង់មកដល់ត្រើយ ប្រកបដោយក្តីក្សេមក្សាន្តហើយគួរណាស់តែអាត្មាអញលើកក្បូននេះ ដាក់ទៅលើត្រើយ ឬចង់ទុក ឬក៏ពន្លិចបោលទៅ ហើយធ្វើដំណើរចរចេញទៅតាមក្តីប្រាថ្នា ។ ធ្វើដូច្នេះ

ទើបឈ្មោះថាអ្នកធ្វើដំណើរនេះ បេះធ្វើការគួរសមចំពោះក្បូននោះ ។

ភិក្ខុទាំងឡាយ ! ធម្មវិន័យដែលតថាគតបានសម្តែងហើយ ប្រៀបដូចក្បូនដូច្នោះដែរធម្មវិន័យនេះ គ្រាន់តែជាសំពៅកេគ្រាសម្រាប់ជិះឆ្លងតែប៉ុណ្ណោះទេ មិនមែននាំឲ្យកើតមានឧបាទាន សម្រាប់ប្រកាន់ខ្ជាប់ទេ ។

ភិក្ខុទាំងឡាយ ! បុគ្គលណាមួយយល់ឃើញធម្មវិន័យនេះ ថាទុកដូចជាសំពៅកេគ្រា បុគ្គលនោះឈ្មោះថាបានប្រតិបត្តិធម្មវិន័យ ដែលតថាគតសម្តែងហើយនេះសមគួរទៅតាមធម៌ហើយ ព្រោះបានលះបង់ធម៌ធម៌ (១) ទាំងអស់ពោលបង់អស់ហើយ ។

ដំណើរនិទាននេះ ធ្វើឲ្យយើងបានយល់ច្បាស់ថា ពុទ្ធវចនៈ មានអត្ថន័យថានាំសត្វទៅកាន់ សិវឋានសន្តិវរបទ បរមសុខ. ខេមឋាន ត្រើយត្រានអមតនិព្វានពិតប្រាកដ ។ ពុទ្ធវចនៈនេះ ជាស្វាក្ខាតធម៌ដឹកនាំសត្វទៅកាន់ទីបំផុតទុក្ខបានពិត ។ ពុទ្ធវចន. នេះ ជានិយ្យានិកធម៌ គឺជាសំពៅកេគ្រាដឹកនាំសត្វទៅកាន់ត្រើយត្រានអមតនិព្វានពិតប្រាកដ ។ ព្រះសម្ពុទ្ធទ្រង់មិនសម្តែងធម៌ទុកគ្រាន់តែសម្រាប់បញ្ឆិតសត្វលោក ឬទុកគ្រាន់តែបង្ហាញបុគ្គលបញ្ញវន្តឲ្យចង់មើលចង់ដឹងនោះទេ ។ ធម្មវិន័យព្រះអង្គ ពិតជាធម៌នាំសន្តិភាព នាំ

---

១- ក្នុងអដ្ឋកថាសូត្រនេះពន្យល់ថា កុសលធម៌ក្តី អកុសលធម៌ក្តី ព្រមទាំងឈានសមាបត្តិ ត្រូវលះបង់ពោលទាំងអស់ ព្រោះធម៌ទាំងអស់នេះ មិននាំឲ្យទៅដល់ទីបំផុតទុក្ខទេ ។

សេចក្ដីសុខ មកប្រគល់ឲ្យសត្វលោក ដែលកំពុងក្ដៅពេលពលដោយភ្លើងទុក្ខ ភ្លើងកិលេសបានយ៉ាងសក្ដិសិទ្ធិបំផុត ។ ធម្មវិន័យព្រះអង្គនេះជាទឹកអម្រឹត គួរសាធុជនក្រេបផឹកបំបាត់ក្ដីស្រេកឃ្លានបានយ៉ាងប្រសើរបំផុត ។

អ្នកមិនបានសិក្សាពុទ្ធសាសនា ដោយម៉ត់ចត់តែងនិយាយថា ពុទ្ធ-សាសនាមិនមានលក្ខណៈដោយបរិបូណ៌ទៅតាមផ្លូវលោក គឺគេចង់និយាយថា ព្រះសម្ពុទ្ធមិនចេះវិជ្ជាផ្លូវលោក សម្រាប់បង្កើតសារពើវត្ថុជាផាសុក = Confort សម្រាប់មនុស្សលោកឡើយ ។ ព្រះសម្ពុទ្ធទ្រង់ជាសព្វញ្ញុពុទ្ធ ទ្រង់មិនមានអ្វីនៅសល់ទើសទាក់នឹងព្រះបញ្ញាញាណព្រះអង្គទេ ធម៌ណាជាកុសលជាធម៌ដឹកនាំសត្វលោកទៅកាន់ សន្តិវរបទ ទ្រង់តែងតែសម្ដែងធម៌នោះអស់ថិរៈវេលា ៤៥ វស្សា ដើម្បីជាប្រយោជន៍ដល់មនុស្សលោក ទេវលោកព្រហ្មលោក ។ ធម្មវិន័យព្រះអង្គនេះជាកញ្ចក់សម្រាប់ឆ្លុះមើលអ្វីក៏បាន មើលល្អក៏បានមើលអាក្រក់ក៏បាន ស្រេចហើយតែអ្នកឆ្លុះត្រូវការ ។

សម័យមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថនៅសីសបាវន ជិតក្រុងកោសម្ពី ។ ពេលនោះ ទ្រង់ឈោងព្រះហស្តទៅចាប់សន្លឹកឈើមួយក្ដាប់មកទុកក្នុងព្រះហស្ត ហើយទ្រង់ត្រាស់សួរទៅ

កាន់ភិក្ខុទាំងឡាយថា :(១)

" ភិក្ខុទាំងឡាយ ! អ្នកទាំងឡាយយល់ឃើញដូចម្តេច ? សន្លឹកឈើមួយក្តាប់ ដែលនៅក្នុងដៃតថាគតនេះ និងសន្លឹកឈើដែលមាននៅព្ធដ៏ដើមឈើឯណោះ ឯណាច្រើនជាងឯណា ?

សូមទ្រង់ព្រះមេត្តាប្រោស ! ភិក្ខុទាំងឡាយ ទូលព្រះដីកា ហើយក្រាបទូលថា សន្លឹកឈើដែលនៅក្នុងក្តាប់ព្រះហស្តនេះ មានចំនួនតិចណាស់ ឯសន្លឹកដែលមាននៅព្ធដ៏ដើមឈើក្នុងសីសបាវ័ននេះ មានចំនួនច្រើនណាស់ និងគណនាគ្រាប់ពុំបានឡើយ ។

ភិក្ខុទាំងឡាយ ធម៌វិន័យដែលតថាគតបានត្រាស់ដឹង ហើយដែលតថាគតយកមកសម្តែងប្រាប់ដល់អ្នកទាំងឡាយ មានចំនួនតិចណាស់ ឯធម៌ដែលតថាគត បានត្រាស់ដឹងហើយមិនបានយកមកសម្តែងប្រាប់ដល់អ្នកទាំងឡាយ មានច្រើនណាស់ ដូចសន្លឹកឈើដែលមាននៅក្នុងសីសបាវ័ននេះឯង ។ ចុះហេតុអ្វី ក៏តថាគតមិនយកធម៌ទាំងអស់នោះមកសម្តែងប្រាប់អ្នកទាំងឡាយ ? ព្រោះថាធម៌ទាំងអស់នោះ មិនមានប្រយោជន៍ មិននាំសត្វលោកទៅនិព្វាន ។

(នៅមានត)

---

១- សំយុត្តនិកាយ មហាវគ្គ សីសបាវណ្ណវគ្គ សៀវភៅទី ៣៩ ទំព័រ ២៥៣ ។

# រឿងបណ្ឌិតសាមណេរ

## អដ្ឋកថាធម្មបទ បណ្ឌិតវគ្គទី ៦ ភាគទី ៤

លោក ប៊ុំ - ប៊ុយ រៀបរៀង

កាលព្រះបរមសាស្ដាគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹង បណ្ឌិត-សាមណេរ ( ឲ្យជាហេតុ ) ហើយទ្រង់សម្ដែងធម៌ដោយបទគាថាថា ឧទកំ ហិ នយន្តិ ដូច្នេះជាដើម ។

មានសេចក្ដីពិស្ដារថា = កាលកន្លងទៅជាងមួយសែនកប្បហើយ ព្រះកស្សបសម្មាសម្ពុទ្ធ មានព្រះខីណាស្រពពីរម៉ឺនអង្គជាបរិវារ បានស្ដេចយាងទៅឯនគរពារាណសី ។ មនុស្សទាំងឡាយកំណត់ដឹងកម្លាំងរបស់ខ្លួន ហើយរួបរួមគ្នា ៨ នាក់ខ្លះ ១០ នាក់ខ្លះ បានថ្វាយអាគន្តុកទាន ។

ថ្ងៃមួយ ក្នុងវេលាភត្តកិច្ច ព្រះបរមគ្រូបានទ្រង់ធ្វើអនុមោទនាយ៉ាងនេះថា ម្នាលឧបាសកនិងឧបាសិកាទាំងឡាយ! មនុស្សខ្លះក្នុងលោកនេះ គិតថា គាត់ឲ្យទ្រព្យសម្បត្តិរបស់ខ្លួនជាទាន តែម្នាក់ឯងប៉ុណ្ណោះ ក៏ល្មមសមគួរហើយ មិនបាច់ឃោសនាដឹកនាំបបួលអ្នកដទៃទេ គិតរួច ក៏ថ្វាយទានតែម្នាក់ឯង មិនឃោសនាបបួលអ្នកដទៃទៀតទេ អ្នកនោះ រមែងបានភោគសម្បត្តិតែម្យ៉ាង មិនបានបរិវារសម្បត្តិទេ ក្នុងទីដែលខ្លួនកើតហើយ,

មនុស្សខ្លះចេះតែឃោសនាបបួលអ្នកដទៃ ឯខ្លួនឯងមិនបានឲ្យទានទេ អ្នកនោះរមែងបានតែបរិវារសម្ប័ទម្យ៉ាង មិនបានភោគសម្ប័ទទេ ក្នុងទីដែលខ្លួនកើតហើយ, មនុស្សខ្លះ ខ្លួនឯងក៏មិនបានឲ្យទាន សូម្បីអ្នកដទៃក៏មិនបបួលផង អ្នកនោះរមែងមិនបានទាំងភោគសម្ប័ទ ទាំងបរិវារសម្ប័ទ ក្នុងទីដែលខ្លួនកើតហើយ ជាមនុស្សស៊ីដែលគេចិញ្ចឹមជីវិត, មនុស្សខ្លះ ខ្លួនឯងក៏ឲ្យទាន អ្នកដទៃក៏បបួល អ្នកនោះ រមែងបានទាំងភោគសម្ប័ទ ទាំងបរិវារសម្ប័ទ ក្នុងទីដែលខ្លួនកើតហើយ ។

មានបុរសជាបណ្ឌិតម្នាក់ ឈរស្តាប់ព្រះធម៌ទេសនា នៅក្នុងទីជិត គិតថា សម្បត្តិទាំងពីរយ៉ាង នឹងកើតមានដល់អញយ៉ាងណា គ្រានេះ អញនឹងធ្វើយ៉ាងនោះ ។ គាត់ក៏ថ្វាយបង្គំព្រះសាស្តា ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃព្រឹកស្អែក សូមព្រះអង្គទទួលភិក្ខា របស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់សួរថា អ្នកត្រូវការភិក្ខុចំនួនប៉ុន្មានរូប? ។ ចុះបរិវាររបស់ព្រះអង្គមានប៉ុន្មាន? ។ មានចំនួនពីរម៉ឺនរូប ។ សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃទាំងអស់ ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គក្នុងថ្ងៃព្រឹកស្អែក ។ ព្រះសាស្តាទ្រង់ទទួលនិមន្តហើយ ។ ឯបណ្ឌិតបុរស ចូលទៅក្នុងស្រុក ហើយដើរប្រកាសឃោសនាថា អម្ម តាតា អស់លោកអ្នកនាងជាបងប្អូនដូនតាម៉ែឪ! ក្នុងថ្ងៃព្រឹកស្អែកនេះ ខ្ញុំនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធានទុករួចហើយ លោកអ្នកទាំងឡាយ ចូរថ្វាយទានដល់ភិក្ខុទាំង-

ឲ្យយកតាមសេចក្ដីអាចនឹងធ្វើបាន កាលជនទាំងឡាយកំណត់ដឹងកម្លាំងរបស់ខ្លួនហើយឆ្លើយថា យើងខ្ញុំនឹងថ្វាយដល់ភិក្ខុដប់រូប ម្ភៃរូប មួយរយរូប ប្រាំរយរូប ដូច្នេះ គាត់ក៏កត់ត្រាពាក្យរបស់អ្នកទាំងអស់នោះទុកក្នុងបញ្ជី តាំងពីដើមរៀងមក ។ ក្នុងសម័យនោះ មានបុរសម្នាក់ប្រាកដឈ្មោះថា មហាទុគ្គតៈ ព្រោះមានភាពជាមនុស្សទាល់ក្រណាស់ទៅក្នុងព្រះនគរនោះ ។ បណ្ឌិតបុរស ក្រឡេកឃើញមហាទុគ្គតៈនោះដើរមកចំមុខខ្លួនក៏ប្រាប់ថា នែសម្លាញ់ មហាទុគ្គតៈ! ខ្ញុំនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃព្រឹកស្អែក, អ្នកនគរទាំងឡាយនឹងនាំគ្នាថ្វាយទាន តើអ្នកឯងនឹងទទួលប្រគេនចង្ហាន់ដល់ភិក្ខុប៉ុន្មានរូបដែរ ។ មហាទុគ្គតៈ ឆ្លើយថា លោក! ខ្ញុំមានប្រយោជន៍អ្វីដោយភិក្ខុទាំងឡាយ ពួកអ្នកដែលមានទ្រព្យ ទើបគេត្រូវការដោយភិក្ខុទាំងឡាយ, ឯខ្ញុំគ្រាន់តែអង្ករប្រមាណមួយនាឡិ ដើម្បីនឹងបបរក្នុងថ្ងៃព្រឹកស្អែក ក៏មិនទាន់មានទេ, ខ្ញុំធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិត មិនទាន់ត្រូវការដោយភិក្ខុទាំងឡាយទេ ។ ធម្មតាអ្នកដែលដឹកនាំគេ ត្រូវតែជាអ្នកឈ្លាសវៃប៉ិនប្រសប់ណាស់ ព្រោះដូច្នោះ បណ្ឌិតបុរសនោះ សូម្បីកាលមហាទុគ្គតៈ និយាយថា "គ្មានអង្ករ" ក៏នៅតែមិនឈប់ស្ងៀម, ចង្អុលពន្យល់យ៉ាងនេះ ថា សម្លាញ់ មហាទុគ្គតៈ! មនុស្សជាច្រើន ក្នុងព្រះនគរនេះ គេបរិភោគភោជនដ៏ល្អ ស្លៀកពាក់សំពត់ពាក់សាបប៉ិតខៃ

ស្អិតស្អាងខ្លួនដោយគ្រឿងអាភរណៈផ្សេងៗ ដេកលើដំណេកដ៏មានសិរី ហោយសម្បត្តិសម្បូណ៌សប្បាយ ចំណែកខ្លួនអ្នកឯងធ្វើការស៊ីឈ្នួលគេ ពេញមួយថ្ងៃ នៅតែមិនបានអាហារល្មមឆ្អែត កាលបើដូច្នេះ អ្នកឯងមិន ទាន់ដឹងខ្លួនទេឬថា អញមិនបានទ្រព្យអ្វីៗ ព្រោះមិនបានធ្វើអំពើល្អៗ ទុកមកពីកាលមុនៗ បាទ! ខ្ញុំដឹងយ៉ាងហ្នឹងដែរ លោក!ៗ បើអ្នកដឹង ហើយ ហេតុអ្វីគ្រានេះ បានជាអ្នកមិនព្រមធ្វើបុណ្យ. អ្នកនៅតែកំលោះ សម្បូណ៌ដោយកម្លាំងកាយ បើធ្វើការឈ្នួល ហើយថ្វាយទានតាមកម្លាំង ដែលរកអង្ករបាន មិនគួរឬៗ កាលបើបណ្ឌិតបុរសពន្យល់យ៉ាងច្បាស់ លាស់ដូច្នេះ មហាទុគ្គតៈ កើតសេចក្ដីស្ងួតចិត្ត ហើយឆ្លើយទូលថា លោកចូរកត់ភិក្ខុមួយរូបទុកក្នុងបញ្ជីឲ្យខ្ញុំផង ខ្ញុំនឹងធ្វើការឈ្នួលយ៉ាងណា មួយហើយ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូបៗ បណ្ឌិតបុរស មិនបាន ចុះឈ្មោះគាត់ទុកក្នុងបញ្ជីផងទេ ដោយគិតថា ចាំបាច់អ្វី ដោយភិក្ខុមួយ រូប ដែលអញត្រូវចុះទុកក្នុងបញ្ជីៗ មហាទុគ្គតៈ ទៅដល់ផ្ទះហើយ ប្រាប់ភរិយាថា នាងដ៏ចម្រើន! ក្នុងថ្ងៃព្រឹកស្អែក អ្នកនគរគេនាំគ្នាធ្វើភត្ត ថ្វាយដល់ព្រះសង្ឃ, ឯអ្នកដឹកនាំគេប្រាប់បងថា អ្នកចូរទទួលប្រគេនចង្ហាន់ ដល់ភិក្ខុមួយរូប ចុះ, ក្នុងថ្ងៃព្រឹកស្អែក យើងទាំងពីរនាក់នឹងប្រគេនចង្ហាន់ ដល់ភិក្ខុមួយរូបៗ លំដាប់នោះ ភរិយារបស់គេ មិននិយាយថា យើងទាំង ពីរនាក់ជាមនុស្សទាល់ក្រណាស់ ហេតុអ្វីបានជាអ្នកហ៊ានទទួលព្រមតាម

ពាក្យគេដូច្នេះទេ តែជានិយាយថា បង! អ្នកធ្វើអំពើល្អហើយ ដ្បិតពីកាលមុន ៗ យើងទាំងពីរនាក់មិនបានថ្វាយទានអ្វីទុកមកសោះ បានជាដល់មកជាតិនេះកើតជាអ្នកកម្សត់ទុគ៌តដល់ម្លឹង យើងទាំងពីរនាក់ធ្វើការឈ្នួលហើយ ទើបប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប, និយាយព្រមព្រៀងគ្នារួចទាំងពីរនាក់បានចេញទៅរកទីកន្លែងអ្នកជួល ៗ លោកមហាសេដ្ឋីបានឃើញមហាទុគ្គតៈ មកដល់ហើយសួរថា សម្លាញ់ មហាទុគ្គតៈ! អ្នកមកនឹងធ្វើការឈ្នួលឬ ? ៗ បាទ! ខ្ញុំបាទនឹងធ្វើ ៗ អ្នកនឹងទទួលធ្វើការយ៉ាងណា ? ៗ បើលោកឲ្យខ្ញុំបាទធ្វើការយ៉ាងណា ខ្ញុំបាទនឹងធ្វើការយ៉ាងនោះ ៗ បើដូច្នោះ ក្នុងថ្ងៃព្រឹកស្អែកនេះ យើងនឹងប្រគេនចង្ហាន់ព្រះភិក្ខុសង្ឃពាន់បីរយរូប អ្នកចូរមក ចូរទៅពុះឧសចុះ, ប្រាប់រួចយកកាំបិតនឹងពូថៅមកប្រគល់ឲ្យ ៗ មហាទុគ្គតៈ ក៏ក្រវាត់ខ្លួនយ៉ាងណែនហើយ មានសេចក្ដីឧស្សាហ៍ប្រឹងប្រែងណាស់ ពោលកាំបិតចាប់ពូ-ថៅ ពោលពូថៅចាប់កាំបិត ទំពុះឧសឥតឈប់ ៗ លំដាប់នោះ លោកសេដ្ឋីសួរបុរសនោះថា សម្លាញ់! ថ្ងៃនេះ អ្នកឯងខំប្រឹងធ្វើការលើសពីធម្មតា តើមានហេតុអ្វីអេះ ? លោកម្ចាស់! ខ្ញុំបាទនឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ៗ លោកសេដ្ឋីស្ដាប់ពាក្យរបស់បុរសហើយ មានចិត្តជ្រះថ្លាគិតថា បុរសនេះ ធ្វើអំពើជាការក្រដែលបុគ្គលធ្វើបាន, គេមិនព្រមជាអ្នកនៅស្ងៀម [illegible] ទេ នៅតែនិយាយថា ខ្ញុំធ្វើការ

ឈ្នួលបានអង្ករហើយ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូបដែរ ។ ចំណែក
ភរិយារបស់សេដ្ឋី ឃើញភរិយារបស់មហាទុគ្គតៈ ហើយសួរថា នាង
នឹងធ្វើការយ៉ាងណា ? ។ បើលោកស្រីឲ្យខ្ញុំធ្វើការយ៉ាងណា ខ្ញុំនឹងយ៉ាង
នោះ ។ ភរិយាសេដ្ឋីប្រាប់ឲ្យនាងនោះចូលទៅឯពេងត្បាល់បុកស្រូវ ប្រាប់
ស្រីបម្រើឲ្យយកគ្រឿងប្រើប្រាស់ មានចង្អេរនិងអង្រែជាដើម ប្រគល់ឲ្យ
ភរិយាបុរសកម្សត់ ។ នាងសប្បាយចិត្តណាស់ ធ្វើការហាក់ដូចជាច្រៀង
រាំ បុកស្រូវផង អុំអង្ករផង ។ លំដាប់នោះ លោកស្រីភរិយារបស់សេដ្ឋី
សួរនាងថា នែនាង! នាងត្រេកអរកាយសប្បាយចិត្តណាស់នឹងធ្វើការ
ងារ ចុះមានហេតុអ្វី? ។ ខ្ញុំទាំងពីរនាក់ប្តីប្រពន្ធ ធ្វើការឈ្នួលនេះរួច
ហើយ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ។ ភរិយាសេដ្ឋី ឮពាក្យនាង
ហើយជ្រះថ្លានឹងនាងថា ស្រីនេះធ្វើអំពើជាកម្រដែលបុគ្គលនឹងធ្វើបាន ។
នៅវេលាដែលមហាទុគ្គតៈ ពុះឧសរួចស្រេចហើយ លោកសេដ្ឋីក៏
ឲ្យអង្ករស្រូវសាលីបួននាឡិ ប្រាប់ថា នេះ ជាថ្លៃឈ្នួលរបស់អ្នក ហើយ
ឲ្យអង្ករស្រូវសាលីបួននាឡិទៀត ប្រាប់ថា នេះ ជារង្វាន់របស់អ្នក ។
បុរសនោះទៅដល់ផ្ទះហើយប្រាប់ភរិយាថា បងធ្វើការឈ្នួលបានស្រូវសា-
លីហើយ ស្រូវសាលីនេះនឹងធ្វើជាអាហារ នាងចូរទិញយកទធិនិងប្រេង
និងគ្រឿងហឹរទាំងឡាយ ដោយថ្លៃឈ្នួលដែលនាងបានហើយ គឺថា ប្តី
ប្រាប់ប្រពន្ធឲ្យយកថ្លៃឈ្នួលដែលប្រពន្ធបាននោះ ទៅទិញទធិជាដើម ។

ចំណែកកិរិយារបស់សេដ្ឋី ឲ្យសប្បិមួយដបទធិមួយចាន គ្រឿងហឹរមួយមុខទៀត អង្ករនៃស្រូវសាលីសបរិសុទ្ធមួយនាឡិ ដល់កិរិយារបស់មហាទុគ្គតៈ នោះ ៗ ប្តីប្រពន្ធទាំងពីរនាក់ បានអង្កររួមគ្នាជាប្រាំនាឡិ ដោយប្រការដូច្នេះ ៗ ប្តីប្រពន្ធទាំងពីរនាក់ សប្បាយចិត្តណាស់ដោយគិតថា យើងទាំងពីរនាក់បានទេយ្យធម៌ហើយ(១) ក៏ក្រោកឡើងអំពីព្រហាម ៗ នាងកិរិយានិយាយ នឹងមហាទុគ្គតៈ ជាប្តីថា អ្នកចូរទៅរកបន្លែមក ៗ មហាទុគ្គតៈ ទៅរកទិញបន្លែក្នុងផ្សារមិនឃើញមាន ទើបដើរទៅច្នៃស្ទឹង មានចិត្តរីកកាយ ដោយគិតថា អញនឹងបានថ្វាយភោជនដល់លោកម្ចាស់ទាំងឡាយ ហើយក៏ស្រែកច្រៀងជាភ្លេងបេះបន្លែ ៗ ឯនាយព្រានឈរបង់សំណាញ់ឮថា ប្រហែលជាសំឡេងរបស់ មហាទុគ្គតៈ ទើបស្រែកសួរថា អ្នកឯងមានចិត្តរីកកាយខ្លាំងណាស់ ស្រែកច្រៀងជាភ្លេង តើមានហេតុអ្វី? ៗ ខ្ញុំបេះបន្លែសម្លាញ់! ៗ អ្នកនឹងយកបន្លែទៅធ្វើអ្វី ? ៗ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ៗ ភិក្ខុរូបណាឆាន់បន្លែ.របស់អ្នកឯង ភិក្ខុរូបនោះមានចិត្តសប្បាយណាស់ ៗ ខ្ញុំមិនធ្វើដូចម្តេចបាន សម្លាញ់! មានតែនឹងប្រគេនលោកឆាន់ដោយបន្លែដែលខ្ញុំបានទេហើយ ៗ បើដូច្នោះ អ្នកចូរមកណេះសិន ៗ នឹងឲ្យខ្ញុំទៅធ្វើអ្វីសម្លាញ់ ? ៗ អ្នកចូរដោតត្រីទាំងនេះឲ្យជាត្រណោត មួយត្រណោត

---

១- វត្ថុដែលសម្រាប់បរិច្ចាគ ។

ថ្ងៃមួយកាក់ខ្លះ មួយត្រណោត ថ្ងៃប្រាំសេនខ្លះ ថ្ងៃមួយរៀលខ្លះ ។ មហាទុគ្គតៈ បានផ្ញើតាមបន្ទាប់នាយព្រានសំណាញ់ ។ អ្នកនគរទាំងឡាយវិញយកត្រណោតត្រីដែល មហាទុគ្គតៈ ដោតទុកស្រេចនោះទៅ ដើម្បីប្រយោជន៍ដល់ភិក្ខុដែលខ្លួនបាននិមន្តហើយៗ ។ កាលមហាទុគ្គតៈ កំពុងតែដោតត្រណោតត្រី ក៏ដល់ពេលភិក្ខាចារ កំណត់ពេលបានហើយនិយាយថា ខ្ញុំនឹងទៅផ្ទះហើយសម្លាញ់ ! ដ្បិតវេលានេះជាពេលភិក្ខុទាំងឡាយនិមន្តមក ៖ នាយព្រានសួរថា ចុះត្រីត្រណោតអ្វីៗមាននៅសល់ខ្លះដែរឬទេ ។ មហាទុគ្គតៈ ឆ្លើយថា គ្មានទេសម្លាញ់ ! អស់រលីងទៅហើយ ។ នាយព្រានប្រាប់ថា បើដូច្នោះ ត្រីពិនស្រស់បួន យើងកប់ទុកក្នុងដីខ្សាច់ដើម្បីប្រយោជន៍ខ្លួន បើអ្នកប្រាថ្នានឹងប្រគេនភិក្ខុឆាន់ ចូរយកត្រីពិនស្រស់ទាំងបួននេះទៅចុះ ថារួចក៏ឲ្យត្រីទាំងនោះទៅមហាទុគ្គតៈ ។

ក្នុងវេលាបច្ចុសសម័យថ្ងៃនោះ ព្រះបរមសាស្តាទ្រង់ពិចារណាមើលសត្វ ឃើញមហាទុគ្គតៈ ចូលទៅក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទើបទ្រង់រំពឹងមើលថា ហេតុអ្វីហ្ន៎ ! ទ្រង់ព្រះតម្រិះឃើញថា មហាទុគ្គតៈ ព្រមទាំងភរិយា គិតគ្នាថា នឹងប្រគេនបង្អាន់ដល់ភិក្ខុមួយរូប បានធ្វើការឈ្នួលពីថ្ងៃម្សិលមិញ គាត់នឹងបានភិក្ខុរូបណាអេះ ? ទើបទ្រង់ពិនិត្យមើលតទៅទៀតថា មនុស្សទាំងឡាយ នឹង

កាន់យកភិក្ខុ តាមសញ្ញាដែលគេកត់ទុកក្នុងបញ្ជី នឹងឲ្យនិមន្តយាងទៅក្នុងផ្ទះ របស់ខ្លួន ៗ, ឯមហាទុគ្គតៈ ក្រៅពីតថាគត មុខជាមិនបានភិក្ខុរូបណាផ្សេងទៀតទេ ។

បានឮថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងទ្រង់ធ្វើការអនុគ្រោះ ចំពោះមនុស្សកម្សត់ទុគ៌តទាំងឡាយ ។ ព្រោះដូច្នេះ ព្រះបរមសាស្ដា ទ្រង់ធ្វើសរីរកិច្ចអំពីព្រហាម ទ្រង់មានព្រះតម្រិះថា នឹងសង្គ្រោះមហាទុគ្គតៈ ដូច្នេះ ហើយស្ដេចចូលទៅកាន់ព្រះគន្ធកុដីគង់នៅ ។ កាលមហាទុគ្គតៈ យូរត្រីដើរទៅដល់ផ្ទះខ្លួន បណ្ឌុកម្ពលសិលាសនៈ របស់ព្រះឥន្ទ ក៏សម្ដែងនូវអាការក្ដៅ ។ ព្រះឥន្ទទ្រង់ពិចារណាថា មានហេតុអ្វីបម្លែកអេះ ? ទ្រង់ឃើញថា ពីថ្ងៃម្សិលមិញ មហាទុគ្គតៈ ព្រមទាំងភរិយារបស់ខ្លួនគិតថា នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប បានធ្វើការឈ្នួល តើគាត់នឹងបានភិក្ខុរូបណាហ្ន៎ ? ទ្រង់ព្រះចិន្ដាតទៅទៀតថា ភិក្ខុរូបដទៃពុំមានដល់គាត់ទេ, មានតែព្រះសាស្ដាគង់នៅក្នុងព្រះគន្ធកុដីសម្រេចព្រះឥរិយាបថ ដែលតាំងព្រះហឫទ័យថា នឹងធ្វើការសង្គ្រោះដល់មហាទុគ្គតៈ ។ គប្បីថ្វាយបបរនឹងភត្តជាមួយនឹងសម្លសម្រេចហើយ [illegible]ការសបតែដល់ខ្លួនចំពោះព្រះតថាគត ដូច្នេះ អញត្រូវតែទៅផ្ទះរបស់មហាទុគ្គតៈ ហើយក្លែងខ្លួនធ្វើជាអ្នកគ្រួ គឺអ្នកដាំស្ល, ទើបធ្វើឲ្យគេមិនស្គាល់ ស្ដេចទៅដល់ជិតផ្ទះរបស់គាត់ ហើយត្រាស់

សួរថា កិច្ចការអ្វី ៗ របស់អ្នកណា ដែលត្រូវការជួលគេធ្វើ មានដែរឬទេ? មហាទុគ្គតៈ ឃើញតាឥន្ទហើយនិយាយថា សំឡាញ់ទីនធ្វើអ្វី? ៗ ខ្ញុំនេះចំណេះគ្រប់យ៉ាង, ឈ្មោះថាចំណេះដែលខ្ញុំពុំចេះដឹងនោះគ្មានទេ, ខ្ញុំស្ទាត់ជំនាញខាងតុបតែងនូវបាយបបរនិងកគ្គជាដើម ៗ យើងខ្ញុំត្រូវការដោយកិច្ចការរបស់អ្នក ប៉ុន្តែ ពុំមានថ្លៃឈ្នួល ដែលទិញគប្បីឱ្យដល់អ្នកទេ ៗ ចុះកិច្ចការអ្វីទៅដែលអ្នកត្រូវធ្វើ? ៗ ខ្ញុំប្រាថ្នាទិញប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ចាំឱ្យអ្នកចាត់ចែងបាយនិងកគ្គ ៗ បើអ្នកចាត់ចែងប្រគេនចង្ហាន់ដល់ភិក្ខុ ខ្ញុំមិនត្រូវការយកថ្លៃឈ្នួលទេ សូមតែអ្នកឲ្យចំណែកបុណ្យឱ្យខ្ញុំ បានដែរឬទេ ៗ កាលបើដូច្នោះ ប្រពៃណាស់ហើយសំឡាញ់! អ្នកចូរមកចុះ ៗ តាឥន្ទ ក៏ចូលទៅក្នុងផ្ទះរបស់គាត់ ហើយឱ្យយកអង្ករជាដើមមកឱ្យ រួចឱ្យ មហាទុគ្គតៈ ទៅ, ប្រាប់ថា អ្នកចូរទៅនាំយកភិក្ខុ ដែលត្រូវបានដល់ខ្លួនមក ៗ ចំណែកបុរសអ្នកខ្វល់ខ្វាយក្នុងទាន បញ្ជូនភិក្ខុទាំងឡាយទៅផ្ទះរបស់ជននោះ ៗ តាមកំណត់ដែលខ្លួនកត់ទុកក្នុងបញ្ជីនោះអស់ ៗ មហាទុគ្គតៈ ចូលទៅដល់បុរសនោះ ហើយនិយាយការថា អ្នកចូរឱ្យភិក្ខុមកខ្ញុំ ៗ ក្នុងខណៈនោះអ្នកកាន់បញ្ជីស្រាប់តែភ្ញាក់ខ្លួនព្រើត និយាយថា ខ្ញុំភ្លេចភិក្ខុរបស់អ្នកទៅហើយ ៗ មហាទុគ្គតៈ ហាក់ដូចជាគេយកលំពែងដ៏មុតមកចាក់ត្រង់ទ្រូង ផ្គងដើមដៃឡើងស្រែកយំនិយាយថា សំឡាញ់! ហេតុដូចម្តេច

បានជាអ្នកធ្វើឲ្យខ្ញុំវិនាស, អ្នកបបួលខ្ញុំពីថ្ងៃម្សិលមុិញ, ខ្ញុំព្រមទាំងភរិយា ធ្វើការឈ្នួលពីព្រលឹមដល់ព្រលប់ ពីព្រឹកមិញនេះ ខ្ញុំស្ទុះស្ទុងទៅគេបេះបន្លែនៅផ្ទះស្ទឹងបានមកហើយ, អ្នកបូឲ្យភិក្ខុមួយរូបកុំខាន ។ មនុស្សទាំងឡាយមកប្រជុំគ្នាមើល សួរថា មានរឿងអ្វីមហាទុគ្គតៈ ។ ប្រាប់សេចក្តីនោះសព្វគ្រប់ ។ មនុស្សទាំងនោះសួរអ្នកកាន់បញ្ជីថា បានឮថាសំឡាញ់ឯង បបួលដឹកនាំមហាទុគ្គតៈ នេះថា អ្នកបូធ្វើការឈ្នួលហើយប្រគេនបង្ហាន់ដល់ភិក្ខុមួយរូប មែនឬទេ? - បាទ! មែនហើយ ។ កាលអ្នកចាត់ភិក្ខុដល់ត្រឹមនេះ មិនឲ្យភិក្ខុមួយរូបដល់មហាទុគ្គតនេះ ជាកម្មអាក្រក់ណាស់ ។ អ្នកកាន់បញ្ជីអៀនខ្មាសនឹងសំដីរបស់អ្នកទាំងនោះ ទើបនិយាយនឹង មហាទុគ្គតៈ ថា សំឡាញ់មហាទុគ្គតៈ អ្នកកុំធ្វើខ្ញុំឲ្យវិនាសឡើយ ខ្ញុំត្រូវជំទៀលគេជាច្រើន ព្រោះហេតុតែអ្នក ឥឡូវមនុស្សទាំងឡាយ នាំយកភិក្ខុដែលខ្លួនត្រូវបាន ៗ តាមកំណត់ដែលខ្ញុំកត់ទុកក្នុងបញ្ជីអស់ទៅហើយ, ឈ្មោះថាអ្នកដែលនឹងបាននាំយកភិក្ខុគង់ក្នុងផ្ទះរបស់ខ្លួនរួចហើយ ទៅឲ្យអ្នកឯង នេះមិនដែលមានទំនៀមទេ, ឯព្រះសាស្តាស្រង់ព្រះកាយស្រេចហើយគង់ក្នុងព្រះគន្ធកុដិ, ចំណែកព្រះរាជា ព្រះយុវ-រាជនិងសេនាបតីជាដើម នាំគ្នាអង្គុយចាំព្រះសាស្តាស្រេចចេញពីព្រះគន្ធ-កុដិដោយគំនិតថា នឹងទទួលបាត្ររបស់ព្រះសាស្តាយកទៅ, ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយតែងទ្រង់ធ្វើសេចក្តីអនុគ្រោះចំពោះមនុស្សទាល់ក្រ,

ចូរអ្នកទៅឯវិហារ ហើយទូលព្រះសាស្តាថា ខ្ញុំព្រះអង្គជាមនុស្សកម្សត់ទុគ៌តណាស់ ព្រះអង្គ ! សូមព្រះអង្គ ធ្វើការសង្គ្រោះដល់ខ្ញុំព្រះអង្គដូច្នេះ បើបុណ្យរបស់អ្នកមាន អ្នកនឹងបានជាប្រាកដ ។ មហាទុគ្គតៈក៏ប្រញាប់ទៅឯវិហារ ។ លំដាប់នោះ ព្រះរាជានិងព្រះយុវរាជជាដើមនិយាយហាមឃាត់ មហាទុគ្គតៈ ថា នែ មហាទុគ្គតៈ ! វេលានេះ មិនមែនជាកាលធ្វើភត្តទេ អ្នកមកធ្វើអ្វីដូច្នេះ? ព្រោះខ្លួនធ្លាប់ឃើញ មហាទុគ្គតៈ ពីថ្ងៃមុនៗ ជាអ្នកសុំបាយសល់ដែលសេសសល់ក្នុងវិហារ ។ មហាទុគ្គតៈឆ្លើយថា លោកម្ចាស់ ! ខ្ញុំដឹងហើយថា វេលានេះមិនមែនជាកាលរបស់ភត្តទេ គឺមិនទាន់ដល់ពេលឆាន់ចង្ហាន់ទេ ក៏ប៉ុន្តែខ្ញុំមកដើម្បីថ្វាយបង្គំព្រះសាស្តា ថារួច ក៏ចូលទៅក្រាបក្បាលត្រង់ធរណីទ្វារព្រះគន្ធកុដិ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន! ក្នុងព្រះនគរនេះ មនុស្សដែលទាល់ក្រលំបាកជាងខ្ញុំព្រះអង្គ គ្មានទេ, សូមព្រះអង្គជាទីពឹងរបស់ខ្ញុំព្រះអង្គ សូមទ្រង់សង្គ្រោះដល់ខ្ញុំព្រះអង្គផង ។ ព្រះបរមសាស្តាបើកទ្វារព្រះគន្ធកុដិ យកបាត្រមកដាក់លើដៃរបស់មហាទុគ្គតៈ ។ មហាទុគ្គតៈ សប្បាយចិត្តយ៉ាងក្រៃលែង ដូចបានសិរី គឺភាពជាស្តេចចក្រពត្តិ ព្រះរាជានិងព្រះយុវរាជជាដើម ងាកសម្លឹងមើលមុខគ្នាទៅវិញទៅមក ។ ពុំមាននរណាមួយអាចទឹងហ៊ានដណ្តើមយកបាត្រ ដែលព្រះសាស្តាប្រទានដល់មហាទុគ្គតៈ

ដោយអាងអំណាចខ្លួនជាធំបានទេ ។ ឯជនទាំងឡាយ ក៏និយាយអង្វរ មហាទុគ្គតៈ ថា សំឡាញ់ មហាទុគ្គតៈ ! អ្នកប្ដូរឲ្យបាត្ររបស់ព្រះសាស្ដាមកយើង យើងនឹងឲ្យប្រាក់មួយពាន់រៀល ឬមួយសែនរៀលទៅអ្នក, អ្នកឯង ជាមនុស្សទាល់ក្រណាស់ យកប្រាក់ទៅចុះ, អ្នកឯងឥតបានប្រយោជន៍អ្វីអំពីបាត្រនេះទេ ។ មហាទុគ្គតឆ្លើយថា ខ្ញុំមិនព្រមឲ្យបាត្រទៅអ្នកណាទេ, ខ្ញុំមិនចង់បានប្រាក់, ខ្ញុំមិនត្រូវការនឹងប្រាក់កាសទេ នឹងនិមន្ដព្រះសាស្ដាឲ្យសោយតែប៉ុណ្ណោះ ។ អ្នកឯទៀត ៗ អង្វរសូមយកបាត្រពីមហាទុគ្គត មិនបានសោះ ។ ចំណែកព្រះរាជាទ្រង់ព្រះតម្រិះថា សូម្បីអញនិយាយលួងលោមឲ្យប្រាក់កាសគេ ក៏នៅតែមិនព្រមឲ្យបាត្ររបស់ព្រះសាស្ដា ម្យ៉ាងទៀត អ្នកណា ៗ ក៏មិនអាចដណ្ដើមបាត្រ ដែលព្រះសាស្ដាប្រទានឲ្យដោយព្រះអង្គឯងដែរ ឈ្មោះថាទេយ្យធម៌របស់គេនឹងល្អវិសេសត្រឹមណា, គង់វេលាដែលគេថ្វាយទេយ្យធម៌រួច អញនឹងនាំព្រះសាស្ដាទៅដំណាក់ ហើយនឹងថ្វាយអាហារ ដែលគេតាក់តែងទុកបម្រុងឲ្យអញ, ទ្រង់ព្រះតម្រិះដូច្នេះហើយ បានស្ដេចតាមព្រះសាស្ដាទៅ ។ ឯព្រះទេវរាជ ចាត់ចែងបវរភត្តនិងបន្លែជាដើមស្រេចហើយ ក៏ក្រាលអាសនៈដ៏សមគួរជាទីគង់របស់ព្រះសាស្ដា ។ មហាទុគ្គតៈនាំព្រះសាស្ដាទៅដល់ផ្ទះហើយក្រាបទូលថា សូមអញ្ជើញព្រះអង្គស្ដេចចូលទៅ ។ ឯគេហស្ថានទីលំនៅរបស់មហាទុគ្គតៈនោះ ទាបពេក បុគ្គលមិន

ឱនចុះហើយ មិនអាចចូលទៅបានឡើយ ។ មែនពិត ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយ កាលស្ដេចចូលទៅក្នុងផ្ទះ មិនទ្រង់ឱនចូលទៅទេ គឺក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ស្ដេចចូលទៅក្នុងផ្ទះ មហាប្រឹថពីស្រុតចុះក្រោម ឯផ្ទះអណ្ដែតខ្ពស់ឡើងទៅលើ ។ រឿងនេះ ជាផលរបស់ទានដែលព្រះពុទ្ធជាម្ចាស់ទាំងឡាយថ្វាយល្អហើយ ។ ឯក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ស្ដេចត្រឡប់ទៅវិញ ទីទាំងពួងជាស្ថានតាំងនៅដោយប្រក្រតីតាមដើម ។ ព្រោះហេតុនោះ ព្រះសាស្ដាឈរហើយស្ដេចចូលទៅក្នុងផ្ទះ គង់លើអាសនៈដែលព្រះឥន្ទតាក់តែងថ្វាយ ។ កាលព្រះសាស្ដាគង់ហើយ ព្រះរាជាត្រាស់សួរថា សម្លាញ់ មហាទុគ្គតៈ ! សូម្បីកាលយើងអង្វរសុំ អ្នកក៏មិនព្រមឲ្យបាត្ររបស់ព្រះសាស្ដាសោះ យើងនឹងសូមមើលឲ្យឃើញសិន តើសក្ការៈដែលអ្នកធ្វើថ្វាយចំពោះព្រះសាស្ដានោះដូចម្ដេចទៅ ។ លំដាប់នោះ ព្រះឥន្ទបើកបបរនិងភត្តជាដើមបង្ហាញឲ្យស្ដេចទត ។ ក្លិនគ្រឿងអប់របស់អាហារទាំងនោះ បានបក់ផ្សាយទូទៅពេញព្រះនគរ ។ ព្រះរាជា ទតឃើញបបរនិងភត្តជាដើម ហើយទូលព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ! ខ្ញុំមកគិតថា ទេយ្យធម៌របស់មហាទុគ្គតៈ នឹងល្អត្រឹមណា កាលគាត់ថ្វាយទេយ្យធម៌រួចហើយ នឹងនាំព្រះអង្គទៅកាន់ព្រះដំណាក់ ហើយនឹងថ្វាយអាហារដែលគេតាក់តែងទុកបម្រុងខ្លួន ដូច្នេះ បានជាតាមព្រះអង្គមក, អាហារ

បែបនេះ ខ្ញុំព្រះអង្គមិនដែលបានឃើញសោះឡើយ, កាលបើខ្ញុំព្រះអង្គនៅក្នុងទីនេះ មហាទុគ្គតៈគប្បីលំបាក, ខ្ញុំព្រះអង្គនឹងទូលលា ដូច្នេះហើយ ស្តេចថ្វាយបង្គំព្រះសាស្តាចៀសចេញទៅ ។ ឯព្រះឥន្ទថ្វាយបបរជាដើម អង្គាសព្រះសាស្តាដោយគោរព ។ ព្រះសាស្តាធ្វើភត្តកិច្ចស្រេចហើយ ធ្វើអនុមោទនា រួចស្តេចក្រោកចាកអាសនៈស្តេចចេញទៅ ។ ព្រះឥន្ទ បានឲ្យសញ្ញាដល់ មហាទុគ្គតៈ ។ ក៏ទទួលបាត្រជូនដំណើរព្រះសាស្តាទៅ ។ ព្រះឥន្ទស្តេចត្រឡប់មកឈរ ត្រង់ទ្វារផ្ទះរបស់មហាទុគ្គតៈ ទតមើលអាកាស ។ ភ្លៀងជាវិការនៃរតនៈ៧ យ៉ាង ធ្លាក់មកពីអាកាស ញុំាងភាជនៈទាំងអស់ក្នុងផ្ទះរបស់មហាទុគ្គតៈឲ្យពេញ រួចញុំាងផ្ទះទាំងមូលឲ្យពេញទៀត ។ ក្នុងផ្ទះមហាទុគ្គតៈ គ្មានចន្លោះភល់ទំនេរឡើយ ភរិយារបស់មហាទុគ្គតៈ ដឹកដៃទារកចេញមកឈរនៅខាងក្រៅ ។ មហាទុគ្គតៈជូនដំណើរព្រះសាស្តាទៅហើយវិលមកដល់ផ្ទះវិញ ឃើញក្មេងឈរនៅខាងក្រៅសួរថា មានរឿងអ្វី ? ។ ភរិយាប្រាប់ថា បង ! ផ្ទះយើងទាំងមូល ពេញទៅដោយកែវ ៧ ប្រការ គ្មានភលចន្លោះ ដើម្បីនឹងដើរចូលទៅទេ ។ មហាទុគ្គតៈ គិតថា ទានដែលអញថ្វាយហើយ ឲ្យផលក្នុងថ្ងៃនេះឯង (ឃើញទាន់ភ្នែក) គិតរួចក៏ទៅគាល់ព្រះរាជាថ្វាយបង្គំ, កាលព្រះអង្គត្រាស់សួរថា មកមានការធុរៈអ្វី ? ក៏ទូលថា បពិត្រព្រះអង្គ ! ផ្ទះខ្ញុំព្រះអង្គ ពេញទៅដោយកែវ ៧ ប្រការ សូមព្រះ

អង្គយកទ្រព្យនោះចុះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឯធានដែលបុរសនេះថ្វាយចំពោះព្រះពុទ្ធជាម្ចាស់ ដល់នូវទីបំផុត ក្នុងថ្ងៃនេះឯង, ហើយត្រាស់ថា បានឮហើយកទើបល្មម ។ សូមព្រះអង្គព្រះរាជទានរទេះមួយពាន់ ដើម្បីដឹកយកទ្រព្យមក ។ ព្រះរាជាទ្រង់បញ្ជូនរទេះទៅឲ្យមួយពាន់ បង្គាប់ឲ្យដឹកនាំទ្រព្យមកគរទុកក្នុងព្រះលានហ្លួង បានជាគំនរប្រមាណមួយដើមត្នោត ។ ព្រះរាជាបង្គាប់ឲ្យហៅអ្នកនគរមកប្រជុំគ្នា ហើយត្រាស់សួរថា ក្នុងព្រះនគរនេះ អ្នកណាមានទ្រព្យប្រមាណប៉ុណ្ណេះដែរឬ ? អ្នកនគរទូលថា គ្មានទេព្រះអង្គ! ។ ធ្វើអ្វីឲ្យគេដែលជាអ្នកមានទ្រព្យប្រមាណប៉ុណ្ណេះ ទើបសមគួរ ។ តាំងឲ្យគេធ្វើជាសេដ្ឋីទើបសមគួរ ព្រះអង្គ! ។ ព្រះរាជាទ្រង់ធ្វើសក្ការៈយ៉ាងធំ ដល់មហាទុគ្គតៈ ហើយព្រះរាជ-ទានតំណែងសេដ្ឋី ។ លំដាប់នោះ ព្រះរាជាត្រាស់ព្រះរាជទានភូមិស្ថានទីសង់ផ្ទះរបស់សេដ្ឋីក្នុងកាលមុនមក ដល់សេដ្ឋីថ្មីនោះ ត្រាស់ថា អ្នកចូរឲ្យមនុស្សកាប់គាស់យកគុម្ពឈើដែលកើតក្នុងទីនោះចេញទៅ ហើយសង់ផ្ទះទៅចុះ ។ កាលជនទាំងឡាយជម្រះស្ថានទីនោះ ដើម្បីឲ្យសេដ្ឋីនោះ ក្រោះពាក្រាបផ្ទៃដីឲ្យស្មើ កំណប់ទ្រព្យទាំងឡាយ ផុសឡើងមល់គ្នានឹងគ្នា (ជះឡើត) ។ កាលសេដ្ឋីនោះក្រាបទូលចំពោះព្រះរាជាហើយ ព្រះអង្គត្រាស់ថា ទ្រព្យនេះ កើតដោយបុណ្យរបស់អ្នកម្នាក់ឯង អ្នកចូរយកតែម្នាក់ឯងចុះ ។ សេដ្ឋីនោះ ធ្វើផ្ទះស្រេចហើយ បានថ្វាយ

មហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធានអស់ ៧ ថ្ងៃ ។ តពីនោះមក សេដ្ឋីនោះតាំងនៅដរាបដល់អស់អាយុ ធ្វើបុណ្យទាំងឡាយ ក្នុងវេលាអស់អាយុ ក៏ទៅកើតក្នុងទេវលោក សោយសម្បត្តិទិព្វអស់មួយពុទ្ធន្តរ ក្នុងកាលនៃព្រះពុទ្ធជាម្ចាស់នេះ ច្យុតចាកអត្តភាពនោះហើយមកចាប់បដិសន្ធិ ក្នុងផ្ទៃរបស់ធីតាអ្នកធំ ក្នុងត្រកូលឧបដ្ឋាក របស់ព្រះសារីបុត្តត្ថេរ ក្នុងនគរសាវត្ថី ។

លំដាប់នោះ មាតាបិតា របស់នាង ដឹងថា នាងមានគភ៌ហើយ បានឲ្យថ្នាំជាគ្រឿងរក្សាគភ៌ ។ លុះសម័យដទៃទៀត នាងកើតជម្ងឺចាញ់ផ្ទៃមានចំណង់យ៉ាងនេះថា ធ្វើម្តេចហ្ន៎ អញគប្បីបានថ្វាយទានដោយរសត្រីក្រហម ដល់ភិក្ខុប្រាំរយរូបមានព្រះធម្មសេនាបតីជាដើម, គប្បីបានស្លៀកដណ្តប់សំពត់ដែលប្រឡាក់ដោយទឹកអម្ពត អង្គុយក្នុងទីបំផុតនៃអាសនៈ ហើយបរិភោគភត្តជាសំណល់នៃភិក្ខុទាំងនោះ ។ នាងប្រាប់ចំណង់ដល់មាតាបិតា ហើយក៏បានធ្វើដូច្នោះ ។ ជម្ងឺចាញ់ផ្ទៃ គឺចំណង់នោះក៏បាត់ទៅ ។ ចំណេរតមក ស្ងួនក្នុងមង្គលទាំង ៧ របស់នាងខាងមុខអំពីកាលនោះ ក៏ញាតិទាំងឡាយនិមន្តភិក្ខុប្រាំរយរូបមានព្រះធម្មសេនាបតីជាប្រធាន ឲ្យឆាន់ដោយរសត្រីក្រហមដូចគ្នា ។ គប្បីជ្រាបរឿងរ៉ាវទាំងអស់ដោយន័យដូចពោលហើយ ក្នុងរឿងនៃតិស្សកុមារចុះ ។ ប៉ុន្តែនេះ ជាវេលានៃការឲ្យនូវរសនៃត្រីក្រហម ដែលកុមារនេះឲ្យហើយ

ក្នុងកាលនៃខ្លួនកើតជាមនុស្សកម្សត់ទុគ៌ត ។ ក៏ក្នុងថ្ងៃតាំងឈ្មោះ, មាតារបស់កុមារនោះពោលថា បពិត្រលោកជាម្ចាស់ដ៏ចម្រើន ! លោកម្ចាស់សូមឲ្យសិក្ខាបទដល់ខ្ញុំប្រុសរបស់លោកម្ចាស់ ។ ព្រះថេរៈសួរថា ទារកនេះ ឈ្មោះអ្វី? ។ មាតាទូលថា បពិត្រលោកជាម្ចាស់! តាំងអំពីកាលដែលកុមារនេះមកចាប់បដិសន្ធិក្នុងផ្ទៃ មនុស្សគនិងមនុស្សឆ្កួត ក្នុងផ្ទះនេះត្រឡប់ទៅជាបណ្ឌិតទាំងអស់ ព្រោះដូច្នោះ បុត្ររបស់ខ្ញុំគួរឲ្យឈ្មោះថាបណ្ឌិតកុមារ ណាស់ ។ ព្រះថេរៈបានឲ្យសិក្ខាបទតាំងអំពីថ្ងៃដែលកុមារនោះកើតហើយ ។ មាតារបស់កុមារនោះគិតថា អញនឹងមិនជំទាស់អធ្យាស្រ័យនៃបុត្ររបស់អញទេ ។ ក្នុងវេលាមានអាយុ ៧ ខួប កុមារនោះបាននិយាយនឹងមាតាថា ខ្ញុំនឹងបួសក្នុងសម្នាក់របស់ព្រះថេរៈ ។ មាតាឆ្លើយថា ប្រពៃណាស់ហើយកូន! ម៉ែគិតទុករួចហើយថា នឹងមិនជំទាស់អធ្យាស្រ័យរបស់កូនទេ, ទើបនិមន្តព្រះថេរៈឲ្យឆាន់ រួចទូលថា ខ្ញុំប្រុសរបស់លោកម្ចាស់ជាក្មេងចង់បួស, ក្នុងវេលារសៀល ខ្ញុំនឹងនាំវាទៅវិហារ, សូមព្រះថេរៈនិមន្តទៅមុនចុះ, ហើយហៅពួកញាតិឲ្យមកប្រជុំគ្នា ប្រាប់ថា យើងទាំងឡាយ នឹងធ្វើសក្ការៈដែលគួរធ្វើ ក្នុងវេលាបុត្ររបស់ខ្ញុំនៅជាគ្រហស្ថ ក្នុងថ្ងៃនេះ, ប្រាប់រួចបបួលគ្នាធ្វើសក្ការៈធំ នាំយកកុមារនោះទៅវិហារ ប្រគល់ប្រគេនដល់ព្រះថេរៈ រួចទូលថា លោកម្ចាស់ សូមឲ្យកុមារនេះបួសចុះ ។ ព្រះថេរៈប្រាប់ថា បព្វជ្ជាជាការលំបាកធ្វើណាស់,

កាលកុមារឆ្លើយថា ខ្ញុំនឹងធ្វើតាមឱវាទរបស់លោកម្ចាស់, ព្រះថេរៈប្រាប់ថា បើដូច្នោះ អ្នកចូរមក!, រួចគោរសក់ ស្រេចហើយប្រាប់ តច-បញ្ចកកម្មដ្ឋាន ( គឺអារម្មណ៍ជាទីតាំងនៃកម្មមានស្បែកជាគម្រប់ប្រាំជាអារម្មណ៍ ) ឲ្យហើយឲ្យបួស ។ ឯមាតាបិតារបស់សាមណេរនោះ នៅក្នុងវិហារ(១)អស់ ៧ ថ្ងៃ ថ្វាយភត្តដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយសេចក្ដីទុក្ខក្រហាយដូចគ្នា ទើបត្រឡប់មកផ្ទះវិញ ក្នុងវេលារសៀលថ្ងៃទី ៧ ។ ក្នុងថ្ងៃទី ៨ កាលព្រះថេរៈចូលទៅក្នុងស្រុក ក៏នាំយកសាមណេរទៅផង មិនបានឲ្យនៅជាមួយនឹងភិក្ខុសង្ឃទេ ។

មានពាក្យ បុច្ឆា ជ្រៀតចូលមកថា ព្រោះហេតុអ្វី? ។ វិសជ្ជនាថា ការទទួលបាត្រនិងចីវរ ឬឥរិយាបថរបស់សាមណេរនោះ នៅមិនទាន់ជាការនាំមកនូវសេចក្ដីជ្រះថ្លាទេ, មួយទៀត វត្តដែលព្រះថេរៈគប្បីធ្វើក៏មាននៅក្នុងវិហារ, មួយទៀត កាលភិក្ខុសង្ឃចូលទៅក្នុងស្រុកហើយ ព្រះថេរៈនឹងត្រួតត្រាមើលទូទៅពេញវិហារ ប្រាសាទនិងដែលគេមិនបានបោស, តម្កល់ទឹកប្រើ ទឹកឆាន់ ទុកក្នុងភាជន៍ទទេ, ទុកដាក់គ្រែតាំងដែលគេទុកចោលរាត់រាយ ទើបចូលទៅស្រុកខាងក្រោយ, មួយទៀត ព្រះថេរៈគិតថា ពួកញាតិយើងកាលចូលទៅឃើញវិហារទទេ កុំឲ្យនិយាយ

១ ក្នុងគ្រាពុទ្ធកាល ទីវត្តទាំងមូលគេហៅថា វិហារ ៗ មិនមែនវត្តដោយឡែក, វិហារដោយឡែក ដូចសព្វថ្ងៃនេះទេ ។

បានថា លោកទាំងឡាយ ចូរមើលទឹកនៃដ៏ស្ដាប់ធម៌ របស់ពួកសាវកនៃព្រះសមណគោតម ដូច្នេះ, ប្រតិបត្តិពេញរិហាររួច ទើបចូលទៅក្នុងស្រុកជាខាងក្រោយ, ព្រោះហេតុនោះ ក្នុងថ្ងៃនោះ លោកឲ្យសាមណេរកាន់បាត្រនិងចីវរចូលទៅស្រុកក្នុងវេលាថ្ងៃខ្ពស់បន្តិច ។ កាលសាមណេរដើរទៅជាមួយនឹងព្រះឧបជ្ឈាយ៍ ឃើញប្រឡាយទឹកក្នុងចន្លោះផ្លូវ ក៏សួរថា នេះ គេហៅអ្វី ? ព្រះករុណា! គេហៅប្រឡាយទឹក សាមណេរ! ។ គេធ្វើអ្វីដោយប្រឡាយទឹកនេះ? ។ គេបង្ហូរនាំទឹកមកខាងឯណោះឯណេះ ដើម្បីធ្វើសស្យកម្ម (សទូង) របស់ខ្លួន ។ ចុះទឹកនេះ មានចិត្តដែរឬទេ? ។ គ្មានទេ អាវុសោ! ។ គេនាំទឹកដែលពុំមានចិត្តដូច្នេះ ទៅបានដែលខ្លួនប្រាថ្នាហើយៗ ឬ ? ។ យ៉ាងនោះហើយ អាវុសោ! ។ សាមណេរគិត ថាបើជនទាំងឡាយ គេនាំទឹកដែលពុំមានចិត្តដូច្នេះ ទៅកាន់បានដែលខ្លួនប្រាថ្នាហើយៗ បានហេតុម្ដេច ក៏ឯអ្នកដែលមានចិត្តនឹងមិនអាចញុំាងចិត្ត ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ហើយធ្វើសមណធម៌? ។ កាលសាមណេរ ដើរតទៅខាងមុខទៀតឃើញជាងធ្នូកំពុងកម្ដៅឈើឲ្យក្ដៅក្នុងភ្លើង ហើយសម្លឹងមើលដោយចុងភ្នែកពត់ឲ្យត្រង់ ដើម្បីធ្វើកូនសរ ក៏សួរថា ព្រះករុណា! មនុស្សពួកនេះ គេហៅពួកអ្វី? ។ គេហៅជាងកូនសរ ។ ចុះគេធ្វើឈើនេះ ។ គេយកឈើនេះកម្ដៅក្នុងឲ្យក្ដៅហើយពត់ឈើឲ្យត្រង់ ដើម្បីធ្វើកូនសរ ។ ឈើនោះមានចិត្តដែរឬ

ទេ ព្រះគុណ ? ។ គ្មានចិត្តទេ អាវុសោ ! ។ សាមណេរគិតថា បើដូច
ទាំងឡាយ កាន់យកឈើដែលឥតចិត្តពេលភ្លើងឲ្យក្តៅ ពត់ឲ្យត្រង់បាន
ម្តេចក៏មនុស្សដែលមានចិត្ត នឹងមិនអាចញុំាងចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅ
ក្នុងអំណាចហើយធ្វើសមណធម៌ ។ លុះសាមណេរដើរទៅមុខទៀត
ឃើញជាងចាំងកង់ធ្វើទឹងកៀរថជាដើម សួរថា ព្រះគុណ ! មនុស្សពួក
នេះគេហៅពួកអ្វី ? ។ គេហៅពួកជាងចាំង អាវុសោ ! ។ គេធ្វើអ្វី ? ។
គេយកឈើទាំងនេះធ្វើកង់យានជាដើម ។ ចុះឈើទាំងនេះ មានចិត្តដែរ
ឬទេ ព្រះគុណ ? ។ ពុំមានចិត្តទេ ។ លំដាប់នោះ សាមណេរមានបរិ-
វិតក្កថា បើដូចទាំងឡាយគេយកដុំឈើដែលឥតចិត្ត ធ្វើកង់ជាដើមបាន
ចុះហេតុអ្វី មនុស្សដែលមានចិត្ត ទឹងមិនអាចញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុង
អំណាចរបស់ខ្លួន ហើយធ្វើសមណធម៌ ។ សាមណេរ ឃើញហេតុទាំង
នេះហើយ ពោលថា ទានប្រោស បើព្រះគុណកាន់យកបាត្រនិងចីវរ
របស់ព្រះគុណទៅ ខ្ញុំព្រះករុណាសូមលាត្រឡប់ទៅវិហារវិញ ។

ព្រះថេរៈមិនគិតថា សាមណេរក្មេងនេះ បួសហើយមិនយូរ កំពុង
ដើរតាមអញ ហ៊ានពោលយ៉ាងនេះទេ, ទើបប្រាប់ថា អ្នកចូរឲ្យមក !
ហើយក៏ទទួលបាត្រនិងចីវររបស់លោកទៅ ។ ឯសាមណេរ សំពះលា
ឧបជ្ឈាយ៍ ហើយកាលនឹងវិលទៅវិញ ក៏ផ្តាំថា បើព្រះគុណនាំយកអា-
ហារមកឲ្យខ្ញុំព្រះករុណា សូមនាំមកដោយរសត្រីធំនក្រហមតែប៉ុណ្ណោះ ។

យើងនឹងបានពីណា អាវុសោ! ។ បើព្រះគុណមិនបានដោយបុណ្យរបស់ព្រះគុណទេ គង់តែនឹងបានដោយបុណ្យរបស់ខ្ញុំព្រះករុណាដែរ ។ ព្រះថេរៈ គិតក្រែងមានអន្តរាយដល់សាមណេរ ដែលអង្គុយនៅខាងក្រៅ ទើបឲ្យកូនសោ ហើយផ្តាំថា អ្នកឯង ចូរបើកទ្វារបន្ទប់លំនៅរបស់យើង ហើយចូលទៅអង្គុយខាងក្នុងចុះ ។ សាមណេរក៏ធ្វើតាមព្រះឧបជ្ឈាយ៍ផ្តាំ ហើយ ញ៉ាំងញាណឲ្យស្ទុងចុះក្នុងករជកាយរបស់ខ្លួន អង្គុយពិចារណាអត្តភាព ។

គ្រានោះ អាសនៈរបស់ព្រះឥន្ទ្រសម្តែងអាការគឺភាពជាអាសនៈក្តៅ ដោយតេជះនៃគុណរបស់សាមណេរ ។ ព្រះឥន្ទ្រពិចារណាមើលថា មានហេតុអ្វីហ្ន៎? ទ្រង់ព្រះតម្រិះថា បណ្ឌិតសាមណេរឲ្យបាត្រនិងចីវរដល់ព្រះឧបជ្ឈាយ៍ហើយត្រឡប់មកវិហារវិញ តាំងចិត្តថា នឹងធ្វើសមណធម៌ត្រូវអញទៅក្នុងទីនោះ ទើបគួរ គិតរួចត្រាស់ហៅមហារាជទាំង ៤ មកប្រាប់ថា អ្នកចូរដេញសត្វស្លាបដែលហើរត្រាច់នៅក្នុងព្រៃជិតវិហារ ហើយនៅចាំថែរក្សាឲ្យជុំវិញ, ត្រាស់ប្រាប់ចន្ទទេវបុត្រថា អ្នកចូរទាញទប់មណ្ឌលនៃព្រះចន្ទទុកសិន, ត្រាស់ប្រាប់សុរិយទេវបុត្រថា អ្នកចូរទាញទប់មណ្ឌលនៃព្រះអាទិត្យទុកសិន, ចំណែកព្រះអង្គ ស្តេចទៅឈរចាំរក្សាក្នុងទីនៃខ្សែសម្រាប់ទាញ (គន្លឹះទ្វារ) ។ ក្នុងវិហារ សូម្បីតែសំឡេងនៃស្លឹកឈើចាស់ក៏គ្មានដែរ ។ ចិត្តរបស់សាមណេរ បាននឹងធឹងហើយ ។ សាមណេរ

ពិចារណាអត្តភាព ក៏បានសម្រេចផលទាំងបី ក្នុងចន្លោះកត្តនោះឯង ។ ចំណែកព្រះថេរៈគិតថា សាមណេរអង្គុយក្នុងព្រះវិហារ អញអាចនឹងរកបានភោជនយកទៅផ្ញើ ក្នុងត្រកូលឈ្មោះឯណោះ គិតហើយក៏និមន្តទៅឯត្រកូលឧបដ្ឋាក ដែលមានសេចក្តីស្រឡាញ់ និងសេចក្តីគោរព មួយកន្លែង ។ ក្នុងថ្ងៃនោះ មនុស្សទាំងឡាយក្នុងត្រកូលនោះ បានត្រីឆ្ពីនក្រហមជាច្រើន អង្គុយចាំមើលដំណើរមករបស់ព្រះថេរៈផ្លូវ ។ លុះឃើញព្រះថេរៈនិមន្តមកដល់ ក៏និមន្តឲ្យចូលទៅខាងក្នុងទូលថា ព្រះករុណាម្ចាស់និមន្តមកក្នុងទីនេះប្រពៃហើយ ទូលរួច ប្រគេនបបរនិងចង្អែមជាដើម បានប្រគេនបិណ្ឌបាតដោយសេត្រីឆ្ពីនក្រហម ។ ព្រះថេរសម្តែងអាការមិននាំយកទៅ ។ មនុស្សទាំងឡាយទូលថា និមន្តឆាន់ចុះ ទានព្រួសព្រះគុណម្ចាស់នឹងបានខ្ទូរគត្តដែលនឹងនាំយកទៅ, ក្នុងវេលាស្រេចកត្តកិច្ច យកភោជនលាយដោយសេត្រីឆ្ពីនក្រហម ដាក់ពេញបាត្ររបស់ព្រះថេរៈហើយប្រគេន ។ ព្រះថេរៈប្រញាប់និមន្តមក ដោយគិតថា សាមណេររបស់អញឃ្លានហើយ ។ ក្នុងថ្ងៃនោះ ចំណែកព្រះសាស្តាសោយអំពីព្រឹករួចស្រេច ស្តេចទៅវិហារ ទ្រង់ពិចារណាថា បណ្ឌិតសាមណេរឲ្យបាត្រនឹងចីវរដល់ព្រះឧបជ្ឈាយ៍ ហើយត្រឡប់មកវិញ ប្រាថ្នានឹងធ្វើសមណធម៌ កិច្ចនៃបព្វជិតរបស់សាមណេរនឹងដល់នូវទីបំផុតឬទេ? ទ្រង់ជ្រាបថា សាមណេរបានសម្រេចផលទាំងបីហើយ ទ្រង់ពិចារណាថា ធម៌ជា

ឧបនិស្ស័យ នៃព្រះអរហត្ត មានឬគ្មានទេ ? ទ្រង់ឃើញថា មាន, ទ្រង់ពិចារណាតទៅទៀតថា សាមណេរ នឹងអាចសម្រេចព្រះអរហត្ត ក្នុងវេលាមុនភត្តតែម្តងឬទេ ? ទ្រង់ជ្រាបថា នឹងអាចបានសម្រេច ។ លំដាប់នោះ ព្រះអង្គទ្រង់ព្រះបរិវិតក្កថា បើសារីបុត្តយកភត្តប្រញាប់មក ដើម្បីឲ្យសាមណេរ មុខជានឹងធ្វើនូវអន្តរាយដល់សាមណេរនោះ តថាគតនឹងទៅអង្គុយចាំរក្សាត្រង់មាត់ទ្វារ លុះសារីបុត្ត ទៅដល់ហើយ តថាគតនឹងសួរប្រស្នាបួនប្រការដល់លោក, កាលលោកឆ្លើយប្រស្នា, សាមណេរនឹងបានសម្រេចព្រះ អរហត្ត ព្រមទាំងបដិសម្ភិទាញាណ, ទ្រង់ជ្រាបដូច្នេះហើយ ស្តេចចេញអំពីព្រះគន្ធកុដិ ទៅទ្រង់ឈរនៅជិតមាត់ទ្វារ ត្រាស់សួរប្រស្នាបួនប្រការ នឹងព្រះថេរៈដែលមកដល់ហើយ ។ ព្រះថេរៈក៏ឆ្លើយប្រស្នាដែលព្រះសាស្តាត្រាស់សួរគ្រប់ប្រការ ។

ក្នុងប្រស្នានោះ មានពាក្យបុច្ឆានិងវិសជ្ជនាតទៅនេះ : "បានឮមកថា ព្រះសាស្តាត្រាស់សួរព្រះថេរៈថា សារីបុត្ត អ្នកបានអ្វីយកមក? ។ បានអាហារយកមក ព្រះអង្គ ! ។ ចុះអាហារនាំមកនូវអ្វី? ។ នាំមកនូវវេទនា ។ ចុះវេទនានាំមកនូវអ្វី? ។ នាំមកនូវរូប ។ ចុះរូបនាំមកនូវអ្វី? ។ នាំមកនូវផស្សៈ" ។

ក្នុងប្រស្នានោះ មានអធិប្បាយដូចតទៅនេះ ៖

មែនពិត អាហារដែលបុគ្គលឃ្លាន តែងបរិភោគហើយបន្ទាបង់សេចក្ដីឃ្លានរបស់បុគ្គលនោះ "នាំមកនូវសុខវេទនា", កាលសុខវេទនាកើតដល់បុគ្គលដែលដល់ហើយ នូវសុខដោយការបរិភោគអាហារ រមែងមានសេចក្ដីបរិបូណ៌នៃវណ្ណៈនាសរីរៈ "វេទនានាំរូបមក" យ៉ាងនេះ, ក៏បុគ្គលអ្នកដល់សុខហើយ រមែងមានសុខសោមនស្សកើតឡើងដោយអំណាចនៃរូបដែលកើតព្រោះអាហារ គិតថា ឥឡូវនេះសេចក្ដីជ្រះថ្លាចិត្តកើតដល់អញហើយ ដេកប្អែកផ្អៀង រមែងបានសុខសម្ផស្ស ។ កាលព្រះថេរៈវិសជ្ជនាប្រស្នាបួនប្រការយ៉ាងនេះចប់ហើយ សាមណេរក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាញាណ ។ ទើបព្រះសាស្ដា ទ្រង់ត្រាស់នឹងព្រះថេរៈថា សារីបុត្ត! អ្នកចូរទៅចុះ! អ្នកចូរឲ្យភត្តដល់សាមណេររបស់អ្នកចុះ ។ ព្រះថេរៈ ក៏ទៅគោះទ្វារហៅសាមណេរ ។ សាមណេរបើកទ្វារចេញមកទទួលបាត្រ អំពីព្រះហស្តព្រះថេរៈដាក់ទុកក្នុងចំណែកម្ខាង ហើយបក់ព្រះថេរៈដោយផ្លិតស្លឹកត្នោត ។ ព្រះថេរៈទើបពោលនឹងសាមណេរថា សាមណេរ! អ្នកចូរធ្វើភត្តកិច្ចចុះ ។ សាមណេរសួរថា ចុះព្រះគុណម្ចាស់? ។ ព្រះថេរៈប្រាប់ថា យើងធ្វើភត្តកិច្ចរួចហើយ អ្នកចូរធ្វើចុះ ។ ក្មេងអាយុ ៧ ខួបបួសហើយ, ក្នុងថ្ងៃទី ៨ បានសម្រេចព្រះអរហត្ត ដូចជាផ្កាឈូកដែលរីកហើយក្នុងថ្ងៃនោះ រង្គំបច្ចវេក្ខណានូវទីធ្លាយក្នុងមាត់ បានធ្វើភត្តកិច្ចរួចស្រេចហើយ ។

ក្នុងវេលាសាមណេរលាងបាត្រទុកដាក់រួចស្រេចហើយនោះ ចន្ទទេវ-បុត្រ លែង ចន្ទមណ្ឌល, សុរិយទេវបុត្រ លែង សុរិយ-មណ្ឌល, មហារាជទាំងបួនលែងនៅរក្សាក្នុងទិសទាំងបួន, សក្កៈ-ទេវរាជ លែងរក្សាត្រង់មាត់ទ្វារ ។ ព្រះអាទិត្យលឿនទៅហួសពាក់កណ្តាល (ថ្ងៃត្រង់) ។ ភិក្ខុទាំងឡាយតិះដៀលថា ស្រមោលហួសប្រមាណហើយ ព្រះអាទិត្យលឿនទៅ ហួសពីពាក់កណ្តាល (ថ្ងៃត្រង់) ហើយ, សាមណេរឆាន់បាយវេលានេះ តើហេតុនេះដូចម្តេចទៅ? ។ ព្រះសាស្តាទ្រង់ជ្រាបហេតុនោះហើយ ស្តេចមកដល់ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ! ពួកអ្នកនិយាយគ្នាពីរឿងអ្វី ។ កាលពួកភិក្ខុក្រាបទូលទ្រង់ជ្រាបហើយ ព្រះអង្គត្រាស់ថា យ៉ាងហ្នឹងហើយ ភិក្ខុទាំងឡាយ! ក្នុងវេលាអ្នកមានបុណ្យធ្វើសមណធម៌ ចន្ទទេវបុត្រទាញទប់ ចន្ទមណ្ឌល ទុក, សុរិយទេវបុត្រ ទាញទប់ សុរិយមណ្ឌល ទុក, មហារាជទាំងបួន នៅចាំរក្សាទិសទាំងបួនក្នុងព្រៃជិតវិហារ, សក្កទេវរាជ ស្តេចមកនៅចាំរក្សាត្រង់ទ្វារ, សូម្បីតថាគត ក៏មិនបានអង្គុយស្ងៀម ដោយគិតថាតថាគតជាព្រះពុទ្ធដូច្នេះដែរ ឧស្សាហ៍ដើរទៅនៅចាំរក្សាបុត្រតថាគតត្រង់មាត់ទ្វារ, បណ្ឌិតទាំងឡាយឃើញមនុស្សបង្ហូរទឹក នាំយកទឹកក្នុងប្រឡាយទៅបាន ទិងឃើញជាងកូនសរពត់កូនសរឲ្យត្រង់បាន និងឃើញជាងចាំងកំពុងចាំង

ឈើ ក៏កាន់យកមកធ្វើឲ្យជាអារម្មណ៍តែត្រឹមប៉ុណ្ណោះ ទើងអាចទូន្មានខ្លួន ហើយកាន់យកព្រះអរហត្តបាន, ព្រះអង្គទ្រង់ត្រាស់ដូច្នេះហើយ កាល ទ្រង់តអនុសន្ធិ ទើបសម្តែងធម៌ដោយបទគាថានេះថា ៖

ឧទកំ ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ, អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតតាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះដែរ) ។

ក្នុងវេលាបប់ធម្មទេសនា ជនជាច្រើននាក់បានសម្រេចសោតាបត្តិ-ផលជាដើម ។

✻

សេចក្តីសង្ខេបក្នុងរឿង បណ្ឌិតសាមណេរ នេះ ៖

មានបុរសកម្សត់ទុគ៌តម្នាក់ ធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិត កើតចិត្តសទ្ធាជ្រះថ្លាបានថ្វាយទានចំពោះព្រះមហាសាវក្ត, ផលបុណ្យនោះ បណ្តាលឲ្យព្រះឥន្ទ្របាចរតនៈ ៧ ប្រការឲ្យយ៉ាងច្រើន ហេតុដល់បាន

គំណែងសេដ្ឋីទៀត, លុះច្យុតពីអត្តភាពនោះហើយ បានមកកើតក្នុងត្រ-កូលជាឧបដ្ឋាកនៃព្រះសារីបុត្តត្ថេរបាននាមថា "បណ្ឌិត", ផលបុណ្យតាមជាប់ប្រកំតឲ្យបានសម្រេចព្រះ អរហត្ត ក្នុងអាយុ ៧ ខួប ។

រឿងបណ្ឌិតសាមណេរ ចប់ ។

## ប៊ិ-ប៉ី

អ្នកមានចំណេះវិជ្ជាផ្សេង ៗ
កុំប្រទូសនឹងអ្នកមានបុណ្យ

អ្នកមានប្រាជ្ញា តែខ្វះវាសនា បុណ្យព្រេងវេរា
នោះដូចឈើខ្ទឹម ដុះសើមក្នុងព្រៃ ឥតគេយកធ្វើ
ឲ្យថ្លៃខ្ពង់ខ្ពស់

ផល-និតិ

# វិចារណកថា

## ការផ្លាស់ប្ដូរប្រពៃណី ក្នុងរឿងរកគូស្រករ

ប្រពៃណីក្ដី ទំនៀមក្ដី ទម្លាប់ក្ដី ពាក្យនេះមានន័យប្រហែលៗគ្នា បើធ្ងន់ស្រាល ក៏តែបន្តិចបន្តួចប៉ុណ្ណោះ ។ រួមសេចក្ដីទៅ គឺមានន័យថានិយម ប្រកាន់នឹងភ្ជាប់ប្រព្រឹត្ត ដំរូវអន្លើមក ។ ការយកបាយទុកជាអាហារទីមួយ សម្រាប់ចិញ្ចឹមជីវិត គឺជាប្រពៃណីម្យ៉ាង ការយកនំបុ័ង ទុកជាអាហារទីមួយសម្រាប់ចិញ្ចឹមជីវិត គឺជាប្រពៃណីម្យ៉ាងទៀត ។ល។

ក្នុងសាកលលោក តាមការសង្កេត ឃើញថាមានប្រពៃណីប្លែកៗគ្នាច្រើនអនេក ខ្លះទទួលទានបាយនឹងដៃ ខ្លះនឹងចង្កឹះ ខ្លះនឹងស្លាបព្រា ខ្លះស្លៀកខោ ខ្លះសំពត់ ខ្លះរុំ ខ្លះសារុង ។ល។

តើប្រពៃណីនេះ មានទទួលការប្រែប្រួលដែរឬទេ ?

ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់សម្ដែងថា: អ្វីៗក្នុងលោក សុទ្ធតែមិនទៀងទាំងអស់ ។ ដូច្នេះ សំនួរខាងលើនេះ ត្រូវទុកជាមោឃ: ប្រសិនបើត្រូវគោរពតាមព្រះឱវាទរបស់ព្រះអង្គ ។

បណ្ដាប្រពៃណីខ្មែរទាំងឡាយខ្លះរបស់យើង ដែលមានការប្រែប្រួលនោះ មានប្រពៃណីមួយគួរឲ្យចាប់អារម្មណ៍ជាងគេ គឺរឿងរកគូ

ស្រុកនេះឯង ។ ហេតុដូចម្ដេចក៏ដូច្នេះ ? វាមកពីមានការប្រែប្រួលព្រាសស្រុក ។

តាមប្រពៃណីដើមរបស់ខ្មែរយើង ការរកគូស្រករឲ្យបុត្រធីតាគឺតម្រូវឲ្យខាងប្រុសទៅស្ដីដណ្ដឹងខាងស្រី ហើយសេចក្ដីបង្គាប់ទាំងប៉ុន្មានគឺខាងស្រីលើកទម្លាក់មកលើខាងប្រុស ទោះបីច្រើនតិចឬធ្ងន់ស្រាលដូចម្ដេច អនុលោមទៅតាមការសន្ដោស ឬមិនសន្ដោសគ្នាទៅវិញទៅមក ឬអនុលោមទៅតាមធនធានតិចច្រើនរបស់ខាងប្រុសដែលទ្រាំទ្របាន ឬមិនបានប៉ុណ្ណោះ ។ ប្រពៃណីបែបនេះ គឺត្រូវជនជាតិខ្មែរគោរពដំហូរហែមក ជាច្រើនសតវត្សណាស់មកហើយ ។

រឿងប្រែប្រួលប្រពៃណីនៃប្រទេសនីមួយ ៗ ទោះបីតិចក្ដីឬច្រើនក្ដី គឺអាស្រ័យដោយកត្ដាដ៏ច្រើន ។ ឯកត្ដាដ៏ធំចម្បងជាងគេ គឺសម្ភារៈនិយមនេះឯង ។ មែនពិត សម្ភារៈនិយមរមែងតែដើរមុខគេ ។ ទាំងអស់អ៊ីចឹងមែនហើយ ដ្បិតថាការបង្កបង្កើតអ្វីមួយ ត្រូវតែពឹងផ្អែកទៅលើសម្ភារនិយមនេះឯងជាបឋមខានពុំបានឡើយ ។ ក៏ប៉ុន្ដែបើយើងប្រកាន់នាំជ្រុលពេកតែទៅលើមុខនេះ គ្មានងាកមើលទៅខាងសីលធម៌ផងនោះ និងជាហេតុនាំឲ្យបានសេចក្ដីសុខដុមរមនារវាងមនុស្សទាំងឡាយក្នុងសង្គមមិនខាន ។ ព្រោះតែការប្រកាន់សម្ភារនិយមខ្លាំងពេកនេះហើយ ទើបគេបង្កើតទ្រឹស្ដីព្រៃម្យ៉ាងថា: «មនុស្ស បងប្អូនគ្នាតែ

ខ្លួនទេ ចំណែកប្រាក់មិនមែនបងប្អូនទេ" ។ ដោយអាស្រ័យការប្រកាន់ទ្រឹស្តីនេះហើយ បានជាសម័យបច្ចុប្បន្ននេះ មានមនុស្សភាគច្រើនហ៊ានធ្វើឲ្យប្រពៃណីខ្មែរខាងរកគូស្រករ មានសភាពប្រែប្រួលប្រាសស្រកី ដូច្នេះ ។

រឿងប្រែប្រួលប្រាសប្រកីនេះ កាលក្នុងជំនាន់អាណាព្យាបាល ក៏មានខ្លះដែរ តែភាគតិចណាស់ តិចទាល់តែមិនសូវមានអ្នកណាចាប់ក្តឹកដល់ ។ ក្នុងសម័យនោះរឿងនេះកើតមានចំពោះតែគ្រួសារវរជនខ្លះប៉ុណ្ណោះ ជាវរជនដែលមានឥទ្ធិពលជាងគេក្នុងផ្លូវកិច្ចការរាជការ ។

ក៏ឯសម័យសង្គមនេះ ការផ្លាស់ប្តូរប្រពៃណីក្នុងរឿងរកគូស្រករគឺលេចឃើញជាក់ច្បាស់ដូចថ្ងៃ ក្នុងចំណោមជនជាតិខ្មែរភាគច្រើនដាច់ខាត ។

មានការណ៍មួយគួរឲ្យអៀនខ្មាសទាំងគួរឲ្យអស់សំណើចផង គឺនៅត្រង់មានអ្នកស៊ីក្បាលហាច ។ ប្រពៃណីដ៏ចាស់ក្រិនមកហើយ មិនមែនគ្មានឥទ្ធិពលសោះទេ សូម្បីក្នុងសម័យនេះក្តី គឺមែនធ្វើឲ្យអ្នកប្រកាន់ទំនៀមទម្លាប់ប្រពៃណីមានការតឹងអៀមទង់ខ្មាសអៀនមិនហ៊ានបញ្ចេញមុខត្រង់ៗខ្លះដែរ ។ ហេតុដូច្នេះហើយ ទើបមានកត្តាចំឡែកមួយបានលេចមុខចេញមកជាប៉ាំង គឺអ្នកស៊ីក្បាលហាបនេះឯង ។ គឺជាគ្រឿងសម្ភារៈសព្វយ៉ាងនោះពីខាងស្រីទាំងអស់ : "របស់ព្រះ បូជាព្រះ" ។

សព្វថ្ងៃអ្នកស៊ីក្បាលហាប ជាស្រីក៏មាន ជាប្រុសក៏មាន តែបើតាមការសង្កេត គឺស្រីភាគច្រើន ។ រឿងនេះមិនខុសពីអ្នកដើរសារខាងទិញថេយន្ត ឬលក់ថេយន្ត ខាងលក់ស្រូវ លក់ជ្រូក ។ល។ ឡើយ ។ អ្នកស៊ីក្បាលហាបនេះ ជួនកាលបបួលបង្គាប់ពីខាងស្រីថា បើរកបានប្រុសមានប្រាក់ខែប៉ុនប៉ុណ្ណេះ ត្រូវបានក្បាលហាបប៉ុណ្ណេះ បើរកបានប្រុសមានប្រាក់បៀវត្សប៉ុនប៉ុណ្ណេះ ត្រូវបានក្បាលហាបលើសឬថយចុះ ។ ឯរឿងក្បាលហាបតិចឬច្រើន អនុលោមទៅតាមទំហំបៀវត្សនៃសាមីខ្លួនខាងប្រុស ។ ជួនកាលអ្នកស៊ីក្បាលហាបរកបានសាមីខ្លួនខាងប្រុស ៣-៤ នាក់ ដាក់វេចខ្ចប់យកទៅជាមួយ រួចដើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុក ពីខេត្តមួយទៅខេត្តមួយ ដើម្បីស្វែងរកផ្ទះណាដែលមានកូនស្រីនៅលីវ ។ កាលបើបានជួបប្រទះហើយ អ្នកស៊ីក្បាលហាបក៏ស្រាយចង្អើយយកឈ្មោះមកបង្ហាញព្រមទាំងបរិយាយអំពីឋានៈ និងមុខងារក្នុងកិច្ចការនៃសាមីខ្លួនខាងប្រុស ប្រាប់គ្រួសារខាងស្រី ដោយវិធីបញ្ចុះបញ្ចូលបញ្ចេះ ៗ ផង ដើម្បីសណ្ដំទឹកចិត្ត ។ រីឯក្បាលហាបនោះ គឺអនុលោមទៅតាមឋានៈខ្ពស់ទាបក្នុងកិច្ចការរាជការ មានមួយពាន់-ពីរពាន់-បីពាន់ ។ល។ មិនតែក្បាលហាបប៉ុណ្ណោះទេ គឺ.នៅថ្ងៃទឹកតែដែលខាងប្រុសត្រូវផ្ដល់ទៅឲ្យខាងប្រុសព្រមទាំងថ្លៃរៀបអាពាហ៍ពិពាហ៍ផងទៀត ។ លុះត្រូវរ៉ូវគ្នាហើយ ទើបគេការកូនខាងស្រីយកទៅឲ្យខាងប្រុស

សម្រាប់ពិនិត្យមើល ឬមួយក៏ខាងស្រីកំណត់ពេលវេលា ឲ្យខាងប្រុសមកដូរខ្លួនវិញ ដើម្បីពិនិត្យរូបសម្បត្តិខាងស្រី ហើយទើបសម្រេចការណ៍ជាស្ថាពរ ប្រសិនបើមានការព្រមព្រៀងគ្នាពីគូភាគីទាំងពីរ ។

ចំពោះរឿងនេះមិនសម្រេចតែត្រឹមតម្លៃទឹកដៃប៉ុណ្ណោះទេ គឺជួនកាលខាងប្រុសមិនស្របតាមផងក៏មានដែរ ព្រោះមានខ្លះត្រូវការតម្លៃទឹកដៃផង ត្រូវការរូបសម្បត្តិផង ហើយដែលមិនព្រមនោះ គឺមកពីខុសខាងរូបសម្បត្តិ ។ តែបើតាមការសង្កេត ឃើញថាភាគច្រើនពេញចិត្តនឹងតម្លៃទឹកដៃណាស់ ត្រង់រូបសម្បត្តិល្មមៗក៏បានហើយ ។

សេចក្តីដូចពោលខាងលើ អាចហុចនូវលទ្ធផលមិនប្រពៃពីភេទស្រីក្នុងយុវភាពប្រពៃណីបានចាត់ទុកជាវត្ថុបរិសុទ្ធ និងមានតម្លៃថ្លៃថ្នូរជាទីគោរពផង បុរសណាប្រាថ្នាចង់បានជាគូប្រពាំជីវិត ត្រូវតែចាត់ឲ្យអ្នកផ្លូវចៅមហា ទៅនិយាយចែចូវ ស្តីដណ្តឹងតាមសម្រួល បើព្រមព្រៀងគ្នាហើយ ការកិច្ចខាងរៀបចំគ្រឿងបណ្ណាការព្រមទាំងពិធីជប់លៀងភ្ញៀវ ស្រេចនៅលើខាងប្រុស ។ នេះមិនដូចឈ្មោះ បុប្ផាបែរជាទៅស្វែករកគូន៍ សុំឲ្យមេត្តាមកគ្រប់លំអងកេសរដ៏បរិសុទ្ធរបស់ខ្លួនទៅវិញ ។ ភេទប្រុស តាមហូរហែមក គេទុកជាភេទប្រកបដោយថាមពល ភេទអង់អាចលើកិត្តិយសស្ត្រីព្រហ្មចារី ក៏ទៅជាដូចម្តេច តើនៅត្រង់ណា? កិច្ចការភ្ជាប់ផ្សេងៗជាខាងក្រៅគេហដ្ឋាន មានកិច្ចប្រកបមុខរបរសម្រាប់

ចិញ្ចឹមជីវិត កិច្ចត្រួតត្រាការរកជការនានា កិច្ចធ្វើសង្គ្រាមដើម្បីការពារបូរណភាពទឹកដីជាដើម ត្រូវជាភារៈរបស់ខ្លួនហើយ ទោះបីលទ្ធិប្រជាធិបតេយ្យបានអនុញ្ញាតឲ្យស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នា នៅចំពោះមុខច្បាប់ក្តី ៗ តែឡូវនេះ នៅជាបណ្តោយឲ្យគេទិញដូចជ្រូកឬឲ្យគេទិញដូចឥឡូក ត្រឡាច តាមអំពើចិត្តបាន ៗ តើកិត្តិយសភេទប្រុសនៅត្រង់ណា ?

លទ្ធផលមិនគាប់ប្រសើរទាំងពីរបែប ដូចពោលមកនេះ តើបណ្តាលមកអំពីអ្វី ? តើមានអ្វីជាមូលហេតុ ? ឆ្លើយថាមូលហេតុនោះ គ្មានអ្វីក្រៅពី ការប្រកាន់សម្ភារនិយមហួសប្រមាណពេកតែប៉ុណ្ណោះឯង ៗ ដូចយើងឃើញស្រាប់ ក្នុងពិភពលោកតាំងពីសតវត្សទី ១៩ រហូតមកដល់សតវត្សទី ២០ នេះ ខាងក្រោយឥទ្ធិពលនៃអាស៊ីទ្វីបបានចុះអន់ថយមក ទ្វីបខាងបស្ចិមទិស ជាអ្នកប្រកាន់សម្ភារនិយម ៗ ពេលចុងក្រោយនេះ សហរដ្ឋអាមេរិកក៏បានឡើងឋានៈជាមេក្លោង ខាងលទ្ធិនេះ ៗ តើលោកបានស្គាល់សុខសន្តិភាពដែរទេ ? ការខ្វះសុខសន្តិភាពនេះមានបុព្វហេតុតែពីការប្រកាន់សម្ភារនិយមហួសប្រមាណនេះឯង ៗ

ឥឡូវដប៉ូនេះបានចូលមកក្នុងប្រទេសយើងហើយ ៗ តែដោយយើងខ្វះឥទ្ធិពលខាងវិទ្យាសាស្ត្រនិងខាងសឹក ការប្រកាន់សម្ភារនិយមនេះ ក៏ស្ទុះទៅជ្រៀតជ្រែកចូលត្រង់កន្លែងស្នូលគឺការផ្លាស់ប្តូរប្រពៃ-

ណ៏ក្នុងរឿងគេគូស្រករនេះឯងទៅវិញ ។

ទោះជាយ៉ាងនេះក្តី ក៏គង់មានខាងស្រីខ្លះ ត្រូវក្ងាត់ដៃជើងហើយដួលតាក់ទីងហីងហោង ព្រោះតែយុវបុរសខ្លះដែរ ។ ខាងស្រីបានទិញយុវបុរសចិញ្ចឹមប្រោះទុក (មិនទាន់ចប់កិច្ចសិក្សា ហើយខ្លាចក្រែងទិញយកមិនទាន់គេ) ដោយចំណាយចិញ្ចឹមមុន ព្រមទាំងទិញមធ្យោបាយដឹកនាំឲ្យប្រើផង មានម៉ូតូជាដើម ។ លុះដល់ទីបំផុត យុវបុរសយើងកែប្រែគំនិតជាថ្មី ដោយជាប់ស្នេហាទៅលើនារីដទៃ ដែលមានសោភណភាពគ្រាន់បើជាង ។ មធ្យោបាយក្រឡិចក្រឡុចនេះ បានធ្វើឲ្យខាងស្រីយើងប្រឡោតតោតតូង ព្រមទាំងយំមិនចេញទឹកភ្នែកផង ព្រោះគ្មានកិច្ចសន្យាអ្វីដ៏ត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែផ្នែកបែបនេះជាភាគតិចទេ ។

នេះហើយ គេហៅថាៈ ការផ្លាស់ប្តូរប្រពៃណីប្រាសស្រកី ។

ផេង-ជ្រីវ (២៨ ៨ ៦៩)

# ចម្រៀង បញ្ចសិខគន្ធព្វទេវបុត្រ

## ដកស្រង់អំពីសក្កបញ្ហសូត្រ សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ភាគ ១៧ មករៀបរៀងជាពាក្យកាព្យ

### ព្រហ្មគីតិ

កាលដែលព្រះជិនស្រី ទើបត្រាស់ថ្មីហើយចមកត សម្រន់· សម្រាកឈប់ គង់ក្រោមម្លប់អជបាល ៗ និគ្រោធដ៏ត្រឈៃ នៅ ក្នុងព្រៃត្រួត្រអាល ទីនោះបាត់តាមកាល ហៅសប្តាហៈទីប្រាំ ៗ ទ្រង់ សោយសេរិមុត្តិ វិសេសផុតពាកកង់កម្ម កិលេសដ៏សាំញ៉ាំ ដែល ដេកត្រាំក្នុងហឫទ័យ ៗ គឺសរព្រះនិព្វាន ដ៏ជាឋានឥតទុក្ខភ័យ ហៅ សុខសែនប្រពៃ ទៀបគល់ជ្រៃនោះឯងណា ៗ

គ្រានោះទេវបុត្រ បរិសុទ្ធមាននាមថា "បញ្ចសិខគន្ធព្វ" បិត នៅនាតាវត្តិង្ស ៗ ជាអ្នកស្ទាត់ក្នុងល្បែង ត្រុកកំប្លែងដ៏វីងប៉ិន ពួក ទេពទទួលដឹង ស្គាល់ថាជាអ្នកចំណាន ៗ ចំណាប់ក្នុងសួគា គ្មាន អ្នកណាប្រៀបធៀបបាន ខាងការលេងកំសាន្ត លំហែប្រាណសព្វ ៗ កាល ៗ គន្ធព្វទេពនោះឯង បិត្តចំបែងតាមបណ្តាល គឺចង់ លេងក្រសាល ត្រេកត្រអាលទំងធីតា ៗ នៃតិម្ពរុរាជ មានអំណាច

ដ៏ក្លៀវក្លា ឈ្មោះនាងសុរិយា(១) វច្ចសាប្រសើរសោយ ៗ តែនាងមិនរវល់ មិនព្រមយល់ប្រគល់កាយ ធ្វើឫកហាក់នឿយណាយ ព្រោះឆោមឆាយនាងជាប់ចិត្ត ៗ ស្រឡាញ់ប្រុសដទៃ កើតប្រពៃគួរស្នេហ៍ស្និទ្ធ មាននាមជាកំរិត „សិខណ្ឌិទេវបុត្រ" ៗ ជាកូនមាតលីសារថីបរិសុទ្ធ នៅឋានប្រសើរផុត គឺត្រៃត្រិង្សសិងប្រពៃ ៗ ទុកជាបញ្ចសិខៈ គន្ធព្វៈរិះគិតវៃ រកកលផ្សេងដទៃ ដ៏ប្រពៃមកចែចង់ៗ នាងនៅតែមិនដោយ មិនព្រមឲ្យប៉ះដល់អង្គ មិនងាកក័ក្រ្ពតម្រង់ចំពោះត្រង់តិចតួចសោះ ៗ ទើបតុកទេពគន្ធព្វ កាន់ពិណគាប់ដោយចិត្តស្មោះ គគាតចូលចំពោះ កាន់សំណាក់នៃបរម ៗ តិម្ពរុកបិតាលើកហត្ថាឡើងប្រណម្យ រឹតខ្សែពិណឲ្យសម ទំនងសម្លេងរបស់ខ្លួនៗ ហើយតាំងផ្ដើមចម្រៀង ដេញពិណច្រៀងឡើងក្រអួន សម្របប្រកបជូន ចែចង់ទូនកនិដ្ឋា ៗ ទាក់ទងដោយព្រះពុទ្ធ ព្រះធម៌សុទ្ធព្រះសង្ឃថា បម្រុះឈាយកាមា ដោយពាក្យថាដូច្នេះ ៖

ពាក្យ ៩

ឱហាសូរ្យាវច្ចសាធីតារម្យ !

រៀបសូមនុទលំពោនកាយថ្វាយបង្គំ

ដល់ឧត្តមបិតាដ៏នៃកញ្ញា ៗ

---

១- ក្នុងបាលី : "សុរិយវច្ចសា" ។

ឆោមឆ៏មន្ទួនស្ងួនមាសផ្អើនផ្ញុំកឿនសាយ
នាងមានកាយផ្សាយពន្លឺភ្លឺផ្លេកថ្លា
ក័ក្រតផ្លូវផង់វង់មូលក្លំសមនាសា
ចាំងមុខាហាញញឹមស្រស់ប្រិមប្រិយ៍ ៗ
សក់ខ្មៅយង់ទ្រង់ជ្រៀងជ្រវិលវល្វញ
អង្កាញ់ជ្រួញអង្កួញខ្វង់ខ្វង់ពិសី
បើកល្យាណបានមកបងគ្រងបី
រួមបេតីសិរីបិតចិត្តឥតអាក់ ៗ
ដូចដើរថ្ងូរត្រូវកំដៅសុបសៅខ្លួន
ស្រេកទឹកជួនជួនប្រទះស្រះត្រជាក់
ត្រេកអរក្តាត់បាត់បារម្ភក្រំថ្នាំងថ្នាក់
អាស្រ័យដាក់សំណាក់ស្រួលឥតអួលអន់ ៗ
ឬដូចជាញាយធម៌លែងញ័រញាប់(១)
ជាទីគាប់ជាប់ហឫទ័យនៃអរហន្ត
បើបងបានបាំនរួមរ័កស្ន័គ្រទឹងតន់
និងបានស្រទន់អន់សម្រេកស្រេកក្នុងប្រាណ ៗ
បងក្រហាល់ទល់ក្រហាយកាយចំប្រប់

---
១- ព្រះនិព្វាន ។

ស្ទើរសន្ទប់ចប់ឧកណ៌ាកល្យាណ
សូមនាងស្ងួយជួយជីវិតគិតឲ្យបាន
ផូរក្នុងប្រាណក្សាន្តទុក្ខតឹងរឹងអនេក ។
រៀមសូមអែបនែបនៅនិត្យជិតជនា(១)
នៃកញ្ញាថ្វ វរលក្ខណ៍ភ័ក្ត្រល្អឯក
សូមក្រមុំកុំខេរខឹងប្រឹងប្រកែក
សូមរំលែកចែកដាក់ទានមានផលា ។
បងអោនងប់ទប់មិនបានប្រាណក្តួលក្តៅ
ព្រោះតែក្ដៅពៅនាងល្អសក្តិប៉ា
ដូចដំរីក្ដីចុះប្រេងវែងខ្លាចផ្សា
ដោយតណ្ហាក្លាក្នុងចិត្តឥតគិតស្លាប់ ។
ចិត្តរៀមងប់ស៊ប់លើស្ងួនទួនស្នេហ៍ស្និទ្ធ
រឹងប្រឹតរឹតប្រកាន់ម៉ាន់ចំណាប់
ដកមិនរួចគួចយ៉ាងស្អិតចិត្តក្រឡាប់
ហាក់ដូចផ្កាប់ស្លាប់រាហ៊ីណាស្រីពៅ ។
ដូចជាត្រីងីសន្ទូចខ្ចូចទាំងប្រាណ
ដោះមិនបានច្រានមិនភ្លាត់ជាប់មាត់ជ្រៅ

១- ដោះ ។

ដួងចិត្តបងប៉ងប្អូនប្អូនទន់ឆោមឆ្ងៃ
ប្រាណមិនទៅនៅមិនស្ងៀមរៀមទុក្ខា ។
នៃឆោមឆាយកាយសស្ងួលបណ្ដូលចេក
ក្ដួរក្រឡេកត្រេកត្រកងនុបបង៉ា
ការរួបរ័តពិតជាបងប៉ងប្រាថ្នា
សូមដង៉ៅកុំថាម្ដេចហើយគេចចេញ ។
កាមនៃបងចងចិន្តាឥតក្លាក្លំ
តែស្ដន់ក្ប្យសមស្រទន់ទ្រលន់ពេញ
បែរជាច្រើនកើនចំណែកបែកចំណេញ
នាំជន្ទេញពេញជន្ទៀវចិត្ត ។
ដូចជាមានមានតិចគួចសួចស្ដើងទេ
ប៉ុន្តែគេរេគំនិតគិតស៊ុចរិច
ឲ្យដល់លោកគោកកក់លេសវិសេសសិទ្ធិ៍
ផលនោះពិតរឹតចំណេញពេញទូលាយ ។
ឱខ្លឹមខ្លួនខ្នួនពិសីស្រីចំឡែក
រូបល្អឯកថ្លៃកសង្ហាថ្លាឆើតឆាយ
បុណ្យក្រាស់ក្រៃលែងលើសធ្ងើលើបានកាយ
គឺបែកតាយថ្វាយដល់ព្រះឈ្មោះតណ្ហា ។

បុណ្យនោះនៃតែជំនួយជួយឲ្យបាន
ជួបកល្យាណប្រាណជំនិតជិតកាយា
កុំឲ្យល្អៀងឃ្លៀងចំណាន់បង់អាសា
បំណាច់ហាថាស្រឡាញ់បាញ់តម្រង់ ។
ព្រះវជិតបុត្រវិសុទ្ធផុតថ្កឹនថ្លែង
ច្រូង់ប្រឹងប្រែងស្វែងវិញ្ញានបាំនផ្លូវផង
មិនគិតម៉ាយណាយល់បាកយ៉ាកដល់អង្គ
ព្រះទ័យត្រង់ផ្លូងចំពោះនោះយ៉ាងណា ។
រីខ្ជួនបនប៉ងបណ្ណាលហើយចូលមក
ប្រឹងស្វែងរកពន្ធកស្ងួនទួនបុប្ផា
សូមឲ្យបានប្រាណនៃបទិត្យជិតធីតា
ត្រេកតណ្ហាសេយ្យា(១)ខានយ៉ាងនោះឯង ។
បើព្រមព្រមមូលមិត្រស្និទ្ធស្នេហ៍ស្នង
សមបំណងបងប្រាថ្នាណាចិតែពួង
រៀមអរពេកត្រេកត្រអាលអស់កាលវែង
ផុតចំបែងវែងជាសុខស្រណុកក្រៃ ។
ដូចព្រះពុទ្ធផុតកិលេសវិសេសសាល

១- ដំណេក ។

ទ្រង់ត្រាស់ក្រសាលក្បាននិងញាណញៀប
ឥតមានទុក្ខក្រប្រជ្រៀតបៀតព្រះទ័យ
លែងមានភ័យវិភ័យជំនះឈ្នះឥតសល់ ។
ប្រសិនណាជាកោសិយសិរីវុទ្ធ(១)
ឲ្យពរពិតគិតសម្រាំងតាំងតម្កល់
បើកឲ្យបងប៉ងទីមនួនសួនទិមល
បងលែងទល់អំពល់ចិត្តគិតទុក្ខា ។
ហៃកល្យាណមានរូបឆោមលោមព័ណ៌ឆើត
ពង់ពៅស្ងួតកើតជាស្រីស៊ីថា
រៀមសូមខុនលំទោនកាយថ្វាយវន្ទា
ដល់បិតាប៉ាអនុជត្រលុបលេន ។
ដែលឱបមាដួបទុក្ខាមានផ្កាស
ក្រអូបល្អជំគាប់ចិត្តឥតគិតគន់
ពួកអ្នកផងបងគម្រេកត្រេកពេកពន់
ណាល្អកល្អន់សម្ងួសម្រុទន់ទ្រលន់អើយ ? ។

កុជក្តីលីលា

កាលបើគន្ធព្វឆើតឆាយ ច្រៀងដោយវែបខាយ យ៉ាងនេះចប់

---

១-ព្រះឥន្ទ ។

ហើយ ៗ សូរ្យាធីតាត្រាណាត្រើយ នាងពុំកន្ដើយ ព្រងើយដូចមុន ៗ
បែរជាស្រឡាញ់ស៊ប់ស៊ុន ចំពោះរូបឃុន ក្នុងទេពគន្ធព្វ ៗ ដួងចិត្ត
នៃនាងញ័រញាប់ ស្រពោនស្រពាប់ ដោយកាមរាគា ៗ រឹបនាង
ញញឹមកំព្រា ញាក់ញ៉ាក់ឆ្លើយថា ហៃបងជំនិត ៗ អ្នកបងចេះច្រៀង
ពេកពិត លួងលោមដួងចិត្ត នៃប្អូនពិសី ៗ ចេះក្រងកែវចងសម្ដី
ចម្រៀងបែបថ្មី ប្រកបតម្រូវ ៗ ព្រះពុទ្ធព្រះធម៌ជាផ្លូវ ព្រះសង្ឃត្រឹម
ត្រូវ តម្រូវលាយកាម ៗ ទាល់តែប្អូនស្រីដោយតាម ធ្លាក់ចិត្តចុះស្នាម
កិលេសតណ្ហា ៗ នុះនុអ្នកបងថ្លៃថ្លា ព្រះពុទ្ធនោះណា មិនដែលចួប
កំព្រា ៗ កាលខ្ញុំទៅលេងរួមរ័ក កំពូងសំណាក់ ពេងសុធម្មា ៗ ពួក
គេសរសើរពល់គ្នា ថាព្រះភគវ ប្រសើរបំផុត ៗ ជាប្រាជ្ញអង់អាច
ចំហុត ព្រះកាយបរិសុទ្ធ បញ្ចោញរស្មី ៗ ហៃបងប៉ុនក្រងសម្ដី
ដូចេះប្អូនស្រី ឥតបីប្រកែក ៗ ប្អូនមិនបាច់គិតភរវែក ចូរប្រុសល្អឯក
ចួបគ្នាថ្ងៃនេះ ៗ គន្ធព្វមានក័ព្វថាអេះ អើហ្នឹងហៅចេះ ស្ដាប់សូរចម្រៀង ៗ
បំណងដែលបងប៉ងទៀង គិតឥតឃ្លាតឃ្លៀង ត្រង់ហ្នឹងហើយពៅ ៗ
ថាហើយញញឹមចូលទៅ អែបនែបនិត្យនៅ ក្បែរពៅសូរ្យា ៗ
ទុនទបក្រេបបពីតា ព្រឺព្រួចកាត្មា ហាក់ដូចក្រឡាប់ ៗ សម្ផស្ស
ប្រុសស្រីចំណាប់ តែប៉ះពាល់ប៉ុប្ប៉ ក្រឡាប់ក្អកវិល ៗ ក្អកក្អេទៅជា
ក្អកព្រឹល ម៉ៀងមើលវមិល មិនច្បាស់ទេណា ៗ ចំណង់បើសម្ផស្សថា

នៃពួកទេព្តា យ៉ាងណាទៅអេះ ៗ ណ្ហើយចុះខ្ញុំសូមឈប់ស្ទះ បញ្ចប់
ត្រឹមនេះ អស់អាថ៌សេចក្តី ៗ ខ្ញុំទើបនឹងរៀនតែងថ្មី សូមពួកកវី
កុំបួញបាញមាត់ ៗ បើឃើញមានខុសក្បាំងក្បាត់ សូមជួយផ្ទៀងផ្ទាត់
តម្រង់ឲ្យបាន ៗ មួយទៀតខ្ញុំធ្វើប៉ះពាន ទៅលើពាក្យគ្មាន នៅក្នុង
ព្រះសូត្រ ៗ លើសខ្វះតិចតួចព្រោះប្រួត កាត់លៃសម្រួត សម្រួល
ឃ្លាកាព្យ ៗ សូមកុំឲ្យខ្ញុំមានបាប អាក្រក់ស្អុះស្អាប ជាប់ដល់អបាយ ៗ
ព្រោះខ្ញុំឥតមានក្បួនក្បាយ រៀនតែងបរិយាយ ដោយចិត្តជ្រះថ្លា ៗ
សន្មតថាចប់កាព្យា ប៉ុណ្ណេះឯងណា និដ្ឋិតាចប់ហោង ៗ

ញ៉ុង - សៀង

"ចំឡងចេញពីទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៤៣-លេខ-៥"

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង-ខាត់ រៀបរៀង*

អភិសំស្តុ ធាតុ សរសើរក្រៃលែង ស្ងួត្រសរសើរ ។

អភិសំស្ថា ធាតុ តាំងនៅ ឋិតនៅ ។ -ស្ថិត គុ. ដែលឋិតនៅ ។

អភិសំស្ប្ឫឝ ធាតុ ងូតទឹក ។ ដកយក ។

អភិសំស្ប្ឫ ធាតុ ទឹកដល់ គិតដល់ ។

អភិសំហិត គុ. ដែលប្រយុទ្ធ ។

អភិសំហិត គុ. ដែលទទួលស្គាល់ ។ ដែលទាក់ទង ។

អភិសំកល្ប បុំ. អភិសំកល្ប សេចក្តីប្រាថ្នា ។

អភិសំក្រុទ្ធ គុ. ដែលក្រេវក្រោធ ។

អភិសំក្រុឝ ធាតុ ស្រែកហៅ ។

អភិសំក្សិប ធាតុ បង្រួម ។ - ក្សិប្ត គុ. ដែលបង្រួម ដែលធ្វើ
ឲ្យតូច ។

អភិសំខ្យា ធាតុ រៀបរាប់ ។

អភិសំខ្យា ស្ត្រី. អភិសំខ្យា ចំនួន ។

អភិសំខ្យេយ គុ. ដែលគួររាប់ ។

អភិសំគម៑ ធាតុ ទៅជួប គោរពរួមគ្នា ។ -គត គុ. ដែលជួបជុំគ្នា។

អភិសំគុប្ត គុ. ដែលគ្រប់គ្រងប្រពៃ ដែលការពារមាំ ។

អភិសំជ្រិត គុ. ដែលតែងតាំង ដែលហោរ:ក ។

អភិសំជ្វរ៑ ធាតុ ព្រួយបារម្ភ ច្រណែន ។

អភិសត្ក្ឫ ធាតុ ធ្វើបដិសណ្ឋារ ។ -សត្ក្ឫត គុ. ដែលប្រកប
ដោយកិត្តិយស ។

អភិសំតប្ត គុ. ដែលក្តៅក្រៃលែង ។

អភិសំត្យជ៑ ធាតុ បោះបង់ចោល ។

អភិសំត្រស្ត គុ. ដែលតក់ស្លុតក្រៃលែង ។

អភិសំទេហ ន៉ុ. អភិសំទេហ អង្គជាតិ ។

អភិសំធក គុ. ដែលកុហក ។

អភិសំធា ធាតុ ដាក់សរ(លើធ្នូ) តម្រង់ ។ តិតផល់ ។ ព្រមព្រៀង

គ្រួបទៅលើ បំភ័ន្ត ។ -ធាយ គុ. ដែលដាប់ ។

-ធិត គុ. ដែលផ្សំគ្នា ដែលប្រកប ។

អភិសំធា ស្ត្រី. អភិសំធា កិរិយាពោលអះអាង សម្ដី ។

អភិសំធាន ន៉ុ. អភិសំធាន កិរិយាជាប់ កិរិយាទាក់ទង សម្ដី

កិរិយាបញ្ឆោត ។

អភិសំធិ ស្ត្រី. អភិសន្ធិ សេចក្ដីប្រាថ្នា បំណង ។ សេចក្ដីព្រម-

ព្រៀង សន្ធិសញ្ញា ។

អភិសំធីន គុ. ដែលបញ្ឆោត ។

អភិសន្ធ គុ. ដែលប្រកបដោយបរិក្ខារ ។

អភិសិន៍ ធាតុ នាំទៅ ។

អភិសមាគម៍ ធាតុ មកចំ ។

អភិសមាបទ៑ ធាតុ ធ្លាក់ទៅក្នុង ។

អភិសមាយា ធាតុ ចូលទៅព្រមគ្នា ។

អភិសមាយុត្ត គុ. ដែលប្រកបដោយ ។ ដូចពាក្យ សមាហិត ។

អភិសមាវត្ត៑ ធាតុ ចូលមកវិញ ។

អភិសមីក្ស៑ ធាតុ មើល ។

អភិសមីរ៑ ធាតុ ធ្វើចលនា ។

អភិសមេ (តិ) ធាតុ ប្រជុំគ្នា ។ -សមេត គុ. ដែលប្រជុំគ្នា ។

អភិសំបត៑ ធាតុ ប្រញាប់ ស្រូតរូត ។

អភិសំបទ៑ ធាតុ មកដល់ បានសម្រេច ។ -បន្ន គុ. ដែលបានដល់ ឬ បានសម្រេច ។

អភិសំបូជ៑ ធាតុ គោរពបូជា ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង៉ូ-កាង

ប្រែ-រៀបរៀង

(៣)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នករាល់វៃឆ្លាសបើបានអាន |
| នឹងចេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

ឯខុងបេង ក៏តាំងទ័ពនៅក្នុងស្រុកងិនថែ ទើបឲ្យទាហានទៅស៊ើបដំណើរកងការមើលថា បេងហេកទីងទៅតាំងនៅដំបន់ឯណា, ទាហានល្បាតវិលមកជម្រាបថា ៖ បេងហេកទៅបាំលុតតតកុត ទៅហួយស្រុកអកោកុក លើកទាហានទៅតាំងនៅត្បូងព្រាំងស៊ីងតោហ្គូស៊ុយ ជាច្រើនណាស់, ខុងបេងបានឮដូច្នោះ ក៏ចាត់ចែងទាហានលើកទៅដល់ស៊ីងតោហ្គូស៊ុយ ឃើញទាហានលុតតតកុតរូបរាងដាំថែបអ្នកលើ ហើយឃើញទឹកនោះគំហួរសង្ហែយ ក្រោមបែកចេញ ៗ ទើបឲ្យគេហៅពួកអ្នកស្រុកមកដណ្ដឹងសួរយកការ, អ្នកស្រុកឆ្លើយថា ទឹកក្នុងស៊ីងតោហ្គូស៊ុយនោះបើស្ទឹក [illegible] មនុស្សក្នុងប្រទេសផ្សេងៗ មិនដឹង [illegible] ក្នុងស្លាប់ក្នុងខណៈនោះ, បើអ្នកស្រុកអកោកុកឯង

ទៅផងដីក  ក៏ឲ្យគេគាស់ដីបញ្ញាទិងកម្លាំងច្រើនឡើង,  ខុងបេងឮដូប្ដោះ ក៏ភ័យណាស់  ចាត់អ៊ុយអៀនឲ្យតាំងបន្ទាយ  នៅក្បែរស្ទឹងនោះ ៗ ឯខ្លួន ខុងបេងថយទ័ពចេញទៅតាំងនៅឆ្ងាយប្រមាណ ២៥០ សិន (១០ គីឡូម៉ែត្រ) ហើយកំដាប់ទាហានទាំងពួងមិនឲ្យដងទឹកនោះផឹកសោះ  ៗ

ឯទៅអ៊ននិងគេហ៊ី  ឃើញខុងបេងទៅតាំងបន្ទាយនៅដូច្នោះ  ក៏លើកទាហានចូលទៅត្រើយម្ខាង  ដើម្បីច្បាំងយកបន្ទាយអ៊ុយអៀន ៗ ក៏លើកចេញទៅតាំងនៅក្រៅបន្ទាយ  លុះទៅអ៊ននិងគេហ៊ី  លើកទ័ពទៅដល់  ក៏ដេញទាហានឲ្យចុះតច្បាំងជាពន្លឹក,  អ៊ុយអៀនឃើញទាហានពុតគ័តកុតភាជយាំងគង់ធន់ដល់អាវុធទាំងពួង ក៏សាយទ័ពវិលទៅបន្ទាយខុងបេង,  ទៅអ៊ននិងគេហ៊ី  ក៏លើកទាហានចូលត្រឡប់មកបន្ទាយ,  អ៊ុយអៀនឲ្យទាហានតាមទៅល្បាតស៊ើបយកការ  ឃើញទាហានពុតគ័តកុតគ្មានផែនទិងទូក  ដើរលើក្រោះធ្ងន់ទឹកទៅបាន  ក៏យកសេចក្ដីទៅជម្រាបខុងបេងគ្រប់ប្រការ  ៗ

ខុងបេងបានស្ដាប់ ក៏ឲ្យទឹកសង្ស័យ  ទើបហៅលិគីមកសួរថា ហេតុផលទាំងនេះ តើទីងជាប្រការម្ដេច ? លិគីថា  ឯទាហានតីទក:ប៉េងពួកនេះមានកម្លាំងពលំ ពាក់ក្រោះផ្ដៅត្រាំប្រេងគង់ធន់ដល់អាវុធគ្រប់ៗគ្នា, ឯយើងទីងច្បាំងយកជ័យជម្នះពានោះ  ឃើញពិបាកណាស់  សូមឲ្យមហាឧបរាជត្រឡប់ទៅស្រុកសេឈួនវិញសិនចុះ,  បេងហោកកិអន់តប្រើរះគិតប៉ុណ្ណឹង

ហើយ មុខជាមិនអាចនឹងតាមយើងបានទេ ។ ខុនបេនរស់សំណើច ហើយថា យើងបានធ្វើការប្រលហួសមកដល់ត្រឹមនេះហើយ នឹងលើកទ័ពថយត្រឡប់វិលទៅវិញ មិនត្រូវសោះ, ពេលព្រឹកនេះ យើងនឹងគិតកលឧបាយយកជ័យជម្នះឲ្យបាន, ហើយខុនបេនក៏ចាត់ចែងឲ្យជូឡុងនិងអ៊ុយអៀននៅក្រោយបន្ទាយ ។

លុះដល់ពេលព្រឹក ខុនបេនក៏ឡើងជិះរទេះតូច នាំទាហានសិទ្ធនិងពួកអ្នកស្រុក លើកទៅតាមឆ្នេរស្ទឹងទិសឯជើង, លុះដល់ជើងភ្នំ ខុនបេនក៏ចុះពីលើរទេះ ដើរទៅដល់ភ្នំធំមួយអន្ទើ កំពូលភ្នំនោះ ជាទីវាលមានសណ្ឋានដូចរូបពស់ ស្មើរាប គ្មានដើមឈើ, ក្បែរវាលនោះ មានកំពែងថ្មជាម្ធនមាំ ហើយមានផ្ទះធំ ១, ខុនបេនក៏សួរថា ទីនេះ ឈ្មោះអ្វី ? អ្នកស្រុកឆ្លើយជម្រាបថា ឈ្មោះចូប៉ូសុក គឺទួលពស់លូន, ផ្លូវធំដែលចុះទៅនោះ ត្រង់ទៅលើស្រុកសាំកាំង, ខុនបេនឮដូច្នោះ ក៏មានអំណរណាស់ថា ការយើងគ្រានេះ មុខជានឹងសម្រេចប្រាកដ, ហើយក៏ចុះពីលើកំពូលភ្នំ ទៅឡើងរទេះតូច វិលមកបន្ទាយវិញ, ខុនបេនបង្គាប់ម៉ាតាយឲ្យយករទេះ ១១ ដែលផ្ទុកខ្ទូធ្វើត្រៀមទុកពីស្រុកមក ។ បើកឡើង, ក្នុងទូនោះ ដាក់ឡេតឈើ ១.១០០, ក្នុងឡេតនោះ ដាក់ផារដែកទីងគ្រាប់ជាច្រើន, ខុនបេន ក៏បង្គាប់ម៉ាតាយថា អ្នកឯង ត្រូវនាំទាហានឲ្យយករទេះ១០នេះ ទៅបង្កប់នៅក្បែរទួលចូប៉ូសុក ត្រៀមការទុកឲ្យព្រមគ្នា

១៥ ថ្ងៃ ។ ម៉ាតាយទទួលប្រសាសន៍ហើយក៏លាខុនបេនទៅ, ខុនបេនក៏ឲ្យជួឡុងនាំទាហានទៅតាំងស្កាត់ នៅក្បែរមាត់ផ្លូវ . ដែលទឹងទៅស្រុកសាំកាំង ឲ្យត្រៀមការទុកព្រមស្រេច, ជួឡុងក៏លើកទាហានទៅ, ខុនបេនឲ្យអ៊ុយអៀនទៅនៅបន្ទាយក្បែរមាត់ស្ទឹង ជោហ្វស៊ុយ ហើយបង្គាប់ថា បើទាហានលុតត័តកុតលើកមកច្បាំង ក៏ឲ្យធ្វើជាបែកថយរត់ បញ្ឆោតឲ្យដេញតាមទៅដល់ទួលចប៉ូសុក, បើឃើញទង់សដោតនៅត្រង់ណាឲ្យចូលទៅឈប់នៅត្រង់នោះ ៗ អ៊ុយអៀនបានស្តាប់មិនបានដឹងក្នុងកលឧបាយខុនបេន ក៏គិតតូចចិត្តថា ខុនបេនក្លែងឲ្យខ្ញុំបានទទួលសេចក្តីអាប់យសដល់សត្រូវខ្មាំង តែគិតខ្លាចអាជ្ញាខ្មាំង ក៏មិនអាចតប្រកែកស្ដេចក៏លើកពលទៅតាំងនៅតាមបង្គាប់, ខុនបេន ក៏ឲ្យកៀវសេកទិនតៀវងីម៉ាតង នាំទាហានដែលបញ្ចុះបញ្ចូលបាន ២.០០០ នោះ ទៅតាំងបន្ទាយ ៧ កាយគ្នានៅតាមឆ្នេរស្ទឹងចប៉ូសុក ឲ្យដោតទង់សទុកជាសម្គាល់ ។

ឯបេនហោក កាលលើកទ័ពមកដល់ជោហ្វស៊ុយ ឃើញកងទ័ពទៅតាំងនៅផ្លូវនោះ ក៏និយាយនឹងលុតត័តកុតថា ខុនបេននេះ ជាមនុស្សមានសតិបញ្ញាខាងធ្វើកលឧបាយល្បួងបញ្ឆោតផ្សេង ៗ, យើងធ្វើសឹកនឹងខុន-បេននោះ ត្រូវតែកំជាប់ទាហានទាំងពួងជាមុនឲ្យហើយ ថាបើច្បាំងនឹងខុនបេនទៅដល់ជាយព្រៃ មិនដើរក្នុងទីសំខាន់ ព្រោះបើនឹងបានចំណាប់យ៉ាងណា ក៏កុំឲ្យដេញជិតតាម, លុតត័តកុតថា អ្នកកុំបីព្រួយបារម្ភ, ឯភ្លូក

ស្រុកសេឈួនដែលមានកលឧបាយច្រើនយ៉ាងណា  យើងក៏អាចដឹងការបានទាំងអស់, យើងនឹងនាំទាហានកងមុខលើកចូលទៅមុន  សម្លាប់ខុងបេងឲ្យបាន, ខ្លួនអ្នកចូរនាំទាហានការពារនៅជាក្រោយចុះ, ហើយលុតតតកុត  ក៏លើកទាហានឆ្លងត្រើយទៅច្បាំងនឹងទ័ពអ៊ុយអៀន ។ ក៏លើកទាហានចេញតនឹងលុតតតកុតបាន ៩ ក្បួន,  អ៊ុយអៀនធ្វើជាចាញ់ដោះបោលបន្ទាយ  បំផាយសេះរត់ទៅ, លុតតតកុតក៏លើកទ័ពឆ្លងត្រឡប់មកបន្ទាយវិញ,  អ៊ុយអៀនក៏វិលចូលបន្ទាយវិញដែរ  ។

លុះព្រឹកឡើង  ថ្ងៃ ១  លុតតតកុត  ក៏លើកទ័ពឆ្លងទៅច្បាំងទៀត, អ៊ុយអៀនចេញច្បាំងបាន ៧ ក្បួនធ្វើជាចាញ់ទាញសេះរត់,  លុតតតកុតឲ្យទាហានដេញតាមទៅឆ្ងាយប្រមាណ ៨០ សិន (៣២០០ម៉ែត្រ) ឃើញឃើងស្ងាត់គ្មានមនុស្សម្នាចេញមកតច្បាំង  ក៏ត្រឡប់មកប្រាប់លុតតតកុតគ្រប់ប្រការ,  លុតតតកុត  បានស្ដាប់  ក៏បបួលទាហានកងធំ  លើកតាមទៅ, អ៊ុយអៀនឃើញលុតតតកុតដេញតាមជិតនឹងទាន់ ក៏ឲ្យទាហានដោះបោល  រត់ចូលទៅក្នុងបន្ទាយទង់ស,  លុតតតកុតឃើញដូច្នោះ  ក៏មានចិត្តកំរើបលើកទាហានតាមទៅដល់បន្ទាយអ៊ុយអៀន ។ ក៏ចេញច្បាំងនឹងលុតតតកុតបាន ៣ ក្បួន  ហើយដោះបោលបន្ទាយ  បំផាយសេះរត់ទៅចូលទៅក្នុងបន្ទាយទង់សទី ២, លុតតតកុតក៏លើកទាហានដេញតាមទៅ, អ៊ុយអៀនចេញច្បាំងបាន ៣ ក្បួន  បំផាយសេះរត់ទៅទៀត តែអ៊ុយអៀន

បានចេញតដៃទឹងលុតត័តកុត ហើយធ្វើជាបាញ់ដល់ ១៥ គ្រា ពោល បន្ទាយ ៧ អន្ទើ, លុតត័តកុតរឹតតែមានចិត្តកំរើប បំផាយសេះដេញហួស ទៅមុខពាហានខ្លួបត្រឡប់វិលមកវិញប្រាប់ថា ក្នុងព្រៃនោះ មានពាហាន ពួនបង្កប់ដោតទង់ទុកជាច្រើន, ចេងហោកបានឮដូច្នោះ ក៏អស់សំណើច ហើយថា ឯខ្លួនចេងនោះពូកែតែខាងកលឧបាយ, បើទឹងច្បាំងគ្នាដោយ កម្លាំងថ្វីដៃក៏ស៊ូទឹងយើងមិនបានទេ, យើងធ្វើសឹកគ្រានេះ មានជ័យជម្នះ ១៥ គ្រា បានបន្ទាយ ៧ អន្ទើ, ពាហានខ្លួនចេងសឹងតែខ្ទេចយើងណាស់ ហើយ, យើងត្រូវបង្អង់ចាំស្តាប់ខ្លួនចេងមើលសិន, មុខជាខ្លួនចេងទឹងបាញ់ ប្រៀបយើងជាប្រាកដ, លុតត័តកុតក៏យល់ឃើញផង ទើបបោះទ័ពនៅទី នេះ ១ យប់ ។

លុះព្រឹកឡើង អ៊ុយគៀន ក៏លើកពាហានចេញច្បាំងបញ្ឆោតលុតត័តកុតទៀត, លុតត័តកុតឲ្យចេងហោកនៅរក្សាបន្ទាយ, ឯខ្លួនឯងតែងខ្លួនពាក់ គ្រោះប្រដាប់ពេជ្រពាក់ផ្គាំ ជិះលើ-កជំរើបចេញមុខពាហាន អ៊ុយគៀនបាន ឃើញដូច្នោះ ក៏ស្រែកដេរលុតត័តកុតជាច្រើន ហើយបំផាយសេះរត់, លុត ត័តកុតឮហើយ ខឹងណាស់ ក្អែកក្រហមដូចភ្លើង ក៏បរដំរីដេញពាហានឲ្យ លើកតាមអ៊ុយគៀន ឃើញទង់សដោតនៅលើកំពូលភ្នំបង្គួសុក ក៏បំផាយ សេះរុកពានពានទៀងទៅ, លុតត័តកុតឡើងទៅដល់ ឃើញទ័ពនោះស្ងាប គ្មានមេ-ឈើជាទីកំបាំងដែលខ្លួនចេងទឹងបង្កប់ពាហានទុក ក៏ប្រមាទបន្តិច

នាំទាហានដេញតាមអ៊ុយអៀនទៅ, លុះទៅដល់ផ្លូវដែលម៉ាតាយបង្កប់ទាហាន ជួនពេលព្រលប់ លុតត័តកុតឃើញរទេះដែលម៉ាតង់យកទៅដាក់កណ្ដាលផ្លូវ សម្គាល់ថាខុងបេងបោលរទេះនោះចុះរត់ទៅហើយ ក៏បង្ខំលើកទាហានតាមទៅ ដល់ផ្លូវដែលដូឡ្យង់ជញ្ជូនថ្មសិលាទិងកាត់ឈើខ្ទប់ទុកនោះ លុតត័តកុតក៏មានអំណររណាស់ ឲ្យទាហានចូលទៅរញ្ជួនថ្មទិងឈើនោះជាច្រួលច្របល់ ប្រញាប់ទិងតាមខុងបេងទៅ, ដូឡ្យង់ក៏ឲ្យទាហានយកភ្លើងដុតឆេះឡើងសន្ធោសន្ធៅពេញផ្លូវព្រៃពីខាងក្រោយ, លុតត័តកុតឃើញភ្លើងឆេះស្ទាក់ផ្លូវ ក៏ភ័យរត់ទៅបណ្ដោយ, ម៉ាតាយក៏ឲ្យដុតភ្លើងគ្រប់ទេះ, ឈ្នួនក៏ឆាបឆេះព័ទ្ធជុំវិញ, ផាវដែកទោះមិញ ក៏ផ្ទុះបែកស្មើរទិងផ្កាយវៃហកក្នុំទិងព្រៃនៅទីនោះ ។

លុតត័តកុតឃើញភ្លើងឆេះព័ទ្ធជុំវិញដូច្នោះ មិនដឹងទិងធ្វើប្រការម្ដេច, ភ្លើងក៏ឆេះកលដូចគេវេច ឆេះចាប់ដល់គ្រោះទាហាន ពនជាលកលគ្រប់គ្នា, លុតត័តកុត ទិងពលយោធាទាំង ៣ មុឺន ក៏ស្លាប់នៅកណ្ដាលភ្លើងនោះទាំងអស់ ។

ខុងបេងឡើងឈរនៅលើកំពូលភ្នំ ក្រឡេកឃើញលុតត័តកុតទិងពលជាប់កណ្ដាលចំណោមភ្លើង ត្រូវទិងផាវដែកដាក់ត្រាប់បែក ផ្កាយលាទត្ថ សន្ធឹកគគ្រឹកគគ្រែង ត្រូវស្លាប់ពលលើងឆេះទាំងអស់ ខ្លះនៅរស់ដាច់ដៃដាច់ជើងខ្ទាក់ក្នុងបែកលលាដ៍ក្បាល បណ្ដាលឲ្យមានក្លិនអសោចនៃខ្មោច

អស្រុកអប់សព្វទិសទី, ខុនបេងក៏បង្កើតព្រឺព្រួចក្នុងឥន្ទ្រិយជាទីសង្វេគ មាន ទឹកភ្នែកនោះហូរស្រក់ចាក់ចុះមកដោយករុណាក្នុងធម្មចិត្ត អាណិតមនុស្ស ដែលស្លាប់ គិតឃើញនាប់ថា ខ្លួនអញធ្វើការគ្រានេះ តើនឹងបានសេចក្ដី គាប់ប្រសើរយ៉ាងណា រីអាយុនៃអាត្មាក៏នឹងខ្ចុះអស់ត្រឹមនេះឯង ព្រោះ កម្មស្ដែងដែលធ្វើឲ្យជីវិតគេវិនាសច្រើនណាស់មកហើយ, ឯអស់ពួកទា-ហានទាំងប៉ុន្មាន ក៏សឹងមានសេចក្ដីសំវេគអាណិតអនាថគ្រប់ៗគ្នា ។

ខណៈភ្លើងឆេះលុតត័តកុតនិងពលយោធា នៅទីនោះ ខុនបេងឲ្យ តៀវងីនាំទាហាន ១ ៤០០ ធ្វើកលជារត់ប្រាក់ទ័ពទៅរកបេងហោកឯបន្ទាយ ហើយឲ្យប្រាប់ថា ឥឡូវ លុតត័តកុតព័ទ្ធខុនបេងជាប់ក្នុងបំណោមហើយ, អស់យើងទាំងឡាយឃើញថា សេចក្ដីស្លាប់នឹងមានមកដល់ខ្លួន បានជានាំ គ្នារត់មកពឹងលោក, សូមឲ្យលោក ប្រញាប់លើកទ័ពណ្ហូនឡើងទៅព្រួត ទៀត, កាលតៀវងីលើកទៅដល់ ហើយបាននិយាយការដូច្នោះ, បេង-ហោកក៏សម្គាល់ថាមែន ទើបលើកទាហានឡើងទៅ ទាំងពេលកណ្ដាល យប់, លុះទៅដល់ជើងភ្នំ ឃើញភ្លើងឆេះភ្លឺរុងរឿង ហើយផ្ទុំក្លិនស្អុយ អស្រុកខ្មោចឥសោចខ្លាំងណាស់, បេងហោកនឹកភ័យ គិតត្រឡប់ចុះមកវិញ, ម៉ាតងនិងតៀវងីក៏ដេញទាហានឲ្យចូលប្រកាប់ប្រសព្វគ្នាចូលទៅ, បេង-ហោកស្រែកដោយសំឡេងខ្លាំង, ទាហានទាំងពួង ក៏រត់ច្រួលច្របល់ចូល បន្ទំជាទាហានខុនបេងទាំងអស់, បេងហោកក៏បំផាយសេះស្ទុះបំពារទ័ពរត់

ទៅដល់ច្រកភ្នំមួយ អង្វើ ប្រទះនឹងខុងបេងឡើងជិះរទេះតូចនាំទាហានមក ស្កាត់ពីមុខ, ខុងបេងក៏ស្រែកដោយសំឡេងខ្លាំងថា អាហោរក្សត់! អាឯង រត់ទៅណា? ប៊ុងហោកភ័យណាស់ញាក់សេះរត់ ទទួលមាតាយលើកទា- ហានស្កាត់ផ្លូវពីមុខពីអាង ព័ទ្ធជុំវិញ ក៏ចាប់ខ្លួនបេងហោកបាន ហើយនាំ បណ្ដើរទៅជូនខុងបេង ។

ឯខុងបេង លុះបេងហោករត់ទៅហើយ ក៏ឲ្យអង់ប៉េង និងគៀវអេក នាំទាហានស្រួចទៅវាយបន្ទាយបេងហោក ឯប៉ូងដោហ្វស៊ុយ ចាប់បាន ខ្លួនអាងចុកយ៉ុងនិងស្ម័គ្របក្ខពួកទាំងអស់, ខុងបេងក៏នាំកងទ័ពត្រឡប់មក បន្ទាយវិញ ហើយនិយាយនឹងទាហានទាំងពួងថា យើងគិតកលឧបាយ ធ្វើសឹកមានជ័យជម្នះស្រួលណាស់ សូម្បីតែកូនទាហានម្នាក់ ក៏មិនបាន ខូចសោះ, កាលលុតត័តកុតដេញអ៊ុយអៀនទៅដល់ជាយភ្នំ នោះយើង ក៏បានយកតែទង់ជ័យទៅដោតបញ្ឆោតទុកក្នុងព្រៃ, ក៏សម្គាល់ថា ទាហាន តាំងនៅក្នុងទីនោះច្រើនណាស់ បានជាមិនអាចនឹងលើកតាមទៅ ត្រឡប់ ដេញអ៊ុយអៀនឡើងទៅលើភ្នំវិញ, បានជាយើងឲ្យម៉ាតាយយករទេះដែល ផ្ទុកដីនោះនោះ ទៅដាក់បោលកណ្ដាលផ្លូវ ហើយយើងឲ្យយកដាវដែក ដាក់ក្រាប់បែកកប់ក្នុងដីបន្ទាឈ្នួសសម្រាប់អុជគ្រាប់កន្ទ្វង, លុតត័តកុតទ្រើស ទ្រូងដំអង់អាចមិនខ្លាចគំនិត " គិតមិនដល់ក៏ចាញ់កលយើង ហើយលុត- ត័តកុតវង្វេងទៅបោះបន្ទាយនៅឆ្នេរស្ទឹងដោហ្វស៊ុយ ខឹងបញ្ឆោតយើងឲ្យ

ស្លាប់ដោយទឹកមានពិសពុល, យើងគិតយល់ថា ទាហានលុតត័តកុតពាក់អាវក្រោះផ្ដៅជ្រលក់ប្រេង បានជាយើងយកភ្លើងការតបពិសទៅវិញខ្លះ ៗ គេក៏ចាញ់តបះយើងវិញ, ទាហានលុតត័តកុតនោះមិញ ណាដែលមានថ្វីដៃខ្លាំងពូកែណាស់ ក៏ក្រឡះស្លាប់នៅក្នុងភ្លើងនោះអស់ទៅហើយ, យើងគិតអនុគ្រោះ គួរឲ្យសង្វេគអាណិតពន់ប្រមាណ, តេជះផលដែលយើងបានតាំងចិត្តធ្វើកដការ ដោយថ្វងព្រះតេជព្រះគុណអម្ចាស់លើសិរសា ដោយចេតនាសុចរិត សូមកុំឲ្យមានវេរាបាបជិតតទៅឡើយ ។

អស់ពលទាហានទាំងពួងបានឮហើយ ក៏នាំគ្នាខុចគំនាប់ដោយគោរពហើយថា ឯគំនិតប្រាជ្ញាមហាឧបកជនោះ ជ្រាលជ្រៅពន្លឹកណាស់ កុំថាតែមនុស្សដើរលើដី សូម្បីទេពារក្ស ដ៏មានរិទ្ធិសិទ្ធិសក្ដិហើរហោះបាន ក៏ទិនប្រមាណការសញ្ញាចិត្ត គិតមិនដល់យល់តម្រិះ របស់មហាឧបកជបានឡើយ ។

ខណៈនោះ ទទួលម៉ាតាយនូវអស់ទាហាននាំបេងហោកទាំងចំណងចូលមក ព្រមទាំងបេងហ៊ុវ តួខ្លៃ និងនាងចុកយ៉ុង, ខុងបេង ក៏ឲ្យស្រាយចំណងចេញទាំងអស់, បេងហោក ក៏ក្រាបចុះគំនាប់តាមសភាព, ខុងបេងក៏ឲ្យបេងហោក បេងហ៊ីវ តួខ្លៃ និងនាងចុកយ៉ុង ចេញទៅអង្គុយពីចម្ងាយហើយឲ្យទាហានរៀបតុលៀងអាហារស្រាបាយ ឲ្យអ្នកអស់ទាំងនេះបរិភោគ ។

ខណៈនោះ កាលឈ្មោះតាំង ៤ នាក់ ផឹកសុរាទៅទើនោះ, ខុនបែនក៏ប្រើទាហានម្នាក់តែងកលទៅនិយាយនឹងបេងហេកថា ឥឡូវមហាឧបរាជនឹងឲ្យបើកលែងអស់លោកទៅវិញម្តងទៀត បើលោកនឹងចង់ផ្ញើសឹកតស៊ូនឹងមហាឧបរាជឲ្យឃើញថ្វីដៃយ៉ាងណា ក៏តាមចិត្ត យើងនឹងលែងឲ្យទៅបញ្ចុះបញ្ចូលទាហានលើកមកច្បាំង ឲ្យអស់ថ្វីដៃចុះ នឹងឃើញច្បាស់ជានរណាឈ្នះ នរណាចាញ់, បេងហេកឮដូច្នោះ ក៏នឹកអៀនខ្មាសក្នុងចិត្តណាស់ អង្គុយសម្រុកទឹកភ្នែកហើយថា ពីដើមមក ព្រោះមិនទាន់បានដឹងឃើញ, ការដែលផ្ញើសឹកនឹងគេ ១ ចាប់បានហើយលែងទៅវិញដល់ ៧ គ្រាដូច្នេះនេះ ហេតុពីព្រោះយើងជាមនុស្សផ្សេងប្រទេសគ្នាក៏មែន តែយើងក៏គង់ស្គាល់ខុសនិងត្រូវ មានសេចក្តីអៀនខ្មាសខ្លះដែរ, ខ្លួនយើងនឹងភរិយាទូវអស់ស្ត្រីបុត្រពួកតាំងប៉ុន្មាន មិនបានផ្ញើសង្គ្រាមតទៅទៀតទេ, សូមនាំគ្នាទៅក្រាបក្រោមបាទដើងមហាឧបរាជ សុំតែអាយុជីវិតទៅចុះទើបត្រូវ, ថាហើយ បេងហេកក៏នាំគ្នាចូលទៅសំពះខុនបែនដោយគោរព ហើយថា ខ្លួនខ្ញុំបាទបានធ្វើសេចក្តីខុសធ្ងន់នឹងមហាឧបរាជ ១ មានសេចក្តីករុណាទុកអាយុជីវិត បើកលែងទៅ ៦ គ្រាហើយ, សូមមហាឧបរាជអត់ទោសប្រោសប្រណីខ្ញុំបាទចុះ ព្រោះតាំងពីថ្ងៃនេះតទៅ ខ្ញុំបាទលែងគិតគំនិតវៀចអាក្រក់នឹងមហាឧបរាជទៀតហើយ ។

ខុនបែនសួរថា អ្នកឯង ព្រមចំណុះចុះចូលយើងហើយឬនៅ ?

បេងហោកឆ្លើយថា ខ្ញុំបាទសូមចំណុះចុះចាញ់មហាឧបកដតទៅហូត ដល់កូនដល់ចៅ, និយាយហើយក៏យំ, ខុនបេងក៏អញ្ជើញបេងហោកឲ្យឡើងអង្គុយលើកៅអីទឹមគ្នា ឲ្យបរិភោគអាហារសេពសុរា ហើយខុនបេងក៏តាំងឲ្យបេងហោកនៅជាចៅហ្វាយស្រុកដូចដើម, ឯបណ្ដាអាណាខែត្រនិងពលទាហាន ដែលចំណុះចុះចូលទៅនឹងខុនបេងតាំងប៉ុន្មាន ក៏បង្វិលឲ្យបេងហោកវិញទាំងអស់ ៗ បីហុយ (នាយទាហាន) និយាយនឹងខុនបេងថា មហាឧបកដមកធ្វើការគ្រោះនេះ ក៏លំបាកពលទាហានណាស់, ឥឡូវបេងហោកស្ម័គ្រចំណុះចុះចូលហើយ ដែលមហាឧបកដនឹងលើកឲ្យបេងហោកនៅឈរក្សាខែត្រតែម្នាក់ឯងនោះ ខ្លាចក្រែងបេងហោកនឹងប្រែចិត្តក្រឡប់ឡើងវិញ យូរទៅឯមុខ នឹងបានសេចក្ដីព្រួយរំខាន, ហេតុនេះ សូមឲ្យមហាឧបកដតាំងពួកយើងពីនាយឲ្យនៅជួយត្រួតត្រាផង ៗ

ខុនបេងថា កូនស្រុកបេងហោកនេះ ខុសគេទគ្នានឹងស្រុកយើងឯនាយ ៣ ប្រការ គឺពួកអ្នកស្រុកអាយនេះ ស៊ីតែសាច់សត្វស្រស់ទៅជាអាហារប្រការ ១ ៗ យើងដែលលើកកងទ័ពមកនេះ គឺបានសម្លាប់បងប្អូនញាតិសន្ដានអ្នកស្រុកនេះអស់ច្រើនណាស់ មុខជាអ្នកស្រុកនេះ នឹងមានចិត្តគុំគួននិងសងសឹកពួកយើងវិញ ប្រការ ២ ៗ កូនស្រុកនេះ គ្មានច្បាប់សម្រាប់ប្រពៃណី ជាទីទំនុកបម្រុងឲ្យត្រង់តាមគន្លងធម៌ ដូចប្រទេសឯទៀតសោះ, បើនរណាប្រព្រឹត្តខុសល្មើសនឹងចិត្តចៅហ្វាយស្រុកហើយក៏ត្រូវសម្លាប់ចេញបាន ប្រការ ៣ ៗ

បើយើងនឹងឲ្យមន្ត្រីពីនាយ ហើយនិងទាហាន នៅកាន់កាប់គ្រង ឃើញថា ជាការលំបាកណាស់ គង់នឹងបានសេចក្តីក្តៅខាងជាក្រោយ, មួយទៀត បេងហេកក៏អស់តម្រិះប្រាជ្ញា គោត្រាចថ្វីដៃយើងណាស់ហើយ កាលណាឡើយនឹងហ៊ានគះម្រើកចិត្តគិតវៀចតទៅទៀត ។

បេងហេកនឹងសេនាប័ក្ខពួកទាំងអស់បានឮដូច្នោះ ក៏នាំគ្នានូវគំនាប់ ក្រាបសំពះខុងបេងដោយសេចក្តីខ្លាច ហើយក៏នាំគ្នាលាចេញទៅ, បណ្តាមហាជននៅក្នុងទីស្រុកនោះ ក៏សឹងនាំគ្នាសង់ជាសាលាទេពារក្ស ហើយឆ្លាក់ធ្វើជារូបខុងបេង ទុកជាទីសក្ការៈបូជា ចារឹកនាមថា ដូហ៊្វី ប្រែថា រូបអាពុកអ្នកស្រុក ទាំងអស់គ្នា ។

បេងហេក ក៏ចាត់ការរើសយកទ្រព្យមានតម្លៃ គឺចិញ្ចៀន កែវកង និងមាសប្រាក់ នាំយកមកជូនគំនាប់ខុងបេងជាច្រើន ហើយប្តេជ្ញាថា ខ្លួនខ្ញុំបានជាខ្ញុំមហាឧបរាជតទៅ បើមហាឧបរាជនឹងមានកិច្ចធុរៈអ្វីៗ ឲ្យតែកូនភាហានកាន់សំបុត្រមកដល់ខ្ញុំបាទចុះ, ខ្ញុំបាទនឹងទទួលប្រតិបត្តិ តាមប្រសាសន៍គ្រប់ប្រការ ។

ខុងបេងបានឮដូច្នោះ ក៏ឲ្យបំណាច់រង្វាន់ទាហានតាមសមគួរ ហើយក៏ចាត់គ្នាឲ្យអ៊ុយគៀនជាទ័ពមុខ, ឯខុងបេងលើកទាហានតាមទៅជាទ័ពហ្លួង លើកទៅស្រុកសេឈួន, បេងហេកនិងអស់អ្នកស្រុកក៏លើកគ្នាជូនដំណើរទៅ, លុះលើកទៅដល់ស្ទឹងឡូស៊ុយ, អ៊ុយគៀនក្រឡេកឃើញ

ព្រះខ្យល់បក់បោកអណ្តែតសឹងដុំថ្មចុះពីលើភ្នំ, ក្នុងស្ទឹងនោះ ចុះអន្លង់ដ៏ត បិទៈដោយពពក ទឹងរកផ្លូវប្រែកច្ចុងទៅក៏មិនរួច, ក៏យអៀនក៏ថយទ័ពត្រឡប់ មកជម្រាបខុនបេនវិញ, ខុនបេន ក៏បង្ខំលើកពលទៅដល់ស្ទឹងឡុកស៊ុយ ឃើញហេតុវិបរិតបម្លែកណាស់ ក៏សួរបេនហោកថា ហេតុផលប្រការម្តេច បានជាដូច្នេះ ? ។

បេនហោកជម្រាបថា ក្នុងទឹស្ទឹងនេះ មានបិសាចកាចសម្តែងរិទ្ធិ ពីដើមមកក៏ធ្លាប់មានដូច្នេះ, សូមឲ្យលោកយកក្បាលមនុស្ស ៤៩ និងសេះស ក្របីខ្មៅ មកសែនបួងសួង ទើបបាត់វិបរិតដូច្នេះ, ខុនបេនថា យើងធ្វើសឹកសង្គ្រាមនឹងគ្នា ទាល់តែស្រេចការ, ផែនដីក៏កបទាបតាមធម្មតាដូច្នេះហើយ, សូម្បីមនុស្សតែម្នាក់ ក៏មិនដែលស្លាប់ចំពោះដៃយើង, មកឥឡូវយើងដល់ទឹស្ទឹងនេះ ជិតនឹងចូលដែនវិញហើយ, នឹងឲ្យយើងត្រឡប់មកសម្លាប់ជីវិតមនុស្សនឹងសត្វនោះ មិនត្រូវសោះ, ខុនបេនក៏ចេញទៅឈរមើលពិគ្រោះនៅឆ្នេរស្ទឹងនោះ ឃើញព្យុះបក់បោកខ្លាំងណាស់ នឹងគិតឆ្លងទៅមិនរួច, ទើបឲ្យគេហៅអ្នកស្រុកមកសាកសួរ, អ្នកស្រុកឆ្លើយជម្រាបថា តាំងពីមហាឧប ជលើកឆ្លងស្ទឹងនេះ មកធ្វើសឹក ក៏មានកើតជាគដូច្នេះជាដរាបមកមិនដាច់ តែដល់ពេលព្រលប់ហើយហួសទៅជប់ភ្ជឺ ចេះតែឮសំឡេងបិសាចស្រែកយំទ្រហឹងអឹងកង, ឃើញរូបអណ្តើកជាប់ទៅតាមផ្សែងពពក, គ្មាននរណានឹងអាចឆ្លងទៅមកបាន, ខុនបេន

បានស្តាប់ ទើបថា ដែលកើតហេតុទាំងនេះ ក៏ព្រោះទោសខ្លួនយើងឯង កាលគ្រាយើងប្រើម៉ាតាយឲ្យនាំទាហាន ១.០០០ លើកទៅនោះ ទាហានទាំងនោះ ក៏ស្លាប់អស់នៅក្នុងស្ទឹងនេះ, ហើយកាលធ្វើសឹកនៅនោះ ទាហានបេងហេក ក៏ស្លាប់ក្នុងទីនេះជាច្រើន, បិសាចទាំងពួងចងពៀរពេក នឹងយើង ទើបបណ្តាលឲ្យឃើញដូច្នេះ, យើងគិតឃើញទាំងម្ល៉េះ ត្រូវរៀបធ្វើការសែនគំនាប់ឲ្យបាត់ទៅវិញឲ្យបាន, អ្នកស្រុកទាំងពួង បានស្តាប់ដូច្នោះ ក៏ប្រាប់សេចក្តីដល់ខុនបេង ដូចបេងហេកនិយាយគ្រប់ប្រការ, ខុនបេងក៏ថា អ្នកពល់គ្នាកុំព្រួយបារម្ភឡើយ, ការនេះ យើងនឹងរិះគិតធ្វើឯង ។

ខណៈនោះ ខុនបេងបង្គាប់ទាហានឲ្យសម្លាប់សេះសក្របីខ្មៅ ហើយឲ្យយកម្សៅមកសូនឲ្យជាលលាដក្បាល ៤៩ ដុំ, លុះពេលកណ្តាលយប់ ក៏ឲ្យលើកចេញទៅតាំងនៅឆ្នេរស្ទឹង, ខុនបេងក៏តែងខ្លួនស្លៀកពាក់ចេញទៅ អុជធៀនធូបនិងប្រទីប ៤៩ ហើយតែងជាសេចក្តីប្រកាសសូត្របួងសួង ឲ្យតៀវកតជាអ្នកសូត្រសេចក្តីថា គ្រានេះ ព្រះចៅឡាវសៀនគ្រងរាជសម្បត្តិបាន ៣ ឆ្នាំ (ព.ស.៧៦៩) មានព្រះតម្រាស់ត្រាស់ប្រើយើងជាឧបរាជឲ្យលើកទ័ពមកប្រាបប្រាមសត្រូវផ្សេងប្រទេស, យើងក៏តាំងចិត្តគិតធ្វើការថ្វាយខ្លួនព្រះតេជព្រះគុណ មិនបានគិតនឿយព្រួយលំបាក ទាល់តែបានសម្រេចការសង្គ្រាមមានជ័យជម្នះសត្រូវហើយ, ឯទាហានទាំងពួង ដែលមានចិត្តសត្យសុចរិត បានដិតដោយមកជាមួយនឹងយើង ក៏ទំនើងនឹង

តាំងចិត្តជួយទំនុកបម្រុងព្រះចៅឡើសៀនដូចគ្នា, វេលានេះ មិនទាន់ស្រេចការ, អ្នកទាំងអស់គ្នាក៏ក្ស័យជីវិតទៅខ្ទះ, ហេតុនេះ គួរអស់អ្នកទឹងជឹងច្បាស់ថាជាកម្មរបស់យើងហើយ មិនគួរឡើយនឹងមកចងចិត្តអាឃាតធ្វើអ្វីទៀត គួរតែនាំសាច់ញាតិមិត្រសម្លាញ់ទៅស្រុកវិញ ជាមួយនឹងយើងចុះ, ក្លួនចៅនៅឯណោះ នឹងបាននៃនព្រេនបូជាតាមទំនៀមបុណណ, យើងក៏នឹងបានក្រាបទូលព្រះចៅឡើសៀន ឲ្យទ្រង់ប្រោស ព្រះរាជទានបំណាច់រង្វាន់ឲ្យដល់សាច់សាលោហិតរបស់អស់អ្នក ឲ្យដល់ខ្នាត, ទោះទាំងទាហានរបង់ហេកទៀត ដែលបានមកក្ស័យក្នុងទីនេះ ក៏ចូរត្រិះរិះទំរែកសេចក្តីសុខទំនុកបម្រុងខ្លួនរបស់ខ្លួន កុំបីមកគុំគួនវិលវល់ ធ្វើឲ្យយើងព្រួយអំពល់តទៅទៀតឡើយ គួរហើយនឹងគិតដល់ព្រះចៅឡើសៀន ដែលគ្រងរាជសម្បត្តិជាបរមក្សត្រទ្រង់ធម៌ តមកពីបុណណពងប្រវេណី ហើយត្រូវឃើញដល់យើងជាទីមហាឧបការ ដែលមានសេចក្តីសត្យសប្បុរស, ចូរទទួលនូវរបស់ជាគ្រឿងពលីការ ដែលយើងបូជានេះ ហើយចូរវិលៈវៈទៅកាន់ឋានទីជាទីលំនៅ តាមគាប់អធ្យាស្រ័យចុះ ។ លុះសូត្រប្រកាសចប់ចុះវេលាណា ខុងបេង ក៏គុជក្រឡាស អុជធាវ វាយឈ្មោះ ហើយយំសោកសោឡោះគាល័យពួកទាហានដែលក្ស័យ តាមសេចក្តីសង្វេគចិត្តក្នុងគ្រានោះ ។

ឯពិសាចដែលជាទាហានខុងបេង ទីងទាហានរបង់ហេកដែលមកប្រជុំក្នុងទីនោះ ឃើញខុងបេងធ្វើពលីការបួងសួងហើយយំសោកដូច្នោះ ក៏

ស្រុះគ្នាយំអាណិតអនាថព្រួចហឹងអឹងកង, ឯព្យុះខ្យល់ ទឹករលកផង ក៏ស្ងប់ស្ងាត់បាត់អស់ទៅក្នុងខណៈនោះ, ខុនបេនឃើញដូច្នោះ ក៏បង្កើតចិត្តសោមនស្សត្រេកអរ ឲ្យទាហានយកគ្រឿងបែនទាំងអស់ បណ្តែតតាមទឹកទៅ, លុះវេលាព្រឹក ខុនបេនក៏ឲ្យវាយឃ្មោះគោះគងទូងកេរ លើកទាហានឆ្លងដលធី ទៅត្រើយម្ខាង រំលងចូលទៅដល់ស្រុកអេងធៀង ហើយចាត់ឲ្យលីឃីនៅឈររក្សាស្រុកនោះ រួចបង្គាប់បេនហេកថា អ្នកចូរនាំទាហានវិលទៅវិញចុះ, អំណើះតទៅ ត្រូវឲ្យអ្នកខំយកចិត្តទុកដាក់រក្សាសេចក្តីសុខ ឲ្យអ្នកស្រុកបានសេចក្តីសុខសម្រាន្ត ហើយត្រូវឲ្យយកចិត្តសេនាទាហាន ឲ្យកប់អានស្រឡាញ់ដោយស្មោះ កុំបីឲ្យមនុស្សទាំងអស់បានសេចក្តីក្តៅក្រហាយឡើយ ។ បេនហេក ទទួលឱវាទហើយ ក៏គំនាប់លាត្រឡប់ទៅខែត្រវិញ ។ ឯខុនបេននោះវិញ ក៏លើកទ័ពស្រូតរូតទៅដល់ស្រុកសេឈួន ។

ខណៈនោះ ព្រះចៅឡៅសៀន បានទ្រង់ជ្រាបថា ខុនបេនមានជ័យជម្នះហើយលើកទ័ពត្រឡប់មកដល់ ក៏ទ្រង់មានព្រះទ័យត្រេកសោមនស្សណាស់ ទ្រង់រថព្រះទីនាំងយាងរហ័សចេញទៅទទួលខុនបេន ដល់ក្រៅក្រុង ចម្ងាយផ្លូវ ៣០០ ស៊ិន (១២គីឡូម៉ែត្រ), លុះទតព្រះនេត្រឃើញខុន-បេនពីចម្ងាយ ក៏ស្តេចកែក្រោយចុះយានព្រះបាទទៅចាំនៅក្បែរផ្លូវ, ខុន-បេនជិះសេះតូចបរទៅ ក៏ក្រឡេកឃើញច្បាស់ ភ័យណាស់ ចុះពីលើសេះ

ចូលទៅក្រាបថ្វាយបង្គំ ហើយទូលថា ទូលព្រះបង្គំជាខ្ញុំ បានទៅធ្វើសឹក នឹងបេងហេកគ្រាខេះ ក៏មានជ័យជម្នះ ហើយបានប្រាបប្រាមសត្រូវតាមនិគមធំតូច បានកបទាបអស់ហើយ ដែលទូលព្រះបង្គំជាខ្ញុំទៅធ្វើការឲ្យយូរ ពុំបានឆាប់រហ័ស នាំឲ្យព្រះអង្គព្រួយព្រះទ័យទោមនស្ស ព្រោះកិច្ចរាជការនោះ ទោសកំហុសលើទូលព្រះបង្គំជាខ្ញុំទាំងប៉ុន្មាន សូមព្រះអង្គទ្រង់អនុញ្ញាត ឲ្យគង់ជាខ្ញុំព្រះរាជការតទៅ ។

ព្រះចៅឡៅសៀនទ្រង់ព្រះបណ្ដាប់ ក៏ចាប់ដៃខុងបេងឲ្យឡើងលើរទេះ ហើយព្រះអង្គក៏ទ្រង់រថព្រះទីនាំង ត្រឡប់ចូលព្រះបរមរាជវាំងវិញ ព្រះចៅឡៅសៀន ទ្រង់មានព្រះរាជហឫទ័យសោមនស្សប្រីតា ចាត់ឲ្យរៀបតុលៀងភោជនាហារក្នុងទីព្រះឋាន បានស្រេច ស្ដេចក៏ឲ្យអញ្ជើញខុងបេងមហាឧបរាជ និងសេនាទាហានទៅទទួលអាហារ ហើយទ្រង់ព្រះករុណាចែកបំណាច់រង្វាន់តាមគុណានុរូប ។ ខុងបេង ក៏យកគ្រឿងបណ្ណាការយ៉ាងល្អៗ សម្រាប់អាណាខេត្រដែលរាយបានទាំង ៣០១ ស្រុកនោះ នាំទៅក្រាបបង្គំទូលថ្វាយ ព្រះចៅឡៅសៀន ហើយក្រាបទូលឲ្យព្រះរាជទានបំណាច់រង្វាន់ ដល់ភរិយាបុត្រពួកពលទាហាន ដែលបានទៅស្លាប់ក្នុងសង្គ្រាម តាមគួរសមជាប្រើន, ទាហានទាំងប៉ុន្មាន ក៏មានសេចក្ដីត្រេកអរគ្រប់ៗគ្នា ខំតាំងចិត្តគិតធ្វើរាជការថ្វាយព្រះចៅ.ឡៅសៀន ដោយសុចរិតអស់ពីចិត្ត ។

ចប់ខ្សែ ៧០ ។

# សាមកុក ទី ៣១

តាំងពីព្រះចៅចូភី បានរាជសម្បត្តិ នាងគុយហេង (ព្រះស្នំ) ធ្វើកលឧបាយជាមួយនឹងតៀវថ្ង(ខន្ទី) កប់រូបព្រះចៅចូភីក្រោមក្រឡាបន្ទំនាងអៀនស៊ី (អគ្គមហេសី), ព្រះចៅចូភីលុះកល, សម្លាប់នាងអៀនស៊ីស្លាប់, រហូតដល់ខុងបេងវាយបានស្រុកឡាំអ័ន, អងបេងចាប់ខ្លួនហែហ្វូ-លិមបាន ។

---

ឯព្រះចៅចូភី ហ៊ូតេ តាំងពីមិនទាន់បានរាជសម្បត្តិ កើតបុត្រានឹងនាងអៀនស៊ី ឈ្មោះចូយ៉យ នាងអៀនស៊ីនោះ ដើមឡើយជាកូនប្រសាអ្ងួនសៀវ, កាលគ្រាចូចូ ទៅវាយបានស្រុកងៀបគុន, ចូភីក៏បាននាងនេះមកធ្វើជាភរិយា, លុះព្រះចៅចូភី បានរាជសម្បត្តិ ទើបលើកនាងអៀនស៊ីជាអគ្គមហេសីឯក, ក្រោយមក យកនាងគុយហេងជាបុត្រីគុយហ៊ុយធ្វើមហេសីខាងឆ្វេង, នាងនោះរូបល្អ, ព្រះចៅចូភីសព្វព្រះទ័យណាស់, គុយហ៊ុយជាបិតា គិតចង់ឲ្យបុត្រីអាត្មាបានធ្វើធំបណ្តាច់ ទើបចូលទៅគិតការសម្រេចនឹងតៀវថ្ងជាខន្ទី ។

តៀវថ្ងគិតថា កុំឲ្យគុយហ៊ុយព្រួយបារម្ភ ព្រោះឥឡូវនេះ ព្រះចៅចូភីទ្រង់ព្រះប្រឈួន សូមឲ្យអ្នកគិតកលឧបាយធ្វើរូបព្រះចៅចូភី ហើយសរសេរឆ្នាំ ខែ ថ្ងៃ ព្រះកំណើតជាប់ជាមួយនឹងរូបនោះ នាំយកទៅកប់ទុកក្រោមគ្រែបន្ទំនាងអៀនស៊ី, ខ្ញុំនឹងទៅចាប់ជីកយករូបនោះ ទៅថ្វាយព្រះចៅចូភី ៗ មុខជានឹងទ្រង់ព្រះពិរោធ ឲ្យសម្លាប់នាងអៀនស៊ីពុំខាន, បុត្រី

អ្នកគង់ទឹងបានជាធំបណ្ដាច់តែឯង, គុយហ៊ុយបានស្ដាប់ដូច្នោះ ក៏យល់ឃើញត្រូវ ទើបចេញទៅធ្វើរូបនោះ ហើយនាំទៅកប់ក្រោមព្រះដំណាក់, តៀវថូក៏ទៅស្ទាក់ចាប់យករូបនោះ ទៅថ្វាយព្រះចៅចូកី ។ មិនបានដឹងក្នុងកលឧបាយ ក៏ក្ដៅក្រហាយក្នុងព្រះទ័យ ចាប់ទោសអគ្គមហេសីថា ក្លែងធ្វើព្រះអង្គឲ្យទ្រង់អាពាធ ក៏ត្រាស់ប្រើពេជ្ឈឃាដ ឲ្យនាំនាងអៀនស៊ីទៅប្រហារជីវិតបង់, ហើយទ្រង់តាំងនាងគុយហោងជាអគ្គមហេសី តែនាងនោះមិនមានព្រះរាជបុត្របុត្រា ឃើញចូយ៉យជាបុត្រនាងអៀនស៊ី មានតម្រិះប្រាជ្ញាស្រស់ស្រួច ក៏គួបចិត្តគិតស្រឡាញ់ ទើបអស់អញ្ជូមបីបាច់ជាបុត្របណ្ដុលបណ្ដាច់ ដូចកើតពីឧទរ, ចូយ៉យក៏ចម្រើនវ័យបាន ១៥ ឆ្នាំ ចេះចាំវិជ្ជាសិល្បសាស្ត្រគ្នាត ពូកែខាងបាញ់ធ្នូនិងប្រើអាវុធទាំងពួង ។

លុះព្រះចៅចូកី សោយរាជសម្បត្តិ បាន ៧ ឆ្នាំ (ព.ស. ៧៦៩) ដល់ខែផល្គុន រដូវក្ដៅ, ព្រះចៅចូកី ក៏នាំចូយ៉យជាព្រះរាជឱរសចេញទៅប្រពាតព្រៃ ដើម្បីដេញបាញ់សត្វ ជាទីប្រៀបបង្ហាត់វិជ្ជា, បណ្ដាខ្ញុំរាជការទូវពលទាហាន ក៏កៀងបានប្រើសមេទិងកូនចេញមកពីព្រៃ, ព្រះចៅចូកីក៏ទ្រង់ធ្នូដ័យបាញ់ទៅត្រូវមេប្រើសស្លាប់, កូនប្រើស ក៏បោលក្រឡាប់តែសំដៅទៅចំមុខចូយ៉យ ។ មានចិត្តអាណិតណាស់ ប្រាសប្រែក្រ្ដូវម្នាក់ធ្នូនៅស្ងៀមមិនបាញ់ ព្រះចៅចូកីជាបិតា ត្រាស់ថា ម្នាលបុត្រសម្លាញ់ ហេតុម្ដេចបានជាបាមិនបាញ់កូនប្រើសដូច្នោះ, ចូយ៉យក្រាបទូលដោយ

ស្មោះថា ប្រើសមេកួន ព្រះបិតាបាញ់មេរាក្សយស្លូតដីវិតទៅហើយ ខ្ញុំ ព្រះបង្គំជាខ្ញុំ ឃើញកូនរាស់នៅឡើយ រាក៏គិតភ័យព្រាលត្រង់មកលើ មនុស្សម្នា រាមិនដឹងខ្លាចដោយអំណាចសេចក្តីអាល័យមេរា ក៏កព្រាដួច រូបទូលព្រះបង្គំជាខ្ញុំដែរ, ទូលព្រះបង្គំជាខ្ញុំមានចិត្តអាណិតរាណាស់ ទឹង លើកដៃរហ័សបាញ់មិនបាន សូមព្រះរាជទានទោស ។

ព្រះចៅបូគី បានទ្រង់ព្រះសណ្តាប់ព្រះរាជនុរាស ក៏ទ្រង់ថ្នស់ព្រះភ័ក្ត្រ ធ្លាក់ព្រះទ័យបង្កើតសេចក្តីអាណិតរាជបុត្រា របូតធ្នូពីព្រះហត្ថាធ្លាក់ទៅ ដល់ដី គិតថាបុត្រយើងនៅក្មេងសេចក្តីកមែន តែមានចិត្តគិតមេត្តាសត្វ គួរទឹងគ្រងរាជសម្បត្តិជាម្ចាស់ផែនដីបាន គិតហើយ ក៏ឡើងគង់លើព្រះ រាជយានទាំព្រះរាជបុត្រវិលចូលមកព្រះបរមរាជវាំងវិញ, ព្រះចៅបូគី ក៏ ទ្រង់តាំងចូយ៉យរាជបុត្រាជាកេងន្លួនអង គឺស្តេចតាងក្រម ។

លុះដល់ខែអាសាធ ព្រះចៅបូគី ទ្រង់ប្រឈួនធ្ងន់ដោយកេតខ្យល់, ពេទ្យព្យាបាលប៉ុន្មានក៏មិនស្រាក ទើបមានព្រះតម្រាស់ឲ្យហៅបូជិន ១ តាន់កុង១ សុម៉ាអ៊ី១ ដែលជានាហ្មឺនធំ ហើយនិងចូយ៉យរាជបុត្រ ឲ្យ ចូលគាល់ផ្លាល់ព្រះអង្គ, ព្រះចៅបូគីទ្រង់ត្រាស់ថា វេលានេះ ខ្លួនយើង ឈឺធ្ងន់ណាស់ មើលទៅមុខជាធន់ពុំបាន, ហើយយើងក៏មានសេចក្តី ព្រួយដោយចូយ៉យនៅក្មេងសេចក្តីខ្លីគំនិត, បើកាលណាយើងអស់អាយុ ជីវិតទៅ, អ្នកទាំងអស់ឆាប់នៅធ្វើរាជការជាមួយនឹងយើងដូចម្តេច, ចូរ

ជួយឈឺឆ្អាលពដការ រក្សាសេចក្ដីសុខ ទំនុកបម្រុងស្រុកទេស ឲ្យបានទៀបរយដោយធម៌, សូម្បីកិរិយាបុត្ររបស់យើងៗ បានឧបត្ថម្ភយ៉ាងណា សុំឲ្យជួយព្យាបាលរក្សាយ៉ាងនោះផងចុះ, នាម៉ឺនទាំង ៣ នាក់ បានឮព្រះតម្រាស់ ក៏ទូលហើសតបថា សូមកុំឲ្យព្រះអង្គទ្រង់ព្រះបរិវិតក្កឡើយ ទូលព្រះបង្គំជាខ្ញុំទាំង ៣ នាក់នេះហើយ នឹងតាំងចិត្តធ្វើពដការថ្វាយធ្ងន់ព្រះតេជព្រះគុណ ដកបតាល់អស់ជីវិត, ព្រះចៅចូក៏ត្រាស់ថា យើងបានឃើញហេតុផៈទីសាគេទក្នុងចិត្តណាស់ ព្រោះខ្លោងទ្វារព្រះនគរជាទីប្រជុំធំឥតហេតុផលអ្វីសោះ ស្រាប់តែបាក់រលុះចុះឯង ឃើញថាខ្លួនយើងនឹងអស់បុណ្យជាក់ស្ដែងប្រាកដក្នុងគ្រានេះ ។

ខណៈនោះ មានពួកខន្ទីចូលទៅទូលថា ចូហ៊ីវជានាម៉ឺនធំសម្រាប់កម្ចាត់សត្រូវខាងទិសឯកើត សុំចូលមកគាល់, ព្រះចៅចូក៏ត្រាស់ហៅឲ្យចូលទៅ ហើយទ្រង់ព្រះកន្សែងពិលាប ត្រាស់សួរចូហ៊ីវថា អ្នកជានាម៉ឺនធំ បានជួយប្រាបប្រាមសត្រូវ តាំងពីស្រុកហ៊ូគោនៅមិនទាន់បានជាទីមាំមួន រហូតមកដល់ទាល់ធំទូលាយត្រឹមនេះហើយ ខ្លួនយើងក៏នៅល្ងមនៅឡើយមិនទាន់នឹងដកប៉ុន្មាន ទើបបានតែ ៤០ ឆ្នាំ បានសោយរាជ្យ ៧ ឆ្នាំ ជាផលកម្មនាំឲ្យកើតកេតធ្ងន់ យើងក៏ឃើញថានឹងគង់នៅគទៅពុំបានទេ, អ្នកនៅឯក្រោយ ចូរជួយទំនុកបម្រុងបុត្រយើងដោយសុចរិត ឲ្យចិត្តយើងអស់ព្រួយវិតក្កផងចុះ, លុះត្រាស់ចប់ព្រះរាជា

ព្រះចៅចូភីក៏ទិវង្គត ។

ចូជិន ១ តាន់កុង ១ សុម៉ាអ៊ី ១ នូវអស់នាម៉ឺនមុខមន្ត្រីតូចធំ ក៏ប្រជុំអញ្ជើញចូយ៉យឲ្យឡើងគ្រងរាជសម្បត្តិ តាំងនាមក្សត្រជាព្រះចៅតៃនុយហង់តេ (ព.ស. ៧៧១), លុះព្រះចៅចូយ៉យសោយរាជសម្បត្តិជាក្សត្រាធិរាជ ក៏ទ្រង់ឲ្យអំណាចលើកលែងមនុស្សទោសក្នុងគុកទាំងអស់ ហើយទើបចាត់ចែងតែងការព្រះបរមសពព្រះចៅចូភី ជាបិតាតាមប្រពៃ-ណី, លុះធ្វើស្រេច ស្ដេចក៏តាំងនាម៉ឺនមុខមន្ត្រីឲ្យឡើងយសសក្តិ តាមថ្នាក់តូចធំជាលំដាប់ ត.ម.ដែលមានគុណ ត.ប់ក្នុងរាជការ ហើយទ្រង់មានព្រះតម្រាស់នឹងសុម៉ាអ៊ីថា ស្រុកសេលៀងនោះ ជាប់ជិតគ្នានឹងស្រុកសេឈួន ជាស្រុកមុខសឹក លុះតែមានអ្នកប្រាជ្ញជំអធិកជ្រៅជ្រះ មានតបះក្លៀវក្លាហាន ទើបបានទៅនៅរក្សាខ្ជាប់ខ្ជួន ។ សុម៉ាអ៊ីបានឮព្រះតម្រាស់ ក៏តែងរឿងក៏ក្រាបទូលថ្វាយ សុំចេញទៅយកអាសានៅរក្សាស្រុកសេលៀង ។ ព្រះចៅចូយ៉យ ក៏យល់ព្រមចាត់សុម៉ាអ៊ី ឲ្យចេញទៅនៅស្រុកសេលៀង ។

(នៅមានត)

# រឿង
# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២៩

នាងកាមាលានៅក្មេងណាស់ ម៉្លោះហើយទុក្ខព្រួយ មិនសូវនៅត្រាំក្នុងបេះដូងនាងបានយូរពេលទេ ឲ្យតែមានឱកាសល្អបន្តិច នាងភ្លេចទុក្ខភ្លាម ។

រល់ព្រឹក អ៊ុយមេស្ហតែងយកបន្លែពីចំណតកប៉ាល់មកឲ្យនាង ។

— លោកមា មើលត្រសក់អីល្អម៉្លេះ សណ្តែក ថៃថាវ អីក៏ល្អៗណាស់ដែរ ប៉ុន្តែកមេស្ហមិនដែលពេញចិត្តទេ ព្រោះគេចេះតែមានចិត្តសង្ស័យថា : កុមារកំព្រាលួចបេះដំណាំអ្នកស្រុកដូចមុនទៀតហើយនាងកាមាលាខឹងក៏ប្រាប់ថា : ។

— នែបង ! កុំចេះតែថា ខ្ញុំរាប់លុយឲ្យគេទៅវិញគេនឹងដៃខ្ញុំណា ! ។

— ឱ, ហ្នឹងរឹតតែបានលួចពីរដូរទៅទៀត, វាលួចយកលុយដែលអូនឲ្យហើយ, វាលួចដំណាំគេទៀត ។

ដើម្បីនឹងដេញដើងកុមារកំព្រា រមេស្ហស្រវថ្លៃបន្លែ ប៉ុន្តែគេគិត

មើលទៅនៅតែឃើញថាប្រាក់ដែលចាយនោះ មិនទាន់សមនឹងរបស់ដែលបានមកសោះ ព្រោះឃើញដូចជាថោកពេក ។ អ៊ុយមេស្ហមិនសប្បាយចិត្តនឹងគេដេញដោលកំឡើយថា ។

— បើខ្ញុំចេះគិតលុយកាក់ត្រឹមត្រូវ ខ្ញុំមិនមែននៅទីនេះទេ ម៉្លេះខ្ញុំទៅធ្វើជាមេហាងបាត់ទៅហើយ មែនទេលោកតា ?

— ណ្ហើយកុំនិយាយ ចាំបាយហើយសឹមដដែក (លោកតានិយាយ) ឯសណ្ដែកវិញខែនេះមានទៅស្រួលរកឯណា ថែមទាំងនៅក្នុងស្រុកដែលយើងមិនស្គាល់គេផងនោះ ប៉ុន្តែណ្ហើយ កុំខ្វល់អ្នកណាថាអីថាទៅរកមនុស្សឯណាឲ្យចេះរករបស់ដែលយើងត្រូវការឲ្យបានទាន់ចិត្តដូចវាហ្នឹង ។

កមេស្ហពុំមាននិយាយកាន់ជើងក្មេង ស្ដីបន្ទោសតាបន្ដិចទៅទៀត តែតាតវ៉ាណាស់គាត់នៅតែបចេសទៀត ។

វាជាក្មេងខ្វះប្រាជ្ញា បើគ្នាខំប្រមូលបានបន្ដិចបន្តួចហើយយើងបន្ទុចបង្អាក់ទៅទៀត ក្រែងបានស្ដាយក្រោយ មុននឹងយើងទៅដល់ទីដៅនៃអ៊ុយមេស្ហ យកបន្ទៃទៅលាងទៅកុំនៅស្ដាប់អី ។

តែកាលណាកមេស្ហស្ដីបន្ទោស អ៊ុយមេស្ហរត់ទៅជិតនាងកាមាលាភ្លាម ហើយចាំតែពីបានមាយើងចូលថែមមក នាងកាមាលាកាន់តែបានគ្នាច្រើនគ្រាន់នឹងនិយាយលេងនៅពេលធ្វើការ ទុកឲ្យកមេស្ហនៅប្រឆ្លៀតក្រអឹកតែឯងមួយថ្ងៃកល់ៗណាក ការស៊ីស្ងាលរវាងមា អ៊ុយ-

មេឃ ទិសនាងកាមាលាក៏ កាន់តែមានសភាពជិតឡើងមួយថ្ងៃបន្តិច ៗ ប៉ុន្តែបុរសយើងនៅតែមានកិរិយាបែបផ្ទន់ទឹងថ្កល់ វិស័យដូចនាគដែលមានជម្រៅបាតស៊ីទឹកជ្រៅពេក មិនហ៊ានចូលទៅក្បែរច្រាំងខ្សាច់គៀន ហើយត្រូវតែបោះយុថ្កាកណ្ដាលទន្លេតែម្នាក់ឯង ឯចំណែកទូកតូចៗដទៃ គេបេះតែចូលទៅ ទោះជាទឹកកក់យ៉ាងណាក៏បេះតែទៅរួចទាំងអស់ ៗ

ព្រឹកមួយនោះ ពេលអ្នកដំណើរក្រោកចេញពីដំណេកមក ផ្ទៃមេឃមានសុទ្ធតែផ្ទាំងពពកស្លាប់បាំងជិត រសាត់លឿនស្ទើរតែដើងមេឃម្ខាងទៅដើងមេឃម្ខាង ទឹកភ្លៀងធ្លាក់ចុះមួយពាំមេត បន្តិចព្រះអាទិត្យក៏បើកឡើងវិញ ដោយខ្យល់ខ្លាំងបក់ផាត់ពពក ទឹកហូរដោយដុំៗនៅក្នុងផ្ទៃទន្លេ ទូកតូចតាចៈលោតរលកក្ញុបក្ញុត ៗ គួរឲ្យភ័យរត់រកច្រាំង ពួកអ្នកភូមិស្រីៗដែលចុះមកដងទឹកកំពង់យកទៅប្រើប្រាស មិនហ៊ានបង្អែរបង្អង់យូរឡើយឯផ្ទៃទន្លេក៏រញ្ជួយហាក់ដូចជាគេអង្រួន រីឯកប៉ាល់ក៏បេះតែបន្តដំណើរជាធម្មតា នាងកាមាលាក៏រៀបចំធ្វើបាយតាមធម្មតាដែរ ៗ

— មើលទៅល្ងាចនេះធ្វើអ្វីមិនកើតទេ មេឃមិនស្រលះទេណាធ្វើអ្វីធ្វើឲ្យហើយតាំពីព្រឹកទៅ (មានិយាយបណ្ដើរងើយមើលមេឃបណ្ដើរ) ដាក់អង្ករដាក់អីមកចាំតួជួយ ៗ

ក្រោយពេលបាយល្ងាច ខ្យល់ក៏កាន់តែខ្លាំងឡើង ៗ ព្រះអាទិត្យក៏លិចបាត់ដោយគ្មានអ្នកណាមួយចាប់ក្ដីសោះ នាវាក៏ចូលរកទីសំចតមុន

ពេលធម្មតា ដោយមេឃមានព្យុះខ្យល់ ។ មិនយូរប៉ុន្មានទកត្រីកាលក៏ទម្លាក់ស្បៃ ខ្មៅងងឹតគ្រប់ផែនដីជាមួយនឹងភ្លៀងព្យុះសង្ឃរា ។

ពុះខ្យល់ព្យុះខ្លាំង នាងកាមាលាភ័យណាស់ ស្ទុះចេញមករកគេ ឯងឲ្យទៅទៅជិតនាង - ។

– កុំភ័យ កប៉ាល់ប៉ុណ្ណេះហើយភ័យអីទៀត ទៅគេងទៅ ខ្ញុំឥតទៅណាឆ្ងាយទេ ខ្ញុំក៏មិនទាន់គេងដែរ (ភរមេស្ហនិយាយ) - ។

ភរមេស្ហចេញផុតទៅ លោកមាពក្រពត្តិចូលមក ។

កុំខ្លាចអីអ្នកនាង ខ្ញុំមិនឲ្យខ្យល់ព្យុះកំណាចនេះ ប៉ះសក់អ្នកនាងមួយសរសៃបានឡើយ ប៉ុន្តែទោះជាលោកមាយើងខំអួតអាងយកខ្លួនពាំងពារយ៉ាងម្តេចក៏នាងកាមាលានៅតែមិនបាត់ភ័យ នាងខំស្ទុះចេញតាមលោកពូហើយស្រែកអង្វរគាត់ថា: ។

– លោកពូ! លោកពូ! ចូលមកអង្គុយជិតខ្ញុំមក អាណិតខ្ញុំទៅ លោកមាបែបអស់អែកមិនចង់ហ៊ានចូល ក៏ឆ្លើយតបថា: -

– ទេ អ្នកនាង ពេលនេះជាពេលដែលអ្នកនាងនឹងលោកប្រុសត្រូវសម្រាន្ត ខ្ញុំត្រូវតែ . . . ( លោកមានិយាយបណ្តើរ ឈានជើងចូលបណ្តើរ )លុះគាត់មើលទៅមិនឃើញភរមេស្ហ គាត់ងល់ ហើយសួរនាងថា:

– លោកប្រុសទៅណា មេឃអាក្រក់យ៉ាងហ្នឹងលោកចេញទៅក្រៅធ្វើអី ?

ឮសូរមាត់លោកពូ កមេស្ហក៏ឆ្លើយពីបន្ទប់ខ្លួនមក លោកពូហោល ក្មែករកសម្ដេង ឃើញកមេស្ហដេកលើគ្រែកើយខ្នើយយ៉ាងខ្ពស់ កំពុងតែមើលសៀវភៅ ។

- លោកអើយ ប្រពន្ធលោកមិនហ៊ាននៅតែឯង ម្ដេចក៏លោកនៅចាំមើលសៀវភៅអ៊ីម្ល៉េះ ម្ដេចក៏មិនទុកសិនទៅ ?

ឮពាក្យមានិយាយទឹងកមេស្ហ នាងកាមាលាខឹងហោស់ទប់មិនបាន នាងចាប់ដៃលោកមាគូសថយក្រោយ ។

- ទេលោកពូ លោកពូមានប្រសាសន៍អីអីចឹង ពេលនោះខ្យល់ព្យុះខ្លាំងណាស់ លប់បាត់សម្លេងនាងកាមាលា កមេស្ហស្ដាប់មិនឮ ឮតែមាត់លោកពូ គាត់ឆ្ងល់ ហើយងាកមកមើលមុខនាងបែបស្រឡាំងកាំង ។ កមេស្ហដាក់សៀវភៅចុះ ដើរតាមមក ។

- មានការអីហ្នឹង ម្ដេចក៏ . . . .

- ទេ!ទេ! ឥតមានការអីទេ (នាងឆ្លើយតបដោយមិនងើបមើលមុខកមេស្ហសោះ) ខ្ញុំចង់ឲ្យគាត់មកនិយាយលេងនឹងខ្ញុំ ហើយគាត់ស្មានថាខ្ញុំខ្លាច ប៉ុន្តែសំដីនាងធ្វើឲ្យកមេស្ហយល់ថា "បើប្រសិនជាអ្នកយល់ថាខ្ញុំត្រូវការអ្នកដើម្បីមកនៅជិតខ្ញុំ នោះច្បាស់ជាខុសហើយ ខ្ញុំមិនបាច់ត្រូវការអ្នកណាមកកំដរខ្ញុំទេ" នាងនិយាយទៅកាន់លោកមាថែមទៀតថា:

—យប់ជ្រៅណាស់ហើយ លោកមាអញ្ជើញទៅសម្រាន្តចុះ ហើយសូមលោកមាជួយមើលអ៊ុយមេស្ហផងមើល ក្រែងវាខ្លាចព្រោះខ្យល់ខ្លាំងណាស់ ។

— ខ្ញុំឥតខ្លាចអ៊ីទេ ម៉ែ ។

នាងក្រឡេកតាមសម្ដីទៅ ឃើញក្មេងកំព្រានៅអង្គុយកៀនទ្វារញ័រទទ្រើត នាងស្ទុះទៅជិត ហើយស្រែកឲ្យវាថា „យីមើលហ្ន៎ ទទឹកជោក ក្មេងចំកួតនេះ„ ។

—ទៅ? នៅដេកក្នុងបន្ទប់ជាមួយលោកមាទៅ អ៊ុយមេស្ហក៏ក្រោកដើរតាមក្រោយលោកមាទៅ ភមេស្ហនៅតែឯងជាមួយនឹងនាងកាមាលា អ្នកសួរទៅនាង :

—អូនចង់ឲ្យបងនៅនិយាយលេងជាមួយអូនទំអូនងុយគេងទេ ?

—ទេបង ខ្ញុំអរគុណហើយ ខ្ញុំងុយគេងហើយ ។

គ្រាន់តែឮចម្លើយនាង អ្នកយល់ដល់ជម្រៅចិត្តនាងទៅហើយ តែអ្នកមិនរកមធ្យោបាយនឹងទាញមកវិញទេ ព្រោះនាងមានខមាន ចិត្តមិនព្រមសារភាពថាខ្ញុំខូចស្រឡាញ់ ហើយត្រូវការអ្នកឡើយ អ្នកក៏ដើរចូលទៅក្នុងបន្ទប់អ្នកទៅទុកនាងឲ្យនៅក្នុងភាពអន្ទះអន្ទែង គេងក៏ពុំលក់ តែទំនៅសម្ងំស្ដាប់សូរខ្យល់ព្យុះលោកបោកបក់ខ្លាំងតែខ្លាំង ក្រុមទាវិកក៏គ្មាន

អ្នកណាមួយដេកដែរ ពេលស្ងប់ម្ដងៗ ព្យុះក៏សម្រុកខ្ទប់បំពង់ សម្លេងបញ្ជារបស់លោកនាវាប្រមុខ នៅក្នុងបន្ទប់គ្រឿងចក្រ ៗ នៅពេលមានខ្យល់ព្យុះខ្លាំងបែបនេះ យុក្តាតែម្យាងមិនអាចទប់កប៉ាល់ឲ្យហ្នឹងបានទេ ទាល់តែប្រើគ្រឿងចក្រឲ្យដើរបន្តិចៗជំរុញទើបបាន ៗ

លុះភ្លៀងទឹងខ្យល់ស្ងប់បន្តិចទៅ នាងកាមាណាក៏ក្រោកចេញមកខាងក្រៅ ខ្យល់នៅមានសន្ទុះខ្លាំងនៅឡើយបក់វិលវល់បញ្ចេញសូរវ៉ូៗបី ដូចសម្លេងឋនៃដងឈើដាប់ ហើយមើលទៅផ្ទៃមេឃ ព្រះច័ន្ទចាំត្រដរ បញ្ចេញរស្មីស្រអាប់តាមចន្លោះដុំពពក ដែលបេះតែរសាត់លឿនស្ទៅវស័យដូចគេចឹង ងាកមើលទៅក្រោយ ឃើញតែផ្ទៃខៀវងងឹតជាប់ពីទឹកទៅមេឃ នាងកាមាណាឈរបណ្ដែតអារម្មណ៍តែម្នាក់ឯងដូចជាសប្បាយបន្តិច ដូចជាព្រួយបន្តិច ៗ

## វគ្គទី ៣០

លុះភ្លឺស្វាងឡើង ព្យុះខ្យល់ក៏ស្ងប់ផង លោកមាចក្រពត្តិក្រោកពីព្រលឹម ហើយដើរចូលទៅមើលកមេស្ហ ៗ លុះឃើញមាអេតកចូលទៅ អ្នកស្រុះផ្លើបក្លាយ តែលោកខាយល់ព្រួចថាកមេស្ហពុំបានមិត្រទៅជាមួយប្រពន្ធទេ ពីយប់មិញនេះ ៗ តែដើម្បីកុំឲ្យមានសួរកើតទាន់ ការបស្ហាប់

និយាយមុខភ្លាម ។

— យី ថ្ងៃនេះអ័ព្ទអួរណាស់ លោកមាសម្រាន្តបានឬទេ ?

ទេ ! លោកកាមេស្ហ ខ្ញុំចំណាស់នេះហើយ ខ្ញុំមិនមែនមិនធ្លាប់ដោះស្រាយបញ្ហាស្មុគ្រស្មាញទេ លោកឃើញខ្ញុំចេះតែនិយាយប៉ប្រប៉ប្រដូចមនុស្សលីលាហើយគិតណាស់ដែលថា ខ្ញុំរកផ្លូវចេញមិនរួចអំពីបញ្ហាទាំងនោះ ប៉ុន្តែមនុស្សបែបលោកខ្ញុំមិនទាន់ដែលជួបនៅឡើយទេ ។

ត្រឹតែប៉ុណ្ណោះកាមេស្ហជូតទឹកមុខមួយរំពេច តែអកខំសើចហើយ. និយាយបន្ទប់ភ្លាមថា :

— មើល៍លោកមា បើសិនជាខ្ញុំស្រាយបញ្ហាស្មុគ្រស្មាញរបស់ខ្ញុំមិនរួច តើជាទោសឧក្រិដ្ឋប៉ុយ៉ាងណា ? មានការខ្លះយើងមើលឃើញតែពីសំបក មិនដឹងជាមានការគាថិកប៉ុនយ៉ាងម្ដេច លោកមាកុំប្រញាប់តែដាក់ទោសឲ្យខ្ញុំពេក ។

— ត្រូវហើយលោក ប៉ុន្តែសូមលោកជ្រាបថា ចុះបើគេមិនទុកចិត្តយើង ទោះជាយើងខំចង់យល់ការរបស់គេយ៉ាងណាក៏ទៅពុំរួចដែរ ព្រោះមនុស្សខ្លះគ្រាន់តែស្គាល់ភ្លាម ហាក់ដូចជាមានការស្និទ្ធស្នាលតែនៅយូរបន្តិចទៅ ស្រាប់តែចេញជាបញ្ហាវាយមិនបែកតែម្ដង ។

លោកកាមេស្ហ បើប្រសិនជាលោកត្រិះរិះបន្តិចទៅ លោកនឹងមិនប្រកាន់ចឹងនឹងខ្ញុំទេ

— តែព្រោះតែខ្ញុំបានគិតរួចហើយ ហើយបានជាខ្ញុំមិនខឹង ប៉ុន្តែខ្ញុំសូមជម្រាបមាថា ទោះខ្ញុំខឹងក្តី មិនខឹងក្តី ទោះលោកមាអន់ចិត្តនឹងខ្ញុំក្តី មិនអន់ក្តី បញ្ហាស្ត្រីស្នាញ់គឺនៅតែមាន មិនដឹងជារលាស់ពេលទៅណាឲ្យផុតបានទេ ។

មុនដំបូងរាមេស្ហគិតថា ការចងមិត្រជាមួយនឹងតាបាស់នោះមុខជាមិនឥតប្រយោជន៍ដល់អ្នកទេ ព្រោះអ្នកត្រូវការតាំងទីលំនៅនៅ ghazidour (គ្ហាស៊ីប៊ូរ) ដែលជាស្រុកដែលអ្នកមិនដែលស្គាល់សោះ តែឥឡូវនេះអ្នកយល់ថាការចងមិត្តនឹងតានេះនាំឲ្យវិនាសដល់អ្នកទៅវិញទេ ព្រោះគាត់ចេះតែចង់ដឹងការពិតរបស់អ្នកគិត ហើយអ្នកក៏សម្រេចចិត្តថា ត្រូវតែទៅរកនៅទីកន្លែងណាដែលគ្មានគេស្គាល់ ទើបសុខ ។

លុះដិតទៅដល់គ្ហាស៊ីប៊ូរ រាមេស្ហនិយាយទៅកាន់លោកមាចក្របត្តិថា: ។

— មើលទៅ ខ្ញុំទៅរកការហោល័យមេធាវីនៅស្រុកលោកមាមិនកើតទេ ខ្ញុំចង់ចុះរហូតទៅរកការសែតម្តងហើយ ។

—លោកកុយតឹកគ្រឹតតឲ្យស្រេចតែម្តងទៅ កុំម្តងទៅនេះ ម្តងទៅនោះ ដូច្នេះមិនកើតទេ . . . . ។

ក្រោយបន្តិចមក លោកតាយើងក៏ទៅរៀបចាប់ចាយ ដើម្បីនឹងចុះ ៗ នាងកាមាលាស្ដីនាត់ថា:

លោកមាមិនសូវស្រួលខ្លួនឬបានជាមិននិយាយលេងនឹងខ្ញុំសោះ ឮសម្តីចំអករបស់នាងកាមាលាលោកនឹកខ្នាញ់ក៏តបទៅវិញ ។

–កុំថែរជាពោចដាក់កំហុសមកឲ្យខ្ញុំទៅវិញនោះ បើយកខ្ញុំមកបញ្ឈរពោលឲ្យខ្ញុំរត់ទៅរកនាងដូចម្តេច (លោកមានិយាយបណ្តើរងើបមើលមុខនាងបណ្តើរ) ប៉ុន្តែលុះមើលទៅឃើញនាងធ្វើឡឹងឡង់ គាត់ក៏សួរបន្ថែមថា: ចុះនាងមិនដឹងថានាងត្រូវទៅរហូតដល់ Bénarès ទេឬ ?

នាងគ្រាន់តែមើលមុខគាត់ស្ងៀមមិនឆ្លើយ មួយសន្ទុះទើបនាងនិយាយ: ។

– មើល៍លោកមា ដាក់អ៊ីចឹងមិនស្រួលទេឲ្យខ្ញុំរៀបជូនវិញ ។

លោកមាមិនស្តីមួយមាត់សោះ ព្រោះគាត់អន់ចិត្តនឹងនាងកាមាលាដែលសុខចិត្តផ្លាស់ទៅចុះឯ Bénarès វិញតាមប្តី ដោយមិនប្រកែកអ្វីបន្តិចសោះ គាត់នឹកក្នុងចិត្តគាត់ថា: "មែនហើយចំណាស់ឯងហើយខំទៅចងមិត្តនឹងគេក្មេង ៗ ធ្វើអ្វីទៀត" ។

លោកមាកំពុងគិតតូចចិត្តដូច្នេះ ស្រាប់តែឮសូរមាត់កម្មករដើររកនាងកាមាលាដើម្បីប្រាប់ឲ្យនាងដឹងថាមិនចុះទៅ Ghazipour ទេ ទៅចុះឯ Bénarès វិញ ។

–កុំកាលរៀបចំអី យើងមិនចុះនៅនេះទេ ចាំទៅចុះនៅ Bénarès វិញ ខ្ញុំចូលចិត្តទៅមើលកន្លែងគេស៊ីឯនោះវិញ មិចពេញចិត្តទេ ?

-ទេ! នាងឆ្លើយទាំងមិនងើបមើលមុខកមេស្វាផង, ខ្ញុំចុះនៅគ្មាស៊ីប៉ុរ ខ្ញុំរៀបចំឥវ៉ាន់ ខ្ញុំអស់ហើយ ។

—គិតនៅតែឯងឬ ? (កមេស្វាសួរបញ្ជាក់បែបស្រង៉ាកចិត្ត ដោយឮនាងប្រកែកដាច់អហង្ការពេក ។

—ចុះមានលោកមាហើយតើ ( នាងង៉ាកមើលមុខលោកមា តែលោកមារគេៀសខ្លួនឆ្លើយកាត់ភ្លាម) ។

យីចុះមេចមកតាមខ្ញុំទៅវិញ គិតប្តីនាងទឹងទឹងខ្ញុំ នាងកាមាលានៅតែរឹងថានាងចុះនៅ Ghazipour ដដែល ព្រោះនាងចង់បញ្ចេញឲ្យកមេស្វាដឹងថា នាងមានសេរីភាពពេញបរិបូណ៌ទឹងធ្វើអ្វីទាំងអស់ ព្រោះនាងគ្មានម្ចាស់ចិត្ត ។

ក្នុងរាត្រីកាលនោះ លុះខ្យល់ផាត់ពពកខ្មៀនខ្មៅស្អាប់ បាត់អស់បញ្ចេញផ្ទៃមេឃស្រឡះធេង មើលទៅគួរឲ្យស្រឡះចិត្ត ប៉ុន្តែកមេស្វាដែលអង្គុយទស្សនាធម្មជាតិ មានចិត្តខ្វល់ខ្វាយវិស័យដូចសូត្រដំពាក់កេមុខមិនឃើញ ព្រោះអ្នកគិតថា:

ការរស់នៅជាមួយនាងកាមាលា ដោយបន្ទំបំភ័ន្តកែ្កអ្នកស្រុកបែបនេះ តែនាងកាមាលាក្តៅក្រហាយ មុខជាកាសខ្ទង់ ធ្វើយបើកសនាលើកនាងដាក់ក្នុងរន្ធដ៏ដៃឲ្យហើយ ទទួលនាងជាប្រពន្ធទៅចុះម្យ៉ាងទៀតមុខទឹងបានទៅដល់នាងហិមណាលិនី អ្នកត្រូវប្រយុទ្ធយកជ័យ

ជំនះលើសត្រូវមួយគង់យ៉ាងធំសម្បើម ដើម្បីកុំឲ្យនាងមានគំនិតសង្ស័យលើចិត្តរបស់អ្នក ប៉ុន្តែចុះមានមធ្យោបាយណា ដើម្បីសឲ្យនាងជឿជាក់ថាអ្នកមានគំចិត្តបរិសុទ្ធ បើសិនជាអ្នករកផ្លូវទឹងបង្ហាញសេចក្ដីបរិសុទ្ធចិត្តអ្នកឃើញ ក៏នៅតែជៀសអាសន្នមិនរួច ចំពោះរូបនាងកាមាលាវិញ គិតទៅគិតមក នៅតែឃើញថាជៀសទទួលនាងកាមាលាជាប្រពន្ធមិនរួច . . ឯចំណែកនាងហិមណាលិនីវិញ បើសិនជានាងទឹកអ្នកតាំងស្ងប់ខ្ពើមវិញ នោះជាការប្រសើរទៅវិញទេ ព្រោះមានមនុស្សម្នាក់ទៀត ត្រៀមខ្លួនចាំតែទទួលនាងស្រេចទៅហើយ ។

## វគ្គទី ៣១

— នែ! អ៊ុយមេស្វា! ឯងចុះទៅណាដែរ ។

- ខ្ញុំ ទៅជាមួយម៉ែ ។

— ចុះអញទិញសំបុត្រឲ្យឯងរហូតដល់ Bénarès ហើយតើ អញនឹងអ្នកឯងទៃដែលត្រូវចុះទៅភ្នាស៊ីបុរីនេះ ។

— ទេ! ខ្ញុំចុះដែរ ខ្ញុំមិនទៅ Bénarès ទេ

ពាមេស្វាមិនស្មានថាអ៊ុយមេស្វា បោះតែតាមអ្នករហូតយ៉ាងនេះទេ លុះព្រឹកឡើងនោះឆ្លើយថាខ្ញុំទៅតាមម៉ែ តែបន្ទូចបំបាក់ដួលអ្នកទឹកឆ្លង ហើយក៏ចាប់ប្រស្នូរនាងកាមាលាថា :

- យើងយកវាទៅជាមួយយើងរហូតឬ ?
- ចុះវាមានអ្នកណា ក្រៅពីយើង ។
- វាមានបងប្អូននៅ Bénarès ដែរទេតើ !
- ប៉ុន្តែវាចូលចិត្តនៅជាមួយយើងជាង ។

នែ ! ស៊ុយមេស្ហ ទៅជិតលោកម៉ាទៅ មើលគេឲ្យមែនទែនណា ប្រយ័ត្នវង្វេង មនុស្សច្រើនណាស់ ។

តាំងពីដើមរៀងមក នាងកាម៉ាលាចាត់ចែងការដូចជាមេផ្ទះ ហើយស្ដាប់បង្គាប់ស៊ុយមេស្ហហាក់ដូចជាប្រពន្ធ តែការស្ដាប់បង្គាប់ត្រូវចប់នៅពេលនេះ ។

ស៊ុយមេស្ហកាន់កញ្ចប់សម្បត្តិមួយតូចរបស់វានៅដៃ ចេះតែដើរតាមនាងកាម៉ាលាតត្រកមួយម៉ាត់ក៏មិនស្ដី ។

លោកម៉ាយើងមានទីលំនៅតូចមួយនៅចន្លោះក្រុងនឹង ភូមិពួកអឺរ៉ុប នៅពីមុខលំនៅនោះមានអណ្ដូងមួយធ្វើដោយថ្ម នៅពីក្រោយផ្ទះមានចំការស្វាយ នៅខាងមុខផ្ទះនោះមានសួនបន្លែ ហើយគាត់បានធ្វើរបងដោយថ្មយ៉ាងខាប់ល្អព័ទ្ធជុំវិញ ។ លោកម៉ាបានទទួលភ្ញៀវទាំងបីនាក់ឲ្យនៅសំណាក់ផ្ទះគាត់ជាបណ្ដោះអាសន្នសិន ទំរាំរកផ្ទះស្រួលបួលបាន ។

អ្នកស្រីហារីកាត់ទីជាប្រពន្ធលោកម៉ា ដែលប្ដីគាត់តែងតែ [illegible] ប្រាប់នាងកាម៉ាលាថា : គាត់ជាមនុស្សមិនរឹងប៉ឹងទេ ដូចជាមិនមាន

ក៏និស្ស័យបង្ហាញឲ្យយើងឃើញថា គាត់មនុស្សខ្វាយខ្វល់សោះ ។ គាត់មានចំណាស់ជាងពាក់កណ្ដាលមនុស្សទៅហើយមែន តែទឹកមុខគាត់បង្ហាញឲ្យឃើញថា គាត់ជាអ្នកនៅមានកម្លាំងពលំគ្រប់គ្រាន់ ហើយជាអ្នកធ្លាត់ផង សក់គាត់មានស្កូវខ្លះតែត្រង់គុម្ពត្រចៀកប៉ុណ្ណោះ ។

កាលដែលគាត់ទើបនឹងរៀបការជាមួយនឹងប្ដីនេះ គាត់បានឈឺជម្ងឺគ្រុនយូរពេក ហើយពេទ្យបានប្រាប់គាត់ថា ទាល់តែផ្លាស់ខ្យល់អាកាសទើបជម្ងឺគាត់អាចស្រាកបាន ហេតុដូច្នេះហើយទើបប្ដីគាត់មករកទីកន្លែងនៅក្នុងគ្រួសារប៉ាវនេះ ហើយប្រកបរបរជាមេសាលារៀនឯកជន ។

សុខភាពអ្នកស្រីហារីការិន ក៏បានស្រួលដូចដើមវិញជាយូរដែរមកហើយ ប៉ុន្តែការដែលមកតាំងនៅតែឯងឆ្ងាយពីញាតិមិត្ត ក៏ធ្វើឲ្យអ្នកព្រួយដូចជាមានជម្ងឺប្រចាំកាយដែរ ។

ក្រោយពីបានអញ្ជើញភ្ញៀវឲ្យចូលទៅក្នុងបន្ទប់មួយនៅក្បែរកនហាលហើយ លោកមាដើរចូលទៅរកប្រពន្ធគាត់ ដែលកំពុងតែរៀបចានឆ្នាំងហាលថ្ងៃ មានបង្អែរស្រូវនៅក្បែរខ្លួនផង ។

– ឯងនេះចេះតែអ៊ុចឹង ហាមមិនស្ដាប់សោះ អាកាសត្រជាក់យ៉ាងហ្នឹងហើយ មកនៅកណ្ដាលវាលគ្មានក្រមារមួយគ្របខ្លួនទៀត ។

– អូនមិនត្រជាក់ ? ក្ដៅចង់របកខ្លួនទៅហើយមិនតិចទេ ។

— បើអ៊ុំចង់ទិញកូនវិញមែនទេ ?

— ហ្នឹងហើយ ចាំខ្ញុំទិញមួយ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ដឹងថាឯងទៅមានការអ្វីក៏យូរម្ល៉េះ ?

—ទេ ! មានរឿងវែងណាស់ កុំអាលចង់ដឹង មកនេះសិន មានមិត្តគេមកលេង ហើយយើងត្រូវទទួលគេ .....

មិនមែនទើបតែម្តងនេះទេ ដែលលោកមានាំភ្ញៀវមកឲ្យប្រពន្ធប៉ុន្តែមុន ៗ មានមកតែម្នាក់ ៗ ម្តងនេះឃើញគ្នាច្រើន អ្នកស្រីផ្ទះមាត់ថា :

—យើដល់ទៅបីនាក់ម្ល៉េះ ឲ្យគេនៅត្រង់ណា ?

—ទេ ទៅជួបនឹងគេសិនទៅ រួចសឹមយើងគិតរៀបចំឲ្យគេនៅត្រង់ណា ៗ សិលាទៅណាហើយ ?

—កំពុងតែដូតទឹកឲ្យក្មេង ៗ

បន្ទាប់មកលោកមាក៏នាំប្រពន្ធគាត់ចេញទៅទទួលភ្ញៀវ នាងកាមាលាធ្វើគារវកិច្ចចំពោះស្រីមេផ្ទះតាមអាយុរបស់ខ្លួន ៗ អ្នកស្រីមេផ្ទះយកដៃស្ទាបចង្ការនាងហើយ បែរទៅនិយាយនឹងប្តីថា :

—នាងនេះមុខដូចពិចកូនយើងណាស់ ពុកអា !

ពិចជាកូនច្បងរបស់គាត់ ដែលមានប្តីទៅនៅឯអាឡាហាបាដ ៗ លោកមាប្រាប់ប្រពន្ធគាត់ថានាងនេះដូចពិចគាត់ស៊ើបខ្ទិប ព្រោះពុំគ្មានដូចអ្វី

បន្តិចសោះ ប៉ុន្តែប្រពន្ធគាត់ឲ្យតែឃើញអ្នកណាល្អ ចូលចិត្តតែជាដូចកូនគាត់ៗ បើសិនជាយកនាងស័ណា មកប្រដូចនឹងនាងកាមាលាឃើញថានៅក្រោមគេទៅហើយ ម៉្លោះហើយដើម្បីមានប្រៀបជាងគេ គាត់តែងតែយកមនុស្សដែលគេពុំដែលឃើញមកប្រដូច ដើម្បីបំបាត់មាត់គេ ។

- ខ្ញុំមានសេចក្តីត្រេកអរណាស់នឹងបាននាងមកនៅជាមួយ ប៉ុន្តែខ្ញុំខ្លាចតែគ្មានប្រដាប់គ្រប់គ្រាន់ តាមសេចក្តីត្រូវការរបស់នាង ៗ ផ្ទះថ្មីរបស់ខ្ញុំរៀបចំមិនទាន់ហើយ បានជានាំគ្នាមកនៅប្រជ្រៀតគ្នានៅទីនេះ ៗ

តាមពិតលោកមាមានផ្ទះថ្មីមួយខ្នងមែន សំរាប់គាត់លក់ដូរ ប៉ុន្តែផ្ទះនោះ គ្មានកន្លែងនៅស្រួលបានទេ លុះលោកមាឃើញគាត់ប្រពន្ធអួតប្រាប់គេថា មានផ្ទះថ្មី ធ្វើមិនទាន់ហើយគាត់ចង់សើច តែគាត់មិនបន្ទុចបង្អាក់ប្រពន្ធគាត់ទេ រួចគាត់ងាកទៅនិយាយនឹងនាងកាមាលា :

ខ្ញុំសង្ឃឹមថានាងនឹងមិនទាស់អំពីការខ្វះខាតនេះទេមែនទេ ? ឯណាបារ៍ ឯងល្អពេកកន្លែងជ្រក ហើយព្រះអាទិត្យមិនមែនផ្តល់ផលល្អដល់ឯងទេ

បារើយ គាត់ក៏ចេញទៅរកមេស្រុក ទុកអ្នកស្រីហារីកាកិទឡៀនៅតែពីរនាក់នឹងនាងកាមាលា ៗ ធ្មៀតទុកាលស្ងាត់នោះ អ្នកស្រីចង់ដឹងណាស់ [illegible] :

— លោកប្តីនាងធ្វើជាមេឃុំឬ ? លោកធ្វើប៉ុន្មានឆ្នាំហើយ ? មួយខែៗបានចំណូលប៉ុន្មានទៅដែរ ?

ចាំ! លោកពុំទាន់បានធ្វើទៅទៀតទេ? ប៉ុន្តែបើលោករករបរធ្វើទៅ? ឪពុកម្តាយលោកទុកទ្រព្យសម្បត្តិច្រើនឬ? ម៉េចក៏នាងមិនដឹង? ដូចជាអស់សំណើច ម៉េចក៏ទៅជាមិនដឹងរឿងគ្រួសារប្តីនាងទៅវិញ គេឲ្យមានមួយខែប៉ុន្មាន បំពង់បាតបែកផ្ទះសំបែង? នាងគ្មានម្តាយក្មេក មុខជាត្រូវធ្វើការស៊ីខ្លួនឯងតាំងពីអស់ហើយ នាងនៅក្មេងយ៉ាងនេះមុខជា ធុញទាល់ហើយ ប្តីពូកូនស្រីខ្ញុំ គេប្រគល់ប្រាក់ដែលគេរកបានតាំងប៉ុន្មានឲ្យកាន់តាំងអស់ . . . ៗ

លុះឮសំដីនិយាយក៏យកប៉ះសព្វគ្រប់ពីស្រីជាមេផ្ទះ នាងទើបឃើញថាខ្លួននាងគ្មានលក្ខណៈជាមេផ្ទះសោះ បើសំគាល់មើលការរស់នៅសព្វថ្ងៃជាមួយនឹងកម្ម ព្រោះថា នាងគ្មានដឹងអ្វីពីគេទាំងអស់ទាំងអតីតប្រវត្តិរបស់គេ តំណរបស់គេ ទាំងគ្រួសាររបស់គេ ក៏នាងមិនស្គាល់ លុះនឹកឃើញដូច្នេះ នាងទៅជាភៀនកើតឬមួយមាត់មិនរួច ៗ ឃើញនាងមិនសូវចុះចមាត់ក ក្មេកស្រីនោះគិតតែស្ងាត់ថែម? ម៉េលក៏កងដៃ នាងគង់នេះបានបើ [illegible] ឲ្យ នាងបានប្តីនុ! នាងត្រូវដឹង ប្តីកូនស្រីខ្ញុំគេចាំរក្រក់ ដើម្បីនឹងទិញឥវ៉ាន់ឲ្យប្រពន្ធគេជាប់រហូត . . . នាងស្តាប់ឮដាក់ដៃក្មេងស្រីម្នាក់ចូល

មក សំទូរក៏ត្រូវដាច់ ៗ ក្មេងស្រីតូចនោះ មានអាយុប្រហែលជាពីរឆ្នាំ គឺជាកូននាងសិលាជា ៗ នាងសិលាជាមានមុខមាត់មិនល្អប៉ុន្មានទេ នាងមានសម្បុរខ្មៅ តែនាងមានទឹកមុខស្រស់បស់ ហើយមានថ្ងាសទូលាយ ៗ

ចំណែកកូមីជាកូននាងសិលាជា នាងក្រឡេកមើលភ្ញៀវ ហើយនិយាយទៅកាន់នាងកាមាលាថា:

„ ជំរាបសួរអ្នកមីង „ ៗ នាងកូមីដែលហៅនាងកាមាលាថាអ្នកមីងនោះ មិនមែនមកពីឃើញនាងដូចម្ដាយមីងវាទេ គឺមកពីនាងតូចនេះមានទម្លាប់ដូច្នេះ គឺថាឲ្យតែឃើញស្រីណាបែបសមរម្យគេហៅមីងទាំងអស់ ៗ

អ្នកស្រី ហារីកាតិទី ថយទៅរៀបចំកន្ទេលជូនភ្ញៀវ ៗ នាងសិលាជាក៏ដឹកដៃនាងកាមាលាចូលទៅក្នុងបន្ទប់ខ្លួន មិនយូរប៉ុន្មានស្រីទាំងពីរនាក់នោះក៏ស្និទ្ធស្នាលនឹងគ្នា ដូចជាមិត្តចាស់យូរមកហើយ ៗ ថ្វីបើនាងសិលាជាមានអាយុច្រើនជាងនាងកាមាលា ប៉ុន្តែនាងកាមាលាមានគំនិតទូលាយ ហើយមានយោបល់ល្អសមរម្យដូចមនុស្សមានវ័យច្រើន ៗ ការដែលមានគំនិតទូលាយបែបនេះ ប្រហែលមកអំពីនាងមិនទាន់ដែលត្រូវមានក្ដីយកក្សិយក្ខចិត្តកំនិនគេ រករឿងទៅមើលទៅ ៗ ព្រោះនាងមិនទាន់មានស្នេហណាក៏ក្ដីស្នេហបាន :

“ នែ ពិសពេលសំខ្ពីងទៅ ធ្វើការដែលគេបង្គាប់ឯនេះ” ឬក៏ថា :

នែ! ក្មេង អើបនិងឲ្យរបស់ប្រកែកញ្ញូលទៅណា” ហេតុដូច្នេះហើយបាន

ជានាងហ៊ានឈមមុខរកសង្គមមនុស្ស ដោយមានបុកការក្រើត បំផុត បុប្ផាមួយទងដែលបញ្ចេញសម្រស់បប្រឹមនៅចុងទងយ៉ាងខ្ពស់លើវៃ ។

ក្រោយពីការស្ងៀមស្ងាត់ពន្ធិចមក នាងសិលាជាក៏ចាប់រាប់រៀបអំពី ប្ដីនាងឈ្មោះប៊ីតីន ដែលធ្វើការនៅកេងស្ពូអាកៀន ។ លោកមារយ៉ង់ មានកូនស្រីតែពីរនាក់គត់ នាងបងបានទៅតាមប្ដី ឯនាក់ប្អូន ដើម្បីកុំឲ្យនាងចេញទៅឆ្ងាយអំពីគាត់ គាត់សុខចិត្តឲ្យនាងទៅបុរសម្នាក់ក្រ ហើយសុខចិត្តទទួលផ្គត់ផ្គង់គ្រួសារកូនគ្រប់បែបយ៉ាងទាំងអស់ កុំឲ្យតែចេញពោលគាត់ ។

(នៅមានត)

# កម្រងចំរៀងបុរាណខ្មែរ

សហ. លី-ធាមតេង ប្រមូលក្រង

## [ តពីលេខមុន ]

ក្នុងទស្សនាវដ្ដីលេខមុន យើងបានបង្ហាញចំនុកបុរាណខ្លះជាចំនុកបែបប្រៀនផ្ដាំផ្ដើ ប្រុស-ស្រី [illegible] ដឹងតាមសៀវភៅខ្លះដែលតម្កល់នៅពុទ្ធសាសនបណ្ឌិត្យ [illegible] នោះ យើងសូមបង្ហាញតទៅទៀត នូវចំនុកប្រភេទដូចគ្នា ហើយយើងនឹងចាំរកនឹងជូនអត្ថបទជាកំណត់បងចាំចំនុកប្រៀនពីគ្រប់មន្ទីរ [illegible] របស់យើង តាមសេចក្ដីអំពាវនាវរបស់យើង ដែលចុះផ្សាយក្នុងលេខមុនរួចហើយ ។

### ទំនុកខ្លះៗ ដែលយើងប្រមូលបាននោះ ដូចតទៅ :

ប្រុស- បង្កើតដែល [illegible] ក្រពើដែល [illegible]

ស្រីដែលបងស្រែក [illegible] ប្រុះខ្មៅខ្មៅណា ។

បានឧទ្ទេសក៏ប្រែ ប្ដូរកបម្ការ

បានខ្មៅខ្មៅណា បងលិស្នាតាម ។

ក្រាងក្រុំបាត្ត ក្រញូញក្រុំបំគាម

[illegible] [illegible]

[illegible] [illegible]

ដើរតាមដងព្រៃ　　ផ្កាធ្លាយទ្រគម　　ៗ

បានដល់មាត់ព្រែក　　ព្នៃខ្ញុំកាយ

ដើរដល់ដើមក្ទុំ　　ពួរសោកនិយាយ　　ៗ

ពួស្ទួរស្ទើយ ៗ　　ដោយតាមព្រះពាយ

មាត់សោកនិយាយ　　ហាកសារម្ទស្រី　　ៗ

សំទៀនទឹកហូរ　　រាគរំពេះភ្ញី

បងស្រវៃមើញស្រី　　ហាក់ថ្លៃនៈដែក　　ៗ

បងឈានជើងដើរ　　ខ្ញុំស្ទុះស្ទៃនែក

តាមដោយជ្រងព្រែក　　ចិត្តបងសែនខ្វល់　　ៗ

បងផ្តាំតាមទឹក　　ទឹកហូរមិនដល់

បងផ្តាំតាមខ្យល់　　ខ្យល់ត់គំញាណ　　ៗ

(តាមការចងចាំរបស់ សមា. ហ្គូច - ភុម)

(ប្រុស)- ផ្គរលោះត្លៀសាន　　ព្រានទៅអគ្គយ៍

ស្រីយកប្តី គ　　បានបុណ្យផលចាស់　　ៗ

(ស្រី) ស្រីណាកំផា　　ស្រីហ្វីនកម្ប្រាស់

បានបុណ្យផលចាស់　　បានប៉ះឡូប៉ៃចិន　　ៗ

×

កាប៉ិចៗអើយ / ក្តិចទ្រយល្ហុន

សន្ទូមន្ទូន់ / ជូនបាយអាថាំង

អាថាំងៗអើយ / ដេកកៀនជញ្ជាំង

ត្រអើកក្តុងក្តាំង / កាប៉ិចវាលូក

×

(ម៉ែ)- កាតុបម៉ែអើយ / ម៉ែឲ្យចាំតា

រវល់ទៅណា / តាស៊ីស្រូវអស់

(ក្មេង)- អ្នកម៉ែឪកូន / កូនទៅកាប់ឧស

ចំបាប់នឹងប្រុស / ចាក់ព្រមួយល្វែង ។

បើម៉ែមិនជឿ / ទៅសួរជូនប្រែង

ដំបូកដើមស្នែង / កន្ទែងក្តៅៗ ។

(តាមការចងចាំរបស់អ្នកស្រី ពេជ-សល់)

ស្រអែមខ្មៅស្មើរ / ស្រអែមខ្មៅស្មើរ

បងប៉ាំងដៃមើល / ស្រអែមមានទ្រូង ។

កុកហើរលើមេឃ　　ផែនដីជាប់ផង់
ស្រអែមមានទ្រង់　　ផែនដីដៃបង ៗ
ស្រអែមខ្មៅម៉ដ្ឋ　　ស្រអែមខ្មៅម៉ដ្ឋ
មេកងឡើងកក់　　ស្រអែមរៀបខ្លួន ៗ
រៀបចាំងកន្ទេលចិន　　រៀបចាំងកន្ទេលយួន
ស្រអែមរៀបខ្លួន　　ទទួលមេកង ៗ
ស្រីចាបព្រៃ　　ស្រីចាបទ្រៃ
ដើរដោយក្ដីស្រែ　　ស្រែងបាំងបាត់ ៗ
បងមានស្នាគើ　　បងគេទៅស្កាត់
ស្រែងបាំងបាត់　　បាត់ខ្មៅបងហើយ ៗ

×

ប្រុស - បារីបងបាច់　　ស្វាវេចកន្ទេង
សង្សារបងមិនលែង　　ស៊ូបងប្រពន្ធ ៗ
ស្រី - បារីបងបាច់　　ស្វាវេចកន្ទេង
បើបងបងលែង　　ជូនប្អូនទៅម៉ែ ៗ
បងទៅស្រុកក្រុង　　ប្អូនទៅស្រុកស្រែ
ជូនប្អូនទៅម៉ែ　　ទៅស៊ីក្ដាមខ្យង ៗ

×

ប្រុស- សារិកាកែវអើយ　　សារិកាកែវកើប
បងលោមឲ្យស៊ើប　　គ្រាន់មើលជើងឆ្នេញ ៗ
បងមើលជើងសក់　　រត់ផ្លូវរមេញ
បងមើលជើងឆ្នេញ　　ឆ្នេញត្រឹមខ្មៅស្រិល ៗ

×

ស្រី- អ្នកប្រុសខ្លួនលទ់　　អ្នកប្រុសខ្លួនលទ់
ខ្លួនឥតប្រពន្ធ　　ធាក់ស្លាដៃឯង ៗ
ធាក់ទៅធាក់មក　　ដូចគេប្រឡែង
ធាក់ស្លាដៃឯង　　ប្រណាំកមុតដៃ ៗ

×

ប្រុស- ស្រឡាញ់សក់ជ្រង　　ដូចទង់ពោក
ស្រឡាញ់សក់ផ្កាក់　　ដូចសក់សារិកាកែវ ៗ
ស្រីសដើរមុខ　　ស្រីខ្មៅដើរក្រោយ
ផានណាតាតឲ្យ　　សំពោងផ្កាថ្កូវ ៗ
តាំងពីរងរកើយ　　ទន្ទឹមដូចក្លូក
ពីរកៃកម្មុខ　　ដង្ខួនដូចគ្នា ៗ
ស្រីសាដេដារ　　ស្រីខ្មៅដេកខ្នើយ
បងត្រូវ[illegible]　　បងយកទាំងពីរ ៗ

ស្រីសដេរនើប ស្រីខ្មៅដេរខុន
ដាក់មុខស្រពោន ខឹងអ័ទឹងបង ៗ
ម្ជុលតែបាក់ ចិត្តោមតែបង
ដេរស្បៃឲ្យបង បងលាទៅបួស ៗ

(តាមការចងចាំរបស់លោក កែវ-ហង្ស
ឯកសារទំនៀមទម្លាប់ លេខ ៦៨-០៣២)

ប្រុស - ស្រីអើយនាងស្រី ទៅណាមកណី
ចូលមកស៊ីស្លា បងសួរដំណេក
ស្រីដេកគ្រន់ណា ចូលមកស៊ីស្លាជាមួយនឹងបង ៗ
ពៅអើយស្រីពៅ ពៅអើយស្រីពៅ
ពេលល្ងាចបងទៅ ស្រីចាប់ខ្នែផង ៗ
នាងចាប់អាលុក វាទៅអាគ្រង
ស្រីចាប់ខ្នែផង ព្រលប់ចង់ដល់ ៗ

ស្រី - អ្នកហាក់ដាំនេះ មុខគួរឲ្យឆ្ងល់
ព្រលប់ចង់ដល់ ដល់កន្លែងណា ៗ
អ្នកដល់ដីដូន ឬដល់ដីតា
ដល់កន្លែងណា វាចាប្រាប់អូន ៗ

ប្រុស - នាងអើយនាងស្រី នាងអើយនាងស្រី

បើនាងយកប្ដី    ស្រីកុំពោលបង    ។
ដាក់ប្ដីពីមុខ    ដាក់បងពីខ្នង
ស្រីកុំពោលបង    សង្សារយូរហើយ    ។

(ប្រមូលបានពី BEFEO ឆ្នាំ ១៩៤១ ដែលនិយាយពី
ចម្រៀងជនជាតិសម្រែនិងព័រ)

ផ្នែកកំណត់-ប្រវត្តិការណ៍

# ព្រះរាជជីវប្រវត្តិ

## នៃសម្ដេចព្រះមហាសុមេធាធិបតី (ជួន-ណាត) ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ

សម្ដេចបានប្រសូត្រនៅថ្ងៃអង្គារ ១១ រោច ខែផល្គុន ឆ្នាំវក ធស័ក ព.ស. ២៤២៧ គឺថ្ងៃទី ១១ មីនា គ.ស. ១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បិតានាម ជួន មាតានាម យក់ (គ្រួសារនេះមានបុត្រតែពីរគត់គឺ សម្ដេច ហើយនិងឧកញ៉ាសោភណមន្ត្រី ជួន ឈុត ជាប្អូន របស់សម្ដេច) ។

កាលនៅជាកុមារ បានសិក្សាអក្សរ និងលេខ ដរាបដល់ជន្មាយុ ១៤ ឆ្នាំ បានបួសជាសាមណេរ ក្នុងថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំ ចសំរិទ្ធិស័ក ព.ស. ២៤៤១ (ឧសភា គ.ស. ១៨៩៧) នៅវត្តពោធិព្រឹក្ស (ហៅវត្តពោល្យំ) សង្កាត់លាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ បួសជាសាមណេរបានពីរឆ្នាំ (ក្នុង ព.ស. ២៤៤៣ គ.ស. ១៨៩៩) សម្ដេចបានចូលសិក្សាព្រះបរិយត្តិធម៌ នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ លុះបានជន្មាយុគម្រប់ ២១ ឆ្នាំ នៅថ្ងៃ ១៤ កើត ខែជេស្ឋ ឆ្នាំរោងឆស័ក ព.ស ២៤ ៨ (មិថុនា ១៩០៤) សម្ដេចបានទៅសូមបំពេញឧបសម្បទាជាភិក្ខុនៅវត្តពោធិព្រឹក្ស ដែលជាវត្តដើម មានព្រះតេជព្រះគុណព្រះទុ-

ឃោសាចារ្យ ម៉ា កោត សុវណ្ណបញ្ញោ កាលនៅជាចៅអធិការវត្តពោធិព្រឹក្ស ជាព្រះឧបជ្ឈាយ៍ ព្រះតេជព្រះគុណ កែវ ម៉ម មិស្សធាគោ ជាគ្រូសូត្រកម្មវាចាចារ្យ និងព្រះតេជព្រះគុណ អ៊ុង ចឹម កិត្តិបញ្ញោ ជាគ្រូសូត្រអនុសាវនាចារ្យ ។ សម្តេចបានទ្រង់ទទួលព្រះនាមបញ្ញត្តិថា ជោតញ្ញាណោ ។ បានទ្រង់បំពេញជាភិក្ខុហើយសម្តេចនិមន្តត្រឡប់មកគង់នៅវត្តឧណ្ណាលោមវិញ ។

## បំណេះវិជ្ជា និង កិច្ចការដែលសម្តេចទ្រង់បាន បំពេញក្នុងព្រះពុទ្ធសាសនា

ក្រៅអំពីភាសាខ្មែរ ដែលសម្តេចទ្រង់បានស្រាវជ្រាវយល់ដល់ឫសគល់ពិតប្រាកដ សម្តេចបានសិក្សាភាសាបាលី អាចអានឬសន្ទនាតាមសំនៀងជាតិបរទេសទាំងអស់ គឺសំនៀង លង្កា ភូមា មន សៀម និង លាវ បានឥតមានទើសទាក់ ។

នៅ ព.ស. ២៤៦៦ និង ២៤៦៧ គ.ស. ១៩២២ និង ១៩២៣ សម្តេចកាលនៅជាព្រះគ្រូសំសត្ថា (ជាមួយសម្តេចព្រះសង្ឃនាយក ហួត តាត វជីរប្បញ្ញោ កាលនៅជាព្រះគ្រូសំវិជ្ជា) បាននិមន្តទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និង អក្សរសិលាចារឹកជាដើម នៅសាលាបារាំងសែសចុងបូព៌ាប្រទេស នៅក្រុងហាណូយ (វៀតណាមខាង

ដើង ) ក្នុងសំណាក់លោកល្វី-ហ្វីណូត៍ (ជាតិបារាំងសែស) ជាចាងហ្វាងសាលានេះ ។

សម្តេចទ្រង់ចេះអក្សរនិងភាសាសៀម ភាសាលាវ យ៉ាងជាក់លាក់ និងភាសាបារាំងសែសល្អប្រាស្រ័យការបាន ដោយសំនៀងត្រូវសរសេរភាសាអង់គ្លេស និងភាសាវៀតណាមផង ។

នៅ ព.ស. ២៤៥៧ គ.ស ១៩១៣ សម្តេចទ្រង់បានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោសថរតនារាម វិហារព្រះកែវមរកតក្រុងភ្នំពេញ ចំពោះព្រះភក្ត្រ ព្រះករុណា ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ បាន ៤ ប្រយោគ ដែលជាប្រយោគជាន់ខ្ពស់បំផុតក្នុងសម័យនោះ ។

ព.ស. ២៤៥៩ គ.ស ១៩១៥ សម្តេចទ្រង់បានប្រឡងជាប់ លេខ ២ បានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃមានឈ្មោះថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

ព.ស. ២៤៦៣ គ.ស. ១៩១៩ សម្តេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិការកាន់កិច្ចការផ្ទាល់ លុះត្រាបានចប់ចុងចប់ដើម ។

ព.ស. ២៤៦៩ គ.ស. ១៩២៥ សម្តេចបានធ្វើជាសមាជិកនៃក្រុមជំនុំពិនិត្យសេចក្តីខុសត្រូវ នៃសៀវភៅនានាដែលសាលាបាលីជាន់ខ្ពស់បោះពុម្ពផ្សាយ ។

ព.ស. ២៤៧០ គ.ស. ១៩២៦ តមកជាច្រើនឆ្នាំ សម្តេចទ្រង់បានទទួលការតែងតាំងជាមេប្រយោគ ក្នុងការប្រឡងយកវិញ្ញាបនបត្របឋមសិក្សាខ្មែរ(១) នៅក្រុងភ្នំពេញ ។

ព.ស. ២៤៧១ គ.ស. ១៩២៧ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំផ្ទៀងសម្រេចវចនានុក្រមខ្មែរ ហើយសម្តេចទ្រង់បានទទួលភារៈ ធ្វើវចនានុក្រមតែមួយព្រះអង្គឯង ដរាបដល់បានចប់សព្វគ្រប់ ក៏បានបោះពុម្ពផ្សាយទាំងភាគ ១ ទាំងភាគ ២ ។

ក្នុងឆ្នាំដដែល នេះ សម្តេចបានទ្រង់ទទួលការតែងតាំងជាសមាជិកនៃក្រុមអភិបាលជំនុំផ្តាច់ឆ្នាំ សម្រាប់ព្រះរាជបណ្ណាល័យកម្ពុជា ដែលសព្វថ្ងៃនេះហៅថា "បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ" ។

ព.ស. ២៤៧៤ គ.ស. ១៩៣០ សម្តេចបានទ្រង់ទទួលការតែងតាំងក្នុងមុខងារជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ។

ក្នុងឆ្នាំដដែលនោះ សម្តេចបានទ្រង់ទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។

ព.ស. ២៤៧៦ គ.ស. ១៩៣២ សម្តេចបានទ្រង់ទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំ ខាងការស្រាវជ្រាវ ជ្រើសរើសរកពាក្យពេចន៍ក្នុងផ្នែកនៃកវីនិពន្ធខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះទៅក្នុងវចនា-

---

១. គឺជា ការប្រឡងយកសញ្ញាបត្របឋមសិក្សាជាន់ខ្ពស់បារាំង-ខ្មែរ ។

នុក្រមខ្មែរ ។

ព.ស. ២៤៧៧ គ.ស. ១៩៣៣ សម្តេចបានទ្រង់ទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅ ដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ។

ព.ស. ២៤៧៨ គ.ស ១៩៣៤ សម្តេចបានទ្រង់ទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀបនឹងពាក្យបារាំង សំរាប់ប្រើក្នុងកិច្ចការរាជការ ។

ព.ស. ២៤៧៩ គ.ស. ១៩៣៥ សម្តេចបានទ្រង់ទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹត ខ្មែរ និងលាវ ប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សា នៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ។

ព.ស. ២៤៨៦ គ.ស. ១៩៤២ សម្តេចបានទ្រង់ទទួលការតែងតាំងជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ (ដែលសព្វថ្ងៃកែប្រែឈ្មោះជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត) ។

ព.ស. ២៤៨៨ គ.ស. ១៩៤៤ សម្តេចបានទ្រង់ទទួលតំណែងជាចៅអធិការ វត្តឧណ្ណាលោម ។

ព.ស. ២៤៨៩ គ.ស. ១៩៤៥ សម្តេចបានទ្រង់ទទួលនាទីជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់ព្រះសង្ឃ ។

ព.ស. ២៤៩១ គ.ស. ១៩៤៧ សម្ដេចបានទ្រង់ទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធម៌ ផ្នែកអក្សរ "ក" នៃគណៈកម្មការជាតិខាងការសិក្សា ។

ព.ស. ២៤៩២ គ.ស. ១៩៤៨ សម្ដេចបានទ្រង់ទទួលនាទីជាប្រធាននៃគណៈកម្មការធម្មវិន័យ ពិនិត្យការផ្សាយសៀវភៅសម្រាប់សាលាធម្មវិន័យ ក្នុងព្រះរាជាណាចក្រ ។

គ.ស. ១៩៦១ រហូតមក សម្ដេចទ្រង់ព្រោសមេត្តាទទួលនិមន្តពីសមាគមអ្នកនិពន្ធខ្មែរធ្វើជាព្រះប្រធាន នៃសម្ភាសន៍អក្សរសាស្ត្រផ្សាយតាមវិទ្យុរៀងរាល់ថ្ងៃសុក្រ ។

គ.ស ១៩៦៨ ទ្រង់ទទួលព្រះឋានៈជាប្រធានគណៈកម្មការពិនិត្យស្នាដៃអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្ត្រខ្មែរ ។

គ.ស. ១៩៦៩ ព្រះអង្គទ្រង់ទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យ និងកំណត់អំពីន័យរបស់ទង់ជាតិខ្មែរ ។

## ព្រះកិច្ចការដែលសម្ដេចទ្រង់បានបំពេញ
## ក្នុងព្រះពុទ្ធសាសនានៅបរទេស

នៅ ព.ស. ២៤៧៩ គ.ស ១៩៣៦ សម្ដេចបានទ្រង់ដឹកនាំគណៈប្រតិភូនៃមន្ត្រីសង្ឃទៅកាន់ក្រុងវៀងចន្ទន៍ និងក្រុងហ្លួងព្រះបាង

ប្រទេសលាវ ដើម្បីប្រជុំមកុដពិធីសម្ពោធពុទ្ធសាសនបណ្ឌិត្យ ប្រទេសលាវផង ដើម្បីជំនុំពិភាក្សាអំពីការសិក្សា សម្រាប់សាលាបាលីរងនៅប្រទេសលាវផង ។

នៅ ព.ស ២៤៧៧ គ.ស. ១៩៣៣ សម្តេចបានទ្រង់ដឹកនាំគណៈប្រតិភូព្រះសង្ឃខ្មែរទៅធ្វើទស្សនាចរណ៍ បំពោះវត្តខ្មែរទាំងឡាយក្នុងដែនកូសាំងស៊ីន (ប្រទេសវៀតណាមខាងត្បូង) ។

នៅ ព.ស. ២៤៨៣ គ.ស. ១៩៣៩ សម្តេចបានទ្រង់ដឹកនាំគណៈប្រតិភូមួយទៅកាន់ប្រទេសលាវម្តងទៀត ដើម្បីប្រជុំប្រឹក្សាកិច្ចការនៃពុទ្ធសាសនបណ្ឌិត្យ ប្រទេសលាវ និងការសិក្សាសម្រាប់សាលាបាលីនៅប្រទេសលាវផង ដើម្បីជួយរំលឹកដាស់តឿនប្រជាជាតិលាវនៅក្នុងទីប្រជុំជន ក្នុងខេត្តនានា នៃព្រះរាជអាណាចក្រលាវ ឲ្យចំប្រឹងយកចិត្តទុកដាក់ក្នុងការសិក្សានិងការប្រតិបត្តិ ឲ្យបានត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនាផង ។

នៅ ព.ស. ២៤៨៦ គ.ស. ១៩៤៣ សម្តេចបានទ្រង់ទទួលនាទីជាសមាជិកឆ្លើយឆ្លងនៃសាលាបារាំងសែស នៅចុងបូព៌ាប្រទេស ហើយនៅ ព.ស. ២៤៩២ គ.ស. ១៩៤៨ សម្តេចបានទ្រង់ទទួលនាទីជាសមាជិកកិត្តិយស នៃសាលានេះ ដរាបរៀងមក ។

នៅ ព.ស. ២៤៩៤ គ.ស. ១៩៥០ សម្តេចបានទ្រង់ដឹកនាំ

គណៈប្រតិភូខ្មែរទៅប្រជុំសន្និសីទ ដើម្បីបង្កើតពុទ្ធិកសមាគមពិភពលោក នៅក្រុងកោឡម្បូ លង្កាទ្វីប ។

នៅ ព.ស. ២៤៩៧ គ.ស. ១៩៥៣ សម្ដេចបានទ្រង់ដឹកនាំគណៈប្រតិភូខ្មែរ ទៅបំពេញបេសកកម្មសុឆន្ទៈ ប្រឹក្សាសម្រេចរឿងធ្វើឆដ្ឋសង្គាយនាទៅក្រុងរង្គូន សហភាពភូមា ។

ក្នុងឆ្នាំជាបន្ទាប់ នៅ ព.ស. ២៤៩៨ គ.ស. ១.៩៥៤ សម្ដេចបានទ្រង់ដឹកនាំគណៈប្រតិភូខ្មែរ និមន្តទៅកាន់ក្រុងរង្គូន ប្រទេសភូមា ម្ដងទៀត ដើម្បីរួមក្នុងការប្រជុំធ្វើឆដ្ឋសង្គាយនា សម័យប្រជុំដំបូង ។

ក្នុងមួយឆ្នាំក្រោយមក ព.ស. ២៤៩៩ គ.ស. ១៩៥៥ សម្ដេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរ ទៅកាន់ឆដ្ឋសង្គាយនា ក្រុងរង្គូន ប្រទេសភូមា ជាលើកទីបី ដើម្បីប្រជុំហើយបិទសម័យប្រចាំឆ្នាំ ។

នៅ ព.ស. ២៥០៣ គ.ស. ១៩៥៩ សម្ដេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ក្រុងជាការតា និងក្រុងស៊ីម៉ារ៉ាំង កោះជ្វា ប្រទេសឥណ្ឌូណេស៊ី ដើម្បីរួមក្នុងពិធីបុណ្យវិសាខបូជា ព.ស. ២៥០៣ ពិធីបញ្ចុះខណ្ឌសីមា និងពិធីសន្មតកេនឧបោសថ ព្រមទាំងជាព្រះឧបជ្ឈាយ៍បំបួសកុលបុត្រ អ្នកប្រទេសនោះចំនួនបីរូបផង ។

## សមណស័ក្តិដែលសម្ដេចបានទទួលជាលំដាប់

ដោយព្រះរាជការិយកិច្ចការផ្សេងៗ ដែលសម្ដេចបានទ្រង់បំពេញ

ក្នុងព្រះពុទ្ធសាសនានោះ សម្ដេចក៏តែងបានឡើងសមណសក្តិជាលំដាប់លំដោយដូចតទៅនេះ គឺ :

ព.ស. ២៤៥៤ គ.ស. ១៩១០ សម្ដេចបានទទួលការតែងតាំងក្នុងសមណសក្តិជាព្រះបាឡាត់សាក្យបុត្តិយ៍ (បាឡាត់របស់ព្រះសាក្យវង្ស ឈុន វត្តឧណ្ណាលោម) ។

ព.ស. ២៤៥៦ គ.ស. ១៩១២ សម្ដេចបានទទួលសមណសក្តិជាព្រះគ្រូសង្ឃសត្ថា (ទីបាំអនុក្រមសម្រាប់ឯក របស់សម្ដេចព្រះមហាសង្ឃរាជព្រះទាម (ទៀង)) ។

ព.ស. ២៤៧៤ គ.ស. ១៩៣១ សម្ដេចបានឡើងសមណសក្តិជា ព្រះសាសនសោភ័ណ (រាជាគណៈកិត្តិយស) ។

ព.ស. ២៤៨៤ គ.ស. ១៩៤០ សម្ដេចបានឡើងសមណសក្តិជាព្រះពុទ្ធឃោសាចារ្យ (រាជាគណៈថ្នាក់ទី ២) ។

ព.ស. ២៤៨៨ គ.ស. ១៩៤៤ សម្ដេចបានឡើងសមណសក្តិជាព្រះពោធិវង្ស (រាជាគណៈថ្នាក់ទី ១) ។

ព.ស. ២៤៩២ គ.ស. ១៩៤៨ សម្ដេចបានឡើងសមណសក្តិជាន់ខ្ពស់បំផុត ជាព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ។

លុះដល់មក ព.ស. ២៤៩៤ គ.ស. ១៩៥០ ព្រះករុណាជាម្ចាស់ជីវិតទ្រង់បានប្រោសប្រគេនព្រះឋានៈ ជាសម្ដេចព្រះមហាសុមេធាធិបតី

សង្ឃនាយកគណៈមហានិកាយ ។

មួយវិញទៀត នៅ ព.ស. ២៤៩៨ គ.ស. ១៩៥៤ រដ្ឋាភិបាលនៃសហភាពភូមា បានប្រគេនព្រះឋានៈសម្ដេច ជាព្រះអគ្គមហាបណ្ឌិតនៃសហភាពភូមា ។

លុះដល់មក ព.ស. ២៥០១ គ.ស. ១៩៥៧ រដ្ឋាភិបាលនៃសហភាពភូមា បានសុំតម្កើងព្រះឋានៈសម្ដេចជា ព្រះអភិធជមហារដ្ឋគុរុនៃសហភាពភូមា ដែលជាសមណសក្តិដ៏ខ្ពង់ខ្ពស់បំផុតមានតែមួយអង្គក្នុងសហភាពភូមា ។

ខែកុម្ភៈ គ.ស. ១៩៦៤ អ្នកនិពន្ធខ្មែរទាំងអស់ បានថ្វាយឋានៈព្រះអង្គជា "ព្រះ អគ្គនិពន្ធអក្សរសាស្ត្រខ្មែរ" និងជាសមាជិកកិត្តិយសនៃសមាគមអ្នកនិពន្ធខ្មែរផង ។

ព.ស. ២៥០៧ គ.ស. ១៩៦៣ សម្ដេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ទ្រង់បានប្រោសប្រគេនព្រះឋានៈសម្ដេចជាសម្ដេចព្រះសង្ឃរាជថ្នាក់ទី១ ។

ថ្ងៃទី ២៨ ឧសភា ១៩៦៧ ទ្រង់បានទទួលសញ្ញាបត្រ "បណ្ឌិតអក្សរសាស្ត្រ" ពេញលក្ខណៈ អំពីសម្ដេចព្រះប្រមុខរដ្ឋ ក្នុងនាមមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ នៃភូមិន្ទសាកលវិទ្យាល័យ ។

# គ្រឿងឥស្សរិយយស

សម្ដេចបានទទួលគ្រឿងឥស្សរិយយសដូចតទៅនេះគឺ :

- មេដាយអស្សឫទ្ធិមុនីសាភករណ៍ នៅ ព.ស. ២៤៦១ គ.ស. ១៩១៧ ។

- មេដាយអស្សឫទ្ធិព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៤៧៦ គ.ស. ១៩៣២ ។

- មេដាយអស្សឫទ្ធិដំរីមួយលាន និង ស្វេតច្ឆត្រ ប្រទេសលាវ នៅ ព.ស. ២៤៧៦ គ.ស. ១៩៣២ ។

- មេដាយ សេនា នៃបណ្ឌិតសភា សាធារណៈរដ្ឋបារាំង នៅ ព.ស. ២៤៨១ គ.ស. ១៩៣៧ ។

- មេដាយអស្សឫទ្ធិ ដឹឡាឡេស្យុងដុណើរ នៃសាធារណរដ្ឋបារាំង នៅ ព.ស. ២៤៨៦ គ.ស. ១៩៤២ ។

- មេដាយ សេនានៃព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៤៨៨ គ.ស. ១៩៤៤ ។

- មេដាយ សេនា ដឹឡាឡេស្យុងដុណើរ នៃសាធារណរដ្ឋបារាំង នៅ ព.ស. ២៤៩២ គ.ស. ១៩៤៨ ។

- មេដាយ មហាសិរីវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៥០៥ គ.ស. ១៩៦២ ។

- មេដាយ មហាសិរីវឌ្ឍសុវត្ថាភ នៅ ព.ស ២៥០៦ គ.ស. ១៩៦៣ ។

- មេដាយ ជាតូបការ ដែលជាគ្រឿងឥស្សរិយយសធំបំផុត ក្នុងព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៥១៣ គ.ស. ១៩៦៩ ។

# កិច្ចការជាស្នាព្រះហស្តនៃសម្តេច

កិច្ចការឯទៀតក្រៅពីមុខការខាងលើនេះ ដែលសុទ្ធសឹងតែជាការមានប្រយោជន៍ជាសាធារណៈក្នុងព្រះពុទ្ធសាសនា និងប្រទេសជាតិនោះនៅមានច្រើនទៅទៀត និយាយដោយសង្ខេប គឺចាប់តាំងពីឆ្នាំជូតសប្តស័ក ព.ស. ២៤៧១ គ.ស. ១៩២៨ រៀងមក សម្តេចបានធ្វើការឧបត្ថម្ភវត្តពោធិព្រឹក្ស (ហៅវត្តពោលព្រំ) ក្នុងសង្កាត់លាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ជាប់គ្នា នឹងឃុំកោះកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាទីជាតិភូមិរបស់សម្តេចដោយសម្តេចបានជាវទីដីជុំវិញវត្ត ចំនួនជាង ៣ ហិកតា ពង្រីកទីវត្តឲ្យធំទូលាយច្រើនជាងពីដើមបានជួយឧបត្ថម្ភលើកថ្កល់ភ្ជាប់ពីថ្កល់ជាតិមកចូលវត្តសុរកី និងវត្តពោធិព្រឹក្ស រួចម្ដាយ ៣ គីឡូម៉ែត្រ បានស្ថាបនាវិហារបេតុងអាគារ៉េសាលាបាលីរង (ពុទ្ធិកបឋមសិក្សា) រៀបចំទីវត្តតាំងមូលឲ្យមានរសកាតសមរម្យតាមសម័យនិយម ស្ថាបនាស្លានធំ ១ និងស្លានតូច ១ សុទ្ធតែ

បេតុងអារម៉េជួងស្ពងតូច កំពង់ប្រវល់ឃុំលាំងកែន និងឃុំកោះកោះ បានឧបត្ថម្ភការស្ថាបនាសាលាបឋមសិក្សាបំពេញវដ្ត "សុភី-ពោធិព្រឹក្ស" ៣ ខ្នង តាំងពី គ.ស. ១៩៦៨ រៀងរហូតដល់សាលារៀននេះ ឡើងដល់ថ្នាក់ឧត្តមដ្ឋាន (សម្រាប់កូនចៅអ្នកស្រុកដើមវត្តសុភី និងវត្តពោធិព្រឹក្ស) បានឧបត្ថម្ភឲ្យដល់លំនោះ បានចាត់គ្រឿងសម្ភារ-ក្រៀម ប្រើការបានដោយស្រួល បានជាវទីដី ៣ ហិកតាកន្លះ បានស្ថាបនាខ្លោងទ្វារបេតុងអារម៉េ ១ បានស្ថាបនា អាសថសាលា (សាលាសំណាក់) ១ ខ្នង បានឲ្យជីកស្រះមួយទំហំ ១០០ ម៉ែត្រ ៤ ជ្រុង ទៅត្រង់ទីទួលបែកចេញទីថ្នល់ជាតិក្នុងឃុំកោះកោះ បានជួយឧបត្ថម្ភឲ្យជីកអណ្តូងយោង ១៦ កន្លែង អណ្តូងបុកប្រើស្នប់ ៣ កន្លែង បានស្ថាបនាគិលានដ្ឋាន ១ ខ្នង ប្រសូតិគ្រឹះ (មន្ទីរសម្ភព) ១ ខ្នង ដោយបេតុងអារម៉េ និងកំពែងបេតុងអារម៉េ បណ្តោយ ១០០ ម៉ែត្រ ទទឹង ៩២ ម៉ែត្រព័ទ្ធជុំវិញមន្ទីរទាំង ២ ខ្នងនេះ បានស្ថាបនា "អគារគ្រូពេទ្យសំណាក់" ក្នុងកំពែងនេះដែរ បានស្ថាបនាអគារបេតុងអារម៉េ ២ ខ្នងក្រៅកំពែងនោះ សម្រាប់គិលានសមណៈ បានចាត់ការឲ្យលើកទំនប់ទឹក ១ កន្លែង បណ្តោយ ៩០០ ម៉ែត្រ ទទឹក ៨០០ ម៉ែត្រ (ដោយសម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសប្រទានព្រះរាជានុញ្ញាតឲ្យលើកទំនប់នេះ) បានឧបត្ថម្ភ

ឲ្យវេយ្យាវច្ចករជាជំណាំលើទីដីខាងលើនេះ ជាប្រយោជន៍ដល់គិលានដ្ឋាន និងប្រសូតិគ្រឹះនៅក្នុងអនាគតកាល (ស្ថាបនកម្មតាំងនេះនៅក្នុងភូមិស្រែបន្ទាយ ឃុំកោះកោះ) បានលះបង់ទីដី ១ កន្លែង ដែលសម្តេចបានថាវ ហើយនោះ ជូនព្រះរាជរដ្ឋាភិបាលឲ្យស្ថាបនាអគារមណ្ឌលទីកម្ម (ប៉ុស្តិ៍ប៉ូលិស) និងមន្ទីររាជសហករណ៍ ។ល។

## កិច្ចការជាស្នាព្រះហស្តខាងអក្សរសាស្ត្រ

សម្តេចបានកសាង គម្ពីរដីកាជាច្រើន ហើយសម្តេចបានប្រែភាសាបាលីរៀបរៀងជាសៀវភៅច្រើនច្បាប់ ។ សៀវភៅដែលកម្រធ្វើកើត ហើយដែលមានប្រយោជន៍ច្រើននោះគឺៈ ។

១. វចនានុក្រមខ្មែរ (មាន២ ភាគ) ក្នុង ព.ស. ២៤៦១ គ.ស ១៩១៩ និងឆ្នាំតៗ មក ។

២- កច្ចាយនត្ថប្ទីបកៈ (វេយ្យាករណ៍បាលីមាន ២ ភាគ) បានធ្វើពី ព.ស. ២៤៦២ គ.ស. ១៩២០ ។

៣- គិហិបដិបត្តិ ក្នុង ព.ស. ២៤៦៨ គ.ស. ១៩២៦ ជាមួយនិងព្រះឧត្តមមុនី អ៊ុំ-ស៊ូ និង សម្តេច ហួត-តាត តាមបញ្ជានៃព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ថោង (ពុទ្ធសាសនបណ្ឌិត្យ) ។

៤. សាមណេរវិន័យ ក្នុង ព.ស. ២៤៦០ គ.ស, ១៩១៧ ជាមួយនិងព្រះថេរៈទាំង ២ អង្គខាងលើនេះដែរ ។

៥- បាតិមោក្ខសង្ខេប (សម្រាយ) ព.ស. ២៤៧០ គ.ស. ១៩២៨

មានសៀវភៅឯទៀតៗ ជាច្រើន ដែលជាការបន្ទាប់បន្សំគឺ :

៦- កាព្យលោកធម៌ បោះពុម្ពដំបូងក្នុង ព.ស. ២៥០០ គ.ស. ១៩៥៧ ។ កាព្យនេះទ្រង់តែងកាលនៅជាព្រះគ្រូសំសត្ថា ។

៧- នាគោបមាទិកថា ព.ស. ២៤៧៥ គ.ស. ១៩៣៣ ។

៨- ព.ស. ២៤៨៤ គ.ស. ១៩៤១ សម្ដេចបានតែងសុភមង្គលគាថាបាលី បញ្ចវគ្គ ៧ គាថា ព្រមទាំងប្រែជាសម្រាយផង សម្រាប់សូត្រថ្វាយ សុភមង្គលសួស្ដី ចំពោះព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុ វរ្ម័ន ។

៩- អត្ថបទផ្សេងៗ ជាច្រើនក្នុងទស្សនាវដ្ដី កម្ពុជសុរិយា របស់ពុទ្ធសាសនបណ្ឌិត្យ តាំងពីឆ្នាំដំបូងតៗ មក ដែលពុំអាចស្រាវជ្រាវមកកប់រៀបក្នុងទីនេះបាន សព្វគ្រប់ឡើយ ។

## អវសានកាល

លុះមកដល់រសៀលថ្ងៃអង្គារ ១២ កើតខែភទ្របទឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៣ កញ្ញា ១៩៦៩ វេលាម៉ោង ១៥,៤៥ នាទី ព្រះសង្ឃដែលគាល់បម្រើព្រះអង្គបានឮសម្លេងកណ្ដឹងរោទ៍ ប៉ុក ខុសធម្មតាពីក្នុងក្រឡាព្រះបន្ទំ ក៏បបួលគ្នាតែចូលទៅគាល់ជាបន្ទាន់ គ្រានោះព្រះអង្គមានបន្ទូលថា "ចុកទ្រូងណាស់ៗ" ។ ក្រោយពីពេលបាត់

ការឲ្យទៅតាមគ្រូពេទ្យទាំងឡាយគឺ លោកវេជ្ជបណ្ឌិត ផា-ម៉េងជុង មី-សាមីឌី យូ-ភិមយាន ព្រំ-ភួន រស់-សារី វេជ្ជបណ្ឌិតជាតិបារាំងឈ្មោះ ម៉ាបារ៉ូ ជាដើម បានចូលមកព្យាបាលជាបន្ទាន់ ឃើញថាព្រះអាការរោគមិនជាធូរប៉ុន្មានទេ ប៉ុន្តែទោះបីយ៉ាងណា ក៏ក្រសួងសុ-ខាភិបាលបានចាត់លោកគ្រូពេទ្យ យូ-ភិមយាន និង លី-ភិមសាន ឲ្យមករក្សាព្រះរោគ និងប្រកបឱសថថ្វាយជាដរាប រហូតដល់ថ្ងៃព្រហស្បតិ ១៤ កើត ខែភទ្របទ ត្រូវនឹងថ្ងៃទី ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី ព្រះអស្សាសបស្សាសៈនៃព្រះអង្គបានចាកចេញពីព្រះកាយ ទ្រង់សោយទិវង្គតដោយស្ងប់ស្ងៀម នៅក្នុងព្រះរាជដំណាក់ព្រះអង្គ នាវត្តឧណ្ណាលោម ។

ក្នុងរយៈកាលដែលទ្រង់ប្រឈួននេះ ឯកឧត្តម អ៊ុង-ហ៊ុងសាន តាមព្រះរាជបញ្ជានៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ បានចាត់អស់លោកវេជ្ជបណ្ឌិតខ្មែរ បារាំង ដ៏ជំនាញៗ ទាំងទទួលខ្វល់ខ្វាយព្យាបាលព្រះរោគព្រះអង្គយ៉ាងពេញសមត្ថភាព ប៉ុន្តែធ្វើម្តេចឡើយនឹងយកជ័យជំនះបានលើអនិច្ចធម៌នោះ ។

សម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់បានដឹងព្រះអង្គជាមុនតាំងពីថ្ងៃប្រឈួនទ្រង់មានព្រះបន្ទូលប្រាប់ព្រះសង្ឃ និងអស់លោកដែលមកថ្វាយបង្គំសាកសួរព្រះសុខភាពថា : អាត្មាហាក់ដូចជាគ្មានសង្ឃឹមទេ . ..

ព្រះរាជបន្ទូលនេះធ្វើឲ្យយើងរាល់គ្នាមានការតក់ស្លុតណាស់ ប៉ុន្តែយើងរាល់គ្នានៅតែជឿថា : ព្រះអង្គនឹងនៅគង់ព្រះជន្មាយុតទៅទៀតបាន ពីព្រោះសង្កេតទៅ ព្រះសរីរាង្គព្រះអង្គ ពុំឃើញមានប្រែប្រួលប៉ុន្មាន ម្យ៉ាងវិញទៀត ទ្រង់នៅចាំព្រះស្មារតីល្អណាស់ អាចមានបន្ទូលសាសងសំណេះសំណាលនឹងអស់លោកដែលមកក្រាបបង្គំគាល់នោះបាន ៗ ជាពិសេស កាលពីព្រឹកនៃថ្ងៃសោយព្រះទិវង្គតនេះ សហជីវិនឯកឧត្តម លន់ នល់ នាយករដ្ឋមន្ត្រី និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-សិរិមត ឧបនាយករដ្ឋមន្ត្រីទី ១ បានចូលក្រាបបង្គំគាល់ព្រះអង្គ ដើម្បីសាកសួរព្រះរោគព្រះអង្គឯង និងដើម្បីក្រាបបង្គំលាព្រះអង្គទៅកាន់បរទេសផង ៗ គ្រានោះ ព្រះអង្គបានទទួលរាក់ទាក់ហើយបានប្រសិទ្ធិពរជូនចំពោះឯកឧត្តម នាយករដ្ឋមន្ត្រី និងថ្វាយចំពោះអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី ១ សូមទៅបំពេញបេសកកម្មនៅប្រទេសគេ បានជោគជ័យផង ៗ ក្រោយមកទៀត សម្តេចព្រះសង្ឃរាជជាទីគោរព ក៏បានព្រះរាជទានសន្ទនាជាមួយសហជីវិន ប៊ី-ឡុច រដ្ឋលេខាធិការក្រសួងធម្មការ និងសហជីវិន ទ្រឹញ-ហ៊ាញ ប្រធានសមាគមអ្នកនិពន្ធខ្មែរ អំពីការធ្វើចេតិយ ៗ ព្រះអង្គទ្រង់មានបន្ទូលហៅ ហើយនិទានអំពីចេតិយឈ្មោះ សិទ្ធត្ថៈ នៅសហភាពភូមាថែមទៀតផង ៗ រួចព្រះអង្គត្រាស់រំលឹកអំពីការបោះពុម្ពវចនានុក្រម ដែលទ្រង់បានរិតរំកែសម្រួលបន្ថែមពាក្យជាច្រើនទៀត

ទោះបីជាកឋិនព្យាធិចេះតែបៀតបៀនព្រះអង្គហើយក្ដី ។ សភាពអស់ទាំងនេះសឲ្យឃើញថាព្រះអង្គនៅរឹងប៉ឹងណាស់ មិនគួរឡើយប្រែប្រួលទៅជា យើងកល់គ្នាមានការសោយសោកដូច្នេះសោះ ។ នេះហើយសមដូច ព្រះពុទ្ធដីការបស់ព្រះអង្គដែលទ្រង់មានព្រះបន្ទូលជារឿយ ៗ ថា : មនុស្សជួបគ្នារញ៉ង់ពីព្រឹក លុះល្ងាចក៏អាចបែកគ្នារហូត សភាពនេះត្រូវដូចព្រះបន្ទូលនោះណាស់ ព្រះអង្គយាងទៅពេលពុទ្ធបរិស័ទកល់គ្នាហាក់គ្មានព្រាងទុក ជាទីគួរឲ្យស្ដាយណាស់ រកពាក្យថ្លែងពុំបានទេព្រះអង្គសោយព្រះទីវង្គត ធ្វើឲ្យរញ្ជួយមួយសកលកម្ពុជា ព្រោះព្រះអង្គប្រកបដោយគុណធម៌គួរគោរពប្រពៃក្រៃលែង ។